ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# ប្រវត្តិវិទ្យា

សម្រាប់

## កម្រិតមធ្យមសិក្សាបឋមភូមិ

២០១៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥០៣ **អយក.**

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា កម្រិតមធ្យមសិក្សាបឋមភូមិ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៦៩/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១ ..**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិ**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២** .-

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិនេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្ដីផ្ដើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣** .-

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤** .-

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៣រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

**កន្លែងទទួល** :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អគ.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សានិងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតមធ្យមសិក្សាបឋមភូមិនេះ បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ សំដៅកសាងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំនៅកម្រិតបន្តដោយពង្រីកវិសាលភាពចំណេះដឹង បំណិនការអប់រំសីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ព្រមទាំងផ្តល់នូវចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យា បំណិនសតវត្សរ៍ទី២១ និងបំណិនសិក្សាពេញមួយជីវិត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ប្រវត្តិសាស្ត្រជាផ្នែកមួយនៃអត្តសញ្ញាណ និងមោទនភាពនៃជាតិមួយ និងពិភពលោកដែលប្រជាជនត្រូវមានកាតព្វកិច្ចសិក្សា ស្វែងយល់ វិភាគ វាយតម្លៃ និងទាញយកបទពិសោធន៍ពីប្រវត្តិសាស្ត្រ ទោះបីជាប្រវត្តិសាស្ត្រមួយចំនួនមានលក្ខណៈរន្ធត់ និងប្រកបដោយភាពអាម៉ាស់ ដូចជាអំពើប្រល័យពូជសាសន៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ។ ការទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រ ការចងចាំ ការចង់ដឹង និងចង់ស្វែងយល់ពីប្រវត្តិសាស្ត្រជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ និងការធានាចីរភាពអភិវឌ្ឍន៍ និងសន្តិភាព ជាពិសេសសម្រាប់ប្រទេសដែលទើបរួចផុតពីជម្លោះដូចជាប្រទេសកម្ពុជា។ ចំណេះ និងបំណិនប្រើប្រាស់ប្រវត្តិសាស្ត្រមានឥទ្ធិពលទៅលើឥរិយាបថផ្លូវចិត្ត និងការប្រព្រឹត្តរបស់ប្រជាជននាពេលបច្ចុប្បន្ន និងទៅអនាគត។ ការខ្វះខាតចំណេះដឹង និងបំណិនផ្នែកប្រវត្តិសាស្ត្រ ការយល់ខុស និងការបកស្រាយដោយគ្មានភស្តុតាងបុរាណវិទ្យា និងវិទ្យាសាស្ត្រ អាចបង្កជម្លោះក្នុងប្រទេសមួយ ឬរវាងប្រទេសនិងប្រទេសទាំងក្នុងពេលបច្ចុប្បន្ន និងតទៅអនាគត។

បេសកកម្មនៃការសិក្សាប្រវត្តិសាស្ត្រ គឺសំដៅយល់ដឹងឱ្យច្បាស់អំពីខ្លួនឯង ពិចារណាអំពីផលប៉ះពាល់ និងផលវិបាកនៃប្រវត្តិសាស្ត្រ និងប្រើប្រវត្តិសាស្ត្រដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួម និងការទទួលខុសត្រូវក្នុងដំណើរការសង្គម។ ចំណេះដឹង និងបំណិនប្រវត្តិសាស្ត្រប្រកបដោយការត្រិះរិះពិចារណា និងការទទួលខុសត្រូវនឹងប្រែក្លាយអ្នកសិក្សាឱ្យទៅជាពលរដ្ឋសកម្ម ប្រកបដោយវិជ្ជាជីវៈ និងមនសិការ។ អតីតកាលជាប្រទីបបំភ្លឺបច្ចុប្បន្នកាល និងបង្ហាញផ្លូវទៅកាន់អនាគតកាល និងបង្កើតទំនាក់ទំនងរវាងបច្ចុប្បន្ន និងអនាគតដែលមិនអាចកាត់ផ្តាច់បាន។ ប្រសិនបើ អ្នកសិក្សាស្គាល់អតីតកាលកាន់តែច្បាស់ អ្នកសិក្សានឹងមានលទ្ធភាពរៀបចំអនាគតបានកាន់តែប្រសើរ។ ប្រជាជាតិមួយដែលគ្មានចំណេះដឹងអំពីអតីតកាល គឺមានន័យថា បានបាត់បង់អត្តសញ្ញាណ។ ពលរដ្ឋដែលស្គាល់ច្បាស់ពីអត្តសញ្ញាណជាតិ គឺស្រឡាញ់ជាតិ ខំបំពេញភាររកិច្ចកសាង និងការពារជាតិ ដោយការទទួលខុសត្រូវ និងមនសិការ។

**អនុគណៈកម្មការមុខវិជ្ជាឯកទេសប្រវត្តិវិទ្យា**

# មាតិកា

ប្រកាស........................................ i
បុព្វកថា........................................ iii
អារម្ភកថា........................................ iv
មាតិកា........................................ v
១- សេចក្តីផ្តើម........................................ ១
២- គោលបំណង........................................ ១
៣- គោលគំនិតៗសំខាន់ៗ........................................ ៣
៤- របាយម៉ោងសិក្សា........................................ ៧
៥- ការណែនាំអនុវត្ត........................................ ៨
៦- ការវាយតម្លៃ........................................ ១០
៧- តារាងកម្មវិធីសិក្សា........................................ ១២
៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៧........................................ ១២
៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៨........................................ ៣០
៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៩........................................ ៤៧
៨- សន្ទានុក្រម ........................................ ៦៤
៩- ឯកសារយោង........................................ ៦៥
១០- បញ្ជីឈ្មោះគណៈកម្មការ........................................ ៦៨

## ១- សេចក្តីផ្តើម

កម្មវិធីសិក្សាប្រវត្តិវិទ្យាសម្រាប់ប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស ចាប់ពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ត្រូវបានតាក់តែងឡើងតាមគោលវិធីរៀនបែបរិះរក លទ្ធផលរំពឹងទុក និងសិក្សាបញ្ញត្តិ។ ក្រោយពីបានសិក្សាប្រវត្តិវិទ្យា នៅគ្រប់ភូមិសិក្សាពីបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ អ្នកសិក្សាត្រូវទទួលបានគុណសម្បទាខ្ពស់បំផុតដើម្បីក្លាយទៅជាពលរដ្ឋពេញលេញដែលចេះប្រើភស្តុតាងបុរាណវិទ្យា បាតុភូត និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាប្រយោជន៍ដល់ចីរភាពអភិវឌ្ឍ និងសន្តិភាពក្នុងពេលបច្ចុប្បន្ន និងអនាគត។

## ២- គោលបំណង

### ២.១- ការអប់រំប្រវត្តិវិទ្យា

ការអប់រំប្រវត្តិវិទ្យានឹងរួមចំណែកដល់ការប្រែក្លាយអ្នកសិក្សាឱ្យទៅជាពលរដ្ឋពេញលេញ ស្របតាមគោលបំណងរបស់ក្របខ័ណ្ឌកម្មវិធីសិក្សាជាតិ ដែលបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៥ ដោយបំពេញសក្តានុពលជាពលរដ្ឋដែលមាន ៖

- **ការទទួលខុសត្រូវខ្ពស់**ចំពោះរាល់ការសម្រេចចិត្ត និងការប្រព្រឹត្តរបស់ខ្លួន
- **ហេតុផល ដឹងខុសដឹងត្រូវ ចេះត្រិះរិះពិចារណា និងចេះប៉ាន់ប្រមាណ**អំពីឧបសគ្គ
- **គំនិតផ្តួចផ្តើម និងការច្នៃប្រឌិត** ក្នុងការរកដំណោះស្រាយបញ្ហា
- **សុទិដ្ឋិនិយម ភាពអត់ធ្មត់ និងមិនទន់ជ្រាយ**ចំពោះឧបសគ្គ ឬការលំបាក
- **ភាពជឿជាក់ និងឧត្តមភាព**ក្នុងការធ្វើការងារជាក្រុមជាប្រយោជន៍ដល់មនុស្សជាតិ
- **មានសីលធម៌ សុជីវធម៌ និងគុណធម៌** ព្រមទាំង**គិតអំពីប្រយោជន៍មនុស្សជាតិ**។

### ២.២- គុណសម្បទាអ្នកសិក្សាប្រវត្តិវិទ្យា

ពលរដ្ឋគ្រប់ៗរូបសុទ្ធតែត្រូវការសេចក្តីសុខ និងវឌ្ឍនភាព ទាំងផ្លូវកាយ ផ្លូវចិត្ត និងចិត្តសង្គម ដោយពឹងអាស្រ័យជាធំលើវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយា។ ដើម្បីស្ថាបនានិងរក្សាសេចក្តីសុខ និងវឌ្ឍនភាពនេះ អ្នកសិក្សាប្រវត្តិវិទ្យាគ្រប់ៗរូប ត្រូវអភិវឌ្ឍគុណសម្បទាមនុស្សខ្លាំងពូកែដែលមានទាំងវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយា បូករួមទាំងគុណសម្បទាពលរដ្ឋសកល គុណសម្បទាសតវត្សរ៍ទី២១ និងគុណសម្បទាប្រវត្តិវិទ្យា។ ពិភពលោកក្នុងសតវត្សរ៍ទី២១ ត្រូវការពលរដ្ឋដែលមានគុណសម្បទាជាពលរដ្ឋពេញលេញ ដើម្បីរួមចំណែកដល់ចីរភាពអភិវឌ្ឍន៍ និងសន្តិភាពឱ្យពិភពលោក។ កម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងមានប្រាក់ចំណូលមធ្យមកម្រិតទាប កាន់តែត្រូវការពលរដ្ឋប្រភេទនេះ ដើម្បីប្រែក្លាយឱ្យទៅជាប្រទេសអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៥០ និងជាសន្តិប្រទេសជានិរន្តរ៍។ ដូច្នេះ សិស្សរៀននៅគ្រប់ភូមិសិក្សាត្រូវការឱ្យប្រព័ន្ធអប់រំបំពាក់គុណសម្បទាជាពលរដ្ឋពេញលេញចាប់ពីពេលនេះតទៅ តាមរយៈការពង្រីកកម្មវិធីសិក្សាគ្រប់មុខវិជ្ជា និងអភិវឌ្ឍគុណសម្បទាគ្រូពូកែ។ ក្រោយពីបានសិក្សាប្រវត្តិវិទ្យានៅសាលាចំណេះទូទៅ និងបច្ចេកទេស ចាប់ពីបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ អ្នកសិក្សាប្រវត្តិវិទ្យានឹងបានអភិវឌ្ឍគុណសម្បទាជាពលរដ្ឋពេញលេញ ចេះប្រើភស្តុតាង ទិន្នន័យ និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្របម្រើប្រយោជន៍មនុស្សជាតិ ៖

### ២.២.១- វិជ្ជាសម្បទា

- សន្និដ្ឋានរួមអំពីគោលបំណង និងចំណងពាក់ព័ន្ធនៃប្រវត្តិសាស្ត្រ សម្រាប់ផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃរបស់មនុស្ស និងធម្មជាតិ ក្នុងបច្ចុប្បន្នកាល និងអនាគតកាល
- ពន្យល់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ទាំងនៅមើលឃើញ និងបាត់បង់ ដូចជា មនុស្ស ទីកន្លែង ដោយប្រើភស្តុតាងបុរាណវិទ្យា និងវិទ្យាសាស្ត្រ
- ចងក្រងប្រវត្តិសាស្ត្រនៃបម្រែបម្រួលសង្គមមនុស្ស ទីកន្លែង មរតកវប្បធម៌ និងធម្មជាតិក្នុងអតីតកាលដែលបន្តនិរន្តរភាពមកដល់បច្ចុប្បន្ន និងទៅអនាគត

### ២.២.២- បំណិនសម្បទា

- បង្កើតទម្រង់ និងមធ្យោបាយនៃការប្រាស្រ័យទាក់ទងល្អ និងវិជ្ជមាន ជាមួយមនុស្ស ធម្មជាតិ និងមរតកប្រវត្តិសាស្ត្រ
- វិភាគចលករនៃបម្រែបម្រួលប្រជាសាស្ត្រ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលបានបង្កើតប្រវត្តិសាស្ត្រក្នុងប្រទេស តំបន់ និងពិភពលោក
- បង្កើតជម្រើស និងមធ្យោបាយនៃដំណោះស្រាយបញ្ហាវប្បធម៌ សង្គម សេដ្ឋកិច្ច និងនយោបាយប្រកបដោយការទទួលខុសត្រូវ ក្រមសីលធម៌ និងច្នៃប្រឌិត

### ២.២.៣- ចរិយាសម្បទា

- ឱ្យតម្លៃចំពោះភាពរួម ភាពដោយឡែក និងនានាភាព នៃវប្បធម៌ សាសនា ទំនៀមទម្លាប់ ជំនឿ និងប្រពៃណី ក្នុងប្រវត្តិសាស្ត្រ ទាំងក្នុងប្រទេស តំបន់ និងពិភពលោក
- ផ្សារភ្ជាប់គុណតម្លៃនៃមរតកប្រវត្តិសាស្ត្រទៅនឹងបច្ចុប្បន្នកាល និងអនាគតកាល
- បណ្តុះសុជីវធម៌ សីលធម៌ គុណធម៌ សម្មាទិដ្ឋិ និងការច្នៃប្រឌិតដោយរៀនសូត្រពីមរតកប្រវត្តិសាស្ត្រ។

## ២.៣- មធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ដល់៩

ដើម្បីធានាសម្រេចគោលដៅអប់រំ ក្នុងការបំពាក់គុណសម្បទាជាពលរដ្ឋពេញលេញ កម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាបឋមភូមិ បំពាក់គុណសម្បទាប្រវត្តិវិទ្យា គុណសម្បទាសតវត្សទី២១ និងគុណសម្បទាពលរដ្ឋសកល។ ក្នុងកម្រិតអប់រំមធ្យមសិក្សាបឋមភូមិចាប់ពីថ្នាក់ទី៧ដល់ទី៩ សិស្សចូលក្នុងវ័យប្រហែលពី១៣ដល់១៥ឆ្នាំ ដែលមានសញ្ញាណបញ្ញាក្នុងការស្វែងយល់អំពីពិភពខាងក្រៅ ចង់ឃើញពិភពលោកដែលល្អប្រសើរ មានបេះដូងចង់ជួយអ្នកដទៃ ចង់ក្លាយជាមនុស្សខ្លាំងពូកែ និងត្រៀមខ្លួនចូលប្រឡូកក្នុងដំណើរការសង្គមដែលមានការប្រែប្រួលឆាប់រហ័ស និងមានចំណងប្រទាក់ក្រឡាគ្រប់ស្រទាប់។ លើសពីនេះទៀត សិស្សក្នុងវ័យនេះត្រូវការគុណសម្បទាជាមនុស្សពេញលេញ រួមមានវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយា សម្រាប់យកទៅបន្តការសិក្សា បម្រើមនុស្សជាតិ និងរស់ក្នុងសង្គមដ៏ស្មុគស្មាញ និងនវកម្មសេដ្ឋកិច្ច។ ដូច្នេះ ការសិក្សាប្រវត្តិវិទ្យាត្រូវបំពាក់គុណសម្បទាខាងក្រោម ៖

- **វិជ្ជាសម្បទា**
    - ភ្ជាប់សារៈសំខាន់នៃអរិយធម៌ វប្បធម៌ សង្គម នយោបាយ និងសេដ្ឋកិច្ច ក្នុងប្រវត្តិសាស្ត្រ តាមប្រទេស តំបន់ និងពិភពលោក សម្រាប់ជាប្រយោជន៍ដល់ជីវភាពប្រចាំថ្ងៃរបស់មនុស្សជាតិក្នុងបច្ចុប្បន្នកាល និងអនាគតកាល
    - ប្រើបុច្ចនបំណិន និងសង្កប្បបំណិនដើម្បីស្វែងយល់អំពីភស្តុតាង និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ សម្រាប់បន្តការសិក្សា និងជីវភាពរស់នៅប្រចាំថ្ងៃ
- **បំណិនសម្បទា**
    - ប្រាស្រ័យទាក់ទងល្អ និងវិជ្ជមានជាមួយធម្មជាតិ មនុស្ស និងមរតកប្រវត្តិសាស្ត្រ ក្នុងគ្រួសារ សាលារៀន ភូមិ សហគមន៍ ប្រទេស តំបន់ និងពិភពលោក
- **ចរិយាសម្បទា**
    - ដាំបណ្ដុះការគិត វាចា ទម្លាប់ និងការប្រព្រឹត្តវិជ្ជមានក្នុងការថែរក្សា និងអភិវឌ្ឍមរតកប្រវត្តិសាស្ត្រ ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ
    - ប្រតិបត្តិគោលការណ៍នៃសុជីវធម៌ សីលធម៌ និងគុណធម៌ ជាប្រយោជន៍ដល់មនុស្សជាតិ។
    - វិនិច្ឆ័យពីតម្លៃនៃភាពរួម ភាពដោយឡែក និងនានាភាពនៃអរិយធម៌ វប្បធម៌ សង្គម នយោបាយ និងសេដ្ឋកិច្ច ក្នុងប្រវត្តិសាស្ត្រ តាមប្រទេស តំបន់ និងពិភពលោក

## ៣- គោលគំនិតសំខាន់ៗ

### ៣.១- គោលវិធីរៀននិងបង្រៀន

គោលវិធីរៀននិងបង្រៀនមានច្រើនបែបច្រើនយ៉ាងកំពុងអនុវត្តតាមសាលារៀន ដូចជា គោលវិធីរៀនបែបរិះរក គោលវិធីសិស្សមជ្ឈមណ្ឌល គោលវិធីរៀនបែបសហការ គោលវិធីរៀនបែបគម្រោង និងគោលវិធីរៀនតាមបញ្ហា។ ការសរសេរកម្មវិធីសិក្សាប្រវត្តិវិទ្យា ប្រើគោលវិធីរៀនបែបរិះរក។ គោលវិធីនេះបង្កបរិយាកាសរៀននិងបង្រៀន ដោយឱ្យអ្នកសិក្សា និងគ្រូបង្រៀនចេះប្រើការឆ្ងល់ ការសួរ ការស្រាវជ្រាវ និងឆ្លើយតបទៅនឹងតម្រូវការនិងធម្មជាតិរបស់កុមារ និងយុវជនក្នុងសតវត្សរ៍ទី២១។ គោលវិធីនេះជួយអ្នកសិក្សាឱ្យមានបុច្ចនបំណិន និងសង្កប្បបំណិន ដោយចេះគិត វិភាគ និងសន្និដ្ឋាន និងប្រើភស្តុតាង បានពីការស្រាវជ្រាវ និងប្រែក្លាយពីការឆ្ងល់ឱ្យទៅជាពុទ្ធិថ្មី។

### ៣.២- លទ្ធផលសិក្សារំពឹងទុក

សាកល្បងគិតបន្តិចមើល! មុនចូលរៀនមួយម៉ោង ឬតិចជាងមួយម៉ោងជាមួយគ្រូបង្រៀនម្នាក់ លើមុខវិជ្ជាប្រវត្តិវិទ្យា តើអ្នកត្រូវទទួលបានវិជ្ជាអ្វី បំណិនអ្វី និងចរិយាអ្វីពីមេរៀននេះ សម្រាប់ជាប្រយោជន៍ដល់ការសិក្សាបន្ត ការរស់នៅប្រចាំថ្ងៃ និងជួយធ្វើឱ្យប្រសើរដល់សង្គម?

ឧទាហរណ៍ រៀនមេរៀនអំពីមនុស្សសំខាន់ៗ ក្នុងប្រវត្តិសាស្ត្រខ្មែរនៅសតវត្សរ៍ទី៩ តើអ្នកត្រូវទទួលបានវិជ្ជាអ្វី បំណិនអ្វី និងចរិយាអ្វីពីមេរៀននេះ ដើម្បីយកទៅប្រើជាគោលប្រយោជន៍ ដល់ការសិក្សាបន្ត ដល់ជីវភាពប្រចាំថ្ងៃ និងដើម្បីជួយដល់អ្នកដទៃ គ្រួសារ សាលារៀន សហគមន៍ ប្រទេស តំបន់ និងពិភពលោក ក្នុងបច្ចុប្បន្នកាល និងអនាគតកាល? ខ្ញុំត្រូវការរៀនអំពីគោលការណ៍ដឹកនាំប្រទេសរបស់ព្រះរាជាសម័យកាលទាំងនោះ អំពីចរិតលក្ខណៈជាអ្នកដឹកនាំដោយឈរលើគោលការណ៍ទសពិធរាជធម៌ និងចង់វិភាគអំពីកត្តានាំឱ្យចក្រភពអង្គររុងរឿង ហើយខ្ញុំក៏ត្រូវការភ្ជាប់ទម្រង់នៃការដឹកនាំរបស់ព្រះរាជាសម័យកាលមុនៗទៅនឹងទម្រង់នៃការដឹកនាំប្រទេសបច្ចុប្បន្ន និងអនាគត។

លទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាសំដៅដល់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលត្រូវប្រើក្នុងការសិក្សាបន្ត ជីវភាពប្រចាំថ្ងៃ និងការងារជាប្រយោជន៍ដល់មនុស្សជាតិ។

### ៣.៣- សិក្សាបញ្ញត្តិ

កម្មវិធីសិក្សាប្រវត្តិវិទ្យាផ្ដោតលើគោលសំខាន់មួយទៀតគឺសិក្សាបញ្ញត្តិ។ សិក្សាបញ្ញត្តិនាំផ្លូវសិស្សនិងគ្រូ ឱ្យគិត និងស្វែងយល់តាមរយៈការឆ្លុះទៅលើខ្លឹមសារគោលនៃមេរៀន និងប្រែក្លាយការឆ្លុះឱ្យទៅជាពុទ្ធិថ្មីពីបញ្ញត្តិនីមួយៗក្នុងមេរៀន។ គ្រប់មេរៀននៃមុខវិជ្ជាប្រវត្តិវិទ្យានៅគ្រប់កម្រិត ផ្ដល់លំនាំឱ្យសិស្សស្វែងយល់ពីបញ្ញត្តិជាមុន ដើម្បីឈានទៅទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពីមេរៀន តាមរយៈសកម្មភាពស្រាវជ្រាវ រៀន និងបង្រៀន។

### ៣.៤- គុណតម្លៃនៃប្រវត្តិវិទ្យា

ប្រវត្តិសាស្ត្រជាអត្តសញ្ញាណ និងមោទនភាពនៃប្រជាជាតិមួយ និងពិភពលោកទាំងមូល។ ដូច្នេះ ជាប្រជាជននៃជាតិមួយ និងរបស់ពិភពលោក ត្រូវមានកាតព្វកិច្ចសិក្សា វិភាគ វាយតម្លៃ ទាញយកបទពិសោធន៍ និងប្រើប្រាស់ភស្តុតាង និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាប្រយោជន៍ដល់មនុស្សជាតិ ព្រមទាំងចេះវាយតម្លៃបច្ចុប្បន្នកាល និងធ្វើចំណោលអំពីអនាគតកាល។ ដូចគ្នានេះដែរ ការសិក្សាប្រវត្តិវិទ្យា គឺសំដៅអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីរកមធ្យោបាយ និងជម្រើសនៃដំណោះស្រាយបញ្ហាសង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយ ព្រមទាំងរួមចំណែកដល់ចីរភាពអភិវឌ្ឍន៍ និងសន្តិភាពសម្រាប់មនុស្សជាតិ។

ក្រោយពីទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ពីការសិក្សាប្រវត្តិសាស្ត្រ អ្នកសិក្សានឹងផ្លាស់ប្ដូរការគិត ការសម្រេចចិត្ត និងការប្រព្រឹត្ត ព្រមទាំងចេះវាយតម្លៃអំពីខ្លួនឯង ពិចារណាអំពីផលប៉ះពាល់ និងផលវិបាកនៃប្រវត្តិសាស្ត្រ ព្រមទាំងប្រកាន់ខ្ជាប់ និងប្រតិបត្តិគោលការណ៍សុជីវធម៌ សីលធម៌ និងគុណធម៌ជាប្រយោជន៍ដល់មនុស្សជាតិ។

### ៣.៥- ទស្សនវិជ្ជានៃប្រវត្តិវិទ្យា

ការសិក្សាប្រវត្តិវិទ្យាសំដៅបណ្ដុះការគិត វាចា ទម្លាប់ និងការប្រព្រឹត្តវិជ្ជមាន និងប្រកបដោយការច្នៃប្រឌិតរបស់អ្នកសិក្សា ដោយឱ្យអ្នកសិក្សាចេះកោតសរសើរចំពោះមរតកប្រវត្តិសាស្ត្រ និងផ្សារភ្ជាប់ប្រវត្តិសាស្ត្រទៅនឹងបច្ចុប្បន្នកាល និងអនាគតកាល ព្រមទាំងប្រើប្រាស់បទពិសោធន៍អតីតកាល ដើម្បីជាមេរៀនជីវិត ក្នុងការបង្កើតជម្រើសនៃដំណោះស្រាយបញ្ហា និងបញ្ចៀសបញ្ហានៃកំហុសប្រវត្តិសាស្ត្រដដែលៗ។

### ៣.៦- ប្រវត្តិវិទ្យានិងគុណសម្បទាពលរដ្ឋសកល

ក្នុងយុគសម័យបច្ចេកវិទ្យាព័ត៌មាន និម្មិតកម្មសង្គម និងនវកម្មសេដ្ឋកិច្ច មនុស្សត្រូវមានអន្តរទំនាក់ទំនងជាមួយជាតិសាសន៍ នយោបាយ វប្បធម៌ សង្គម និងសេដ្ឋកិច្ចនៃប្រទេសដទៃនៅទូទាំងពិភពលោក។ ការរីកចម្រើនដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាកំពុងជំរុញ និងពង្រីកសក្ដានុពលដល់សកលភាវូបនីយកម្ម ដូច្នេះពលរដ្ឋគ្រប់ជាតិសាសន៍ ត្រូវរួមរស់ជាមួយគ្នា និងឱ្យតម្លៃចំពោះភាពរួមគ្នា ភាពដោយឡែក និងនានាភាពនៃវប្បធម៌ នយោបាយ សាសនា ទំនៀមទម្លាប់ ប្រពៃណី និងជំនឿផ្សេងៗគ្នា។ ការស្រាវជ្រាវជាច្រើនបានរកឃើញថា ពលរដ្ឋដែលមានគុណសម្បទាពលរដ្ឋសកល អាចរស់នៅ និងធ្វើការក្នុងគ្រប់បរិបទនៃប្រពៃណី ទំនៀមទម្លាប់ និងជំនឿ និងចូលរួមដល់ចីរភាពអភិវឌ្ឍន៍ និងសន្តិភាពពិភពលោក។ ដូច្នេះ ដើម្បីធានាឱ្យមនុស្សជំនាន់ក្រោយរស់ក្នុងសេចក្ដីសុខ វឌ្ឍនភាព និងសន្តិភាពជាមួយពិភពលោក កម្មវិធីសិក្សាមុខវិជ្ជាប្រវត្តិវិទ្យាក្នុងប្រព័ន្ធអប់រំ ចាប់ពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ត្រូវបញ្ចូលគុណសម្បទាពលរដ្ឋសកល។ ការបញ្ចូលគុណសម្បទាពលរដ្ឋសកលផ្ដល់ប្រយោជន៍ដល់អ្នកសិក្សា និងសង្គមតាមមធ្យោបាយធំៗបី ៖

- បង្ហាញផែនទីអំពីផលនៃអតីតកាលបន្សល់ទុកឱ្យបច្ចុប្បន្ន និងបន្តរក្សាឱ្យអនាគត នូវទំនាក់ទំនងរវាងមនុស្សនិងមនុស្ស ប្រទេស តំបន់ និងពិភពលោក
- វិភាគបាតុភូត ចលករ និងព្រឹត្តិការណ៍សង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយ ដោយប្រើភស្តុតាងបុរាណវិទ្យា និងវិទ្យាសាស្ត្រ និងវិធីសាស្ត្រប្រវត្តិសាស្ត្រ កម្រិតមូលដ្ឋាន ប្រទេស តំបន់ និងពិភពលោក
- បង្កើតទម្រង់ និងជម្រើសនៃដំណោះស្រាយបញ្ហាសង្គម វប្បធម៌ នយោបាយ និងសេដ្ឋកិច្ច ប្រកបដោយការទទួលខុសត្រូវ និងការច្នៃប្រឌិត ដោយប្រើវិធីសាស្ត្រប្រវត្តិសាស្ត្រ និងប្រកាន់ខ្ជាប់គោលការណ៍សន្តិភាពសម្រាប់ជាប្រយោជន៍ដល់មូលដ្ឋាន ប្រទេស តំបន់ និងពិភពលោក។

### ៣.៧- ប្រវត្តិវិទ្យា និងគុណសម្បទាសតវត្សរ៍ទី២១

ការអភិវឌ្ឍបច្ចេកវិទ្យា និម្មិតកម្មសង្គម និងនវកម្មសេដ្ឋកិច្ចកំពុងបង្កើតឱ្យមានបដិវត្តន៍ថ្មីមួយ ហៅថា បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ បដិវត្តន៍ថ្មីនេះបាននាំមកនូវសកលភាវូបនីយកម្មដ៏ប្រទាក់ក្រឡា និងបម្រែបម្រួលប្រជាសាស្ត្រ សង្គម វប្បធម៌ នយោបាយ សេដ្ឋកិច្ច និងទម្រង់នៃការរស់នៅរបស់មនុស្ស ដែលពឹងអាស្រ័យជាធំលើអ៊ីនធឺណែត ឌីជីថល និងឧបករណ៍បច្ចេកវិទ្យាព័ត៌មាន។ ការស្រាវជ្រាវជាច្រើនបានរកឃើញថា ការរីកចម្រើនផ្នែកបច្ចេកវិទ្យានៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ មានល្បឿនពហុគុណលឿនជាងបដិវត្តន៍ឧស្សាហកម្មជំនាន់មុនៗ។ ដើម្បីធានាឱ្យមនុស្សជំនាន់ក្រោយរស់នៅល្អប្រសើរ មានសេចក្ដីសុខ និងទាន់បច្ចេកវិទ្យានៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ កម្មវិធីសិក្សាប្រវត្តិវិទ្យាត្រូវបញ្ចូលគុណសម្បទាសតវត្សរ៍ទី២១ បន្ថែមលើគុណសម្បទាប្រវត្តិវិទ្យា និងពលរដ្ឋសកល។

**គុណសម្បទាសតវត្សរ៍ទី២១**



## ៣.៨- ប្លង់គោលនៃមេរៀន

**ថ្នាក់ទី៧**

**ជំពូកទី១ ប្រវត្តិសាស្ត្រកម្ពុជា និងអរិយធម៌**

មេរៀនទី១៖ ប្រវត្តិវិទ្យា និងការសិក្សាចងក្រង

មេរៀនទី២៖ បុរេប្រវត្តិ និងការផ្លាស់ប្តូរទីកន្លែងរស់នៅ

មេរៀនទី៣៖ ហ្វូណន និងឥទ្ធិពលឥណ្ឌា

មេរៀនទី៤៖ ចេនឡា និងសុខដុមភាព

មេរៀនទី៥៖ អង្គរ និងអរិយធម៌ខ្ពង់ខ្ពស់

**ជំពូកទី២ ប្រវត្តិសាស្ត្រតំបន់ «យុគ និងការវិវត្ត»**

មេរៀនទី១៖ បុរេប្រវត្តិសាស្ត្រ (៦៨០ ០០០ឆ្នាំ-១០០ឆ្នាំមុនគ.ស.)

មេរៀនទី២៖ រដ្ឋដំបូងៗ (ស.វ.ទី១-ស.វ.ទី៨)

**ជំពូកទី៣ ប្រវត្តិសាស្ត្រពិភពលោក និងអរិយធម៌**

មេរៀនទី១៖ បុរេប្រវត្តិសាស្ត្រ និងកំណើតអរិយធម៌ពិភពលោក

មេរៀនទី២៖ អេហ្ស៊ីបបុរាណ និងអរិយធម៌

មេរៀនទី៣៖ ពិភពក្រិក និងលទ្ធិប្រជាធិបតេយ្យ

មេរៀនទី៤៖ ចក្រភពរ៉ូម និងសាធារណរដ្ឋ

មេរៀនទី៥៖ ឥណ្ឌាបុរាណ និងអរិយធម៌

មេរៀនទី៦៖ ចិនបុរាណ និងអរិយធម៌

មេរៀនទី៧៖ អាមេរិកកណ្តាល និងអរិយធម៌

មេរៀនទី៨៖ មជ្ឈិមបូព៌ា និងអរិយធម៌បុរាណ

**ថ្នាក់ទី៨**

**ជំពូកទី១ ប្រវត្តិសាស្ត្រកម្ពុជា និងអរិយធម៌**

មេរៀនទី១៖ ចតុមុខ និងអត្តសញ្ញាណ

មេរៀនទី២៖ លង្វែក និងការពង្រឹងអំណាចឡើងវិញ

មេរៀនទី៣៖ ឧដុង្គ និងការរក្សានិរន្តរភាព

មេរៀនទី៤៖ អាណាព្យាបាលបារាំង និងអភិក្រមទំនើបកម្ម

**ជំពូកទី២ ប្រវត្តិសាស្ត្រតំបន់ "អាស៊ីអាគ្នេយ៍ និងឥទ្ធិពលខាងក្រៅ** (ស.វ.ទី៨-ស.វ.ទី១៥)

មេរៀនទី១៖ អាស៊ីអាគ្នេយ៍ និងឥទ្ធិពលម៉ុងហ្គោល

មេរៀនទី២៖ ឥទ្ធិពលវប្បធម៌ចិន និងផ្លូវពាណិជ្ជកម្ម

មេរៀនទី៣៖ អាស៊ីអាគ្នេយ៍ និងសាសនាឥស្លាម

មេរៀនទី៤៖ អាស៊ីអាគ្នេយ៍ និងឥទ្ធិពលអឺរ៉ុប

មេរៀនទី៥៖ អាស៊ីអាគ្នេយ៍ និងសាសនាគ្រិស្ត

**ជំពូកទី៣ ប្រវត្តិសាស្ត្រពិភពលោក "របកគំហើញដែនដីថ្មី និងបម្រែបម្រួលសង្គម"**

មេរៀនទី១៖ មជ្ឈិមសម័យនៅអឺរ៉ុប និងរបកគំហើញដែនដី

មេរៀនទី២៖ បដិវត្តន៍គហបតីអង់គ្លេស និងអត្ថន័យជាប្រវត្តិសាស្ត្រ

មេរៀនទី៣៖ សង្គ្រាមដណ្តើមឯករាជ្យ និងការបង្កើតសហរដ្ឋអាមេរិក

មេរៀនទី៤៖ បដិវត្តន៍គហបតីបារាំង និងរបបសាធារណរដ្ឋ

**ថ្នាក់ទី៩**

**ជំពូកទី១ ប្រវត្តិសាស្ត្រកម្ពុជា និងអរិយធម៌**

មេរៀនទី១៖ សង្គមរាស្ត្រនិយម និងយុគមាស

មេរៀនទី២៖ សាធារណរដ្ឋខ្មែរ និងសង្គ្រាមស៊ីវិល

មេរៀនទី៣៖ កម្ពុជាប្រជាធិបតេយ្យ និងបដិវត្តន៍

មេរៀនទី៤៖ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា និងការរស់ឡើងវិញ

មេរៀនទី៥៖ ព្រះរាជាណាចក្រទី២ និងស្ថិរភាព

**ជំពូកទី២ ប្រវត្តិសាស្ត្រតំបន់ "ពាណិជ្ជកម្ម និងបម្រែបម្រួលសង្គមសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ (ស.វ.ទី១៥-ស.វ.ទី១៨)"**

មេរៀនទី១៖ វប្បធម៌ថ្មី និង ពាណិជ្ជកម្មអឺរ៉ុប

មេរៀនទី២៖ អាស៊ីអាគ្នេយ៍ និងពាណិជ្ជកម្មចិន

មេរៀនទី៣៖ អាស៊ីអាគ្នេយ៍ និងពាណិជ្ជកម្មព័រទុយហ្កាល់

មេរៀនទី៤៖ អាស៊ីអាគ្នេយ៍ និងពាណិជ្ជកម្មហូឡង់ និងអង់គ្លេស

**ជំពូកទី៣ ប្រវត្តិសាស្ត្រពិភពលោក និងអរិយធម៌ "បដិវត្តន៍ឧស្សាហកម្ម និងចក្រពត្តិនិយម"**

មេរៀនទី១៖ ការរីកចម្រើននៅអឺរ៉ុប និងឱនភាពនៅអាស៊ី

មេរៀនទី២៖ ការប្រជែងអំណាចនៃចក្រពត្តិនិយមនៅប្រទេសចិន

មេរៀនទី៣៖ ឥណ្ឌា និងអំណាចរបស់អង់គ្លេស

មេរៀនទី៤៖ អំណាចរបស់ជប៉ុននៅចិន និងកូរ៉េ

## ៤- របាយម៉ោងសិក្សា

| មុខវិជ្ជា ប្រវត្តិវិទ្យា | ជំពូកទី១ ប្រវត្តិសាស្ត្រកម្ពុជា | ជំពូកទី២ ប្រវត្តិសាស្ត្រតំបន់ | ជំពូកទី៣ ប្រវត្តិសាស្ត្រពិភពលោក | ម៉ោងសរុប |
|---|---|---|---|---|
| ថ្នាក់ទី៧ | ៣៥ ម៉ | ១២ ម៉ | ២៣ ម៉ | ៧០ ម៉ោង |
| ថ្នាក់ទី៨ | ៣៥ ម៉ | ២០ ម៉ | ១៥ ម៉ | ៧០ ម៉ោង |
| ថ្នាក់ទី៩ | ៣៥ ម៉ | ២០ ម៉ | ១៥ ម៉ | ៧០ ម៉ោង |

**កំណត់សម្គាល់ ៖**

១ឆ្នាំសិក្សាមាន៣៥សប្តាហ៍ = ៧០ ម៉ោង

១សប្តាហ៍ = ២ ម៉ោងសិក្សា

១ម៉ោងសិក្សា = ៥០ នាទី

## ៥- ការណែនាំអនុវត្ត

### ៥.១- វិធីសាស្ត្របង្រៀន

ការសរសេរកម្មវិធីសិក្សាប្រវត្តិវិទ្យានេះបានប្រើគោលវិធីរៀនបែបរិះរក លទ្ធផលរំពឹងទុក និងសិក្សាបញ្ញត្តិ។ គោលវិធីទាំងនេះផ្ដល់មធ្យោបាយឱ្យអ្នកសិក្សាគិតអំពីអតីតកាល និងភ្ជាប់សារប្រយោជន៍នៃអតីតកាលជាមួយនឹងជីវភាពបច្ចុប្បន្ន និងអនាគត។ ក្នុងន័យនេះ អ្នកសិក្សាប្រវត្តិវិទ្យាប្រើការឆ្ងល់ដើម្បីបង្កើតពុទ្ធិថ្មី តាមរយៈការរុករក ឬស្រាវជ្រាវ និងយករបកគំហើញពីការឆ្ងល់ទៅពន្យល់ និងវិភាគបាតុភូត និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ (ដែលមានប្រភពត្រឹមត្រូវនិងគួរឱ្យទុកចិត្ត) និងដាំបណ្ដុះការគិត វាចា ទម្លាប់ និងការប្រព្រឹត្តវិជ្ជមាន ដោយប្រើប្រវត្តិសាស្ត្រជាគោលប្រយោជន៍ដល់មនុស្សជាតិ។

គុណភាពនៃការបង្រៀន និងរៀន គឺពឹងអាស្រ័យជាធំលើវិធីសាស្ត្របង្រៀន និងសមត្ថភាពគ្រូបង្រៀន។ គោលវិធីនៃការបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាគឺគោលវិធីរៀនបែបរិះរក។ គោលវិធីរៀនបែបរិះរក គឺបង្កើត និងពង្រីកការឆ្ងល់ ការសួរ ការអាន ការសរសេរ និងការស្រាវជ្រាវ ដើម្បីបំពេញចំណុចខ្វះខាតរបស់អ្នកសិក្សា ដោយដាំបណ្ដុះ ដុសខាត់ និងពង្រីកវិជ្ជា បំណិន និងចរិយាដែលអ្នកសិក្សាមានស្រាប់ឱ្យទៅជាប្រាជ្ញាភិវឌ្ឍន៍តាមឧបនិស្ស័យ។



ប្រភព ៖ (ALAN CRAWFORD, WENDY SAUL, SAMUEL R. MATHEWS, AND JAMES MAKINSTER, 2005) Teaching and Learning Strategies for Thinking Classrooms

ការរៀន និងបង្រៀនដើម្បីឱ្យអ្នកសិក្សាបានផលទៅជាវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយា គឺប្រៀបដូចជាការដាំស្រូវដើម្បីទទួលបានផល។ ផលបានពីការរៀន គឺអ្នករៀន និងគ្រូបង្រៀនត្រូវបណ្ដុះ ដាំ ដុសខាត់ ពង្រីក និងផ្សារភ្ជាប់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ទៅនឹងប្រយោជន៍នៃជីវភាពអភិវឌ្ឍន៍ និងសន្តិភាព។ រូបខាងលើពន្យល់ថា ស្រូវមួយគ្រាប់អាចដុះជាដើមស្រូវរឹងមាំ និងមានផ្លែល្អ ត្រូវការមនុស្ស ធនធាន និងវិធីបណ្ដុះ ដាំ ថែ និងប្រមូលផល។




**ប្រភព៖** ប្រែសម្រួលពី Bloom Taxonomy (Benjamin Bloom, 1956)

## ៥.២- សេចក្តីណែនាំក្នុងការសរសេរសៀវភៅគោល

### ៥.២.១- រចនាសម្ពន្ធសៀវភៅគោល

- សៀវភៅគោលគ្រប់កម្រិតថ្នាក់ត្រូវបែងចែកជាជំពូក មេរៀន ប្រធានបទ និងឧបសម្ពន្ធដែលរួមមាន គំនូសបំព្រួញ ឬសេចក្តីសង្ខេបស្តីពីកាលប្បវត្តិ ផែនទី សន្ទានុក្រម ចំណុចគន្លឹះ សិក្ខាបញ្ញត្តិ ឯកសារយោង និងឯកសារដែលគួរអានបន្ថែម
- ក្រោយបញ្ចប់ជំពូក និងមេរៀននីមួយៗត្រូវមានលំហាត់ កិច្ចការពិភាក្សា ឬស្រាវជ្រាវ ឬសំណួរបំផុសគំនិត ដើម្បីវាយតម្លៃអំពីការសម្រេចលទ្ធផលសិក្សារំពឹងទុកតាមជំពូក ឬមេរៀន
- ក្នុងជំពូក និងមេរៀននីមួយៗ មានអត្ថបទ រូបភាព រូបគំនូរ ឬគំនូសបំព្រួញ និងសំណួរបំផុសគំនិតដែលឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុក។

### ៥.២.២- គោលការណ៍សម្រាប់ការនិពន្ធ

- ការនិពន្ធត្រូវឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុក សិក្ខាបញ្ញត្តិ និងគោលវិធីរៀនបែបរិះរកតាមប្រធានបទនីមួយៗ ដោយភ្ជាប់បុព្វហេតុ (រៀបរាប់ពីកំណរកំណើតបញ្ហាដំបូង ដល់វត្តមាននៃហេតុការណ៍) ការវិវត្ត និងផលវិបាក ដើម្បីឱ្យសិស្សបានត្រិះរិះ និងស្វែងយល់ពីមូលហេតុ និងចំណោលហេតុការណ៍អនាគត
- សំណេរមេរៀនប្រវត្តិសាស្ត្រត្រូវរួមបញ្ចូលវិជ្ជាពាក់ព័ន្ធនឹងតម្រូវការ បំណិនវិភាគ និងការត្រិះរិះពិចារណា
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ ត្រូវតែស្របគ្នា ពិត និងឥតលម្អៀង
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ ត្រូវតែមានបច្ចុប្បន្នភាព និងអាចយកទៅអនុវត្តបានសម្រាប់ការរស់នៅជាក់ស្តែង
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ត្រូវមានភាពសមស្រប សម្រាប់សិស្ស ដោយពិនិត្យមើលទៅលើវ័យ សមត្ថភាព ប្រវត្តិ សាវតារ កម្រិតនៃការអាន និងរបៀប និងទម្លាប់នៃការរៀនរបស់សិស្ស
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ត្រូវមានទំនាក់ទំនងគ្នាពីមេរៀនមួយទៅមេរៀនមួយទៀត
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ត្រូវភ្ជាប់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទៅនឹងបរិបទសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយដ៏ស្មុគស្មាញ ដែលបរិបទទាំងអស់នោះ បង្កើតជាប្រវត្តិសាស្ត្រ
- សៀវភៅប្រវត្តិវិទ្យា ត្រូវរួមបញ្ចូលទាំងរឿងរ៉ាវប្រកបដោយមោទនភាព និងរឿងរ៉ាវដែលត្រូវយកមកធ្វើជាបទពិសោធន៍ដើម្បីអាចជៀសផុតពីកំហុសច្រំដែលៗ
- ខ្លឹមសារក្នុងសៀវភៅប្រវត្តិវិទ្យា ត្រូវទ្រទ្រង់ដោយឯកសារដើមដែលមានការស្រាវជ្រាវបែបវិទ្យាសាស្ត្រ
- អ្នកសរសេរត្រូវជៀសវាងការប្រើប្រាស់ឯកសារស្រង់ពីអ៊ីនធឺណែតគ្មានឈ្មោះអ្នកនិពន្ធ ឬស្ថាប័ន
- អ្នកសរសេរត្រូវជៀសវាងការប្រើភាសាប្រមាថ ភាសារើសអើងទៅលើជាតិសាសន៍ ឬរើសអើងប្រឆាំងស្ត្រី ឬភាសាញុះញង់ដែលអាចបង្កឱ្យមានជម្លោះ ខឹងសម្បា គុំកួន និងសងសឹក
- អ្នកសរសេរត្រូវជ្រើសរើសយកផែនទី ដ្យាក្រាម គំនូរ និងរូបថត ដែលមានលក្ខណៈប្រវត្តិសាស្ត្រ និងពាក់ព័ន្ធជាមួយនឹងសំណេរមេរៀន ដើម្បីអភិវឌ្ឍគុណសម្បទារបស់អ្នកសិក្សា
- ឈ្មោះទីកន្លែងត្រូវសរសេរឱ្យបានត្រឹមត្រូវ តាមឯកសារណែនាំរបស់រាជបណ្ឌិត្យសភាកម្ពុជា
- អ្នកនិពន្ធត្រូវកំណត់គោលការណ៍សរសេរឈ្មោះមនុស្ស និងទីកន្លែងដែលគ្មានក្នុងបញ្ជីណែនាំ
- ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត រាជធានី និងក្រុងទាំងឡាយ ក្នុងប្រទេសកម្ពុជា ត្រូវយកតាមការកំណត់ចុងក្រោយបង្អស់ របស់នាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងមហាផ្ទៃ
- វចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ត្រូវបានប្រើជាមូលដ្ឋានក្នុងការសរសេរអក្សរខ្មែរ។

## ៦- ការវាយតម្លៃ

### ៦.១- សារៈការ

ការវាយតម្លៃលទ្ធផលសិក្សារំពឹងទុក (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាកំណត់ក្នុងកម្មវិធីសិក្សា) ជាដំណើរការនិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងភស្តុតាងអំពីកម្រិតនៃការទទួលវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពីដំណើរការរៀន និងបង្រៀន ទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។ ការវាយតម្លៃ គឺសំដៅរកព័ត៌មាន ឬភស្តុតាង ដើម្បីសន្និដ្ឋាន សម្រេចចិត្ត រកវិធី និងផ្តល់ធាតុចូល ជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូ និងទម្រង់នៃការគ្រប់គ្រងការអប់រំ ឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា។

### ៦.២- អត្ថវាយតម្លៃ

ការវាយតម្លៃលើលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាផ្តល់អត្ថដល់ការធានាគុណភាពអប់រំ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងគុណផលនៃការគ្រប់គ្រងរបស់ប្រព័ន្ធអប់រំដូចជា ៖

- ទទួលបានព័ត៌មានអំពីឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ
- លើកទឹកចិត្តឱ្យសិស្សប្រឹងរៀនបន្ត ដោយកែលម្អចំណុចខ្សោយ ឬចំណុចខ្វះខាត ទាក់ទងនឹងឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនរបស់សិស្ស និងបង្រៀនរបស់គ្រូ
- ទទួលបានព័ត៌មាន ឬទិន្នន័យមូលដ្ឋាន និងភស្តុតាង ឱ្យគ្រូយកទៅវាស់ស្ទង់ប្រសិទ្ធភាពនៃដំណើរការបង្រៀន និងកែលម្អឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពនៃការបង្រៀនបន្ត
- ទទួលបានព័ត៌មានដែលអាចចែករំលែកដល់មាតាបិតា និងអាណាព្យាបាល និយោជក និងសាធារណៈ អំពីស្ថានភាពនៃការសម្រេចលទ្ធផលសិក្សារបស់សិស្ស និងលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា
- ទទួលបានព័ត៌មានអំពីប្រសិទ្ធភាព និងគុណផលនៃការគ្រប់គ្រងរបស់ប្រព័ន្ធអប់រំ។

### ៦.៣- ត្រីកោណនៃការវាយតម្លៃការសិក្សា




ដើម្បីវាស់លទ្ធផលសិក្សារំពឹងទុករបស់សិស្ស ទាំងវិជ្ជា បំណិន និងចរិយា ក្នុងគ្រប់កម្រិតសិក្សា ដែលកំណត់ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ដំណើរការវាយតម្លៃនឹងត្រូវទទួលខុសត្រូវដោយគ្រប់ភាគីពាក់ព័ន្ធក្នុងប្រព័ន្ធអប់រំ ទាំងសិស្ស មាតាបិតា គណៈកម្មការទ្រទ្រង់សាលារៀន សាលារៀន

ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងភាគីពាក់ព័ន្ធនៅកម្ពុជាទាំងមូល។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវអនុវត្តតាមគោលការណ៍ត្រីកោណវាយតម្លៃ គឺការវាយតម្លៃដើម្បីការរៀនបន្ត ការវាយតម្លៃជាការរៀនបន្ត និងការវាយតម្លៃនៃការរៀនបន្ត ដូចមានបង្ហាញក្នុងរូបត្រីកោណវាយតម្លៃខាងលើ។

### ៦.៤- ការវាយតម្លៃដើម្បីការរៀនបន្ត

**ការវាយតម្លៃដើម្បីការរៀនបន្ត** ជាដំណើរការបន្តអត់ឈប់ក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងថ្នាក់ និងមានគោលបំណងលើកកម្ពស់គុណភាពនៃការរៀនរបស់សិស្សក្នុងថ្នាក់ មិនមែនគ្រាន់តែផ្តល់ភស្តុតាងសម្រាប់កំណត់វាសនាសិស្សជាប់ ឬ ធ្លាក់ ឬឱ្យតែពិន្ទុសិស្សក្នុងថ្នាក់នោះទេ។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងថ្នាក់រៀន ត្រូវរៀបចំរួមគ្នាដោយគ្រូ សិស្សឬ/និងមិត្តរួមថ្នាក់ និងជាធាតុដ៏សំខាន់មួយនៃដំណើរការលើកកម្ពស់ ឬផ្លាស់ប្តូរឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀន និងបង្រៀនក្នុងថ្នាក់ និងក្រៅថ្នាក់ ដើម្បីជួយសិស្សឱ្យទទួលបានលទ្ធផលដូចការរំពឹងទុកក្នុងកម្មវិធីសិក្សា តាមកម្រិតថ្នាក់ ជំពូក និងមេរៀន។ ការវាយតម្លៃលទ្ធផលសិក្សាដើម្បីការរៀនបន្តនេះជាទូទៅ ផ្តោតលើលទ្ធផលសិក្សាតាមមេរៀន និងតាមជំពូក ធ្វើមិនផ្លូវការ ធ្វើបន្តជាប្រចាំ និងអាចធ្វើភ្លាមៗ ដើម្បីតាមដានឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពនៃការរៀនរបស់សិស្ស និងដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការបង្រៀនរបស់គ្រូឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុកកំណត់ក្នុងកម្មវិធីសិក្សា។ គោលការណ៍នេះមានវិសាលភាព ក្នុងការ ៖

- ជួយគ្រូឱ្យចេះប្រើព័ត៌មានអំពីការចងចាំ ការយល់ សញ្ញា បំណិន និងឥរិយាបថរបស់សិស្សទទួលបានពីការរៀន និងបង្រៀន ក្នុងថ្នាក់ និងក្រៅថ្នាក់
- ជួយគ្រូឱ្យមានព័ត៌មានអំពីលទ្ធផលសិក្សារបស់សិស្ស ទៅតាមប្រភេទសិស្ស គិតទាំងសិស្សដែលមានតម្រូវការពិសេស ទាំងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា កំណត់តាមមេរៀន និងជំពូក ក្នុងសៀវភៅសិក្សាគោល
- ជួយគ្រូឱ្យស្គាល់ច្បាស់អំពីឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនរបស់សិស្ស និងប្រភេទសិស្ស ដូចជាសិស្សដែលមានតម្រូវការពិសេស
- ជួយសិស្សឱ្យកែលម្អដំណើរការ ឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនបន្ត ទាំងក្នុងថ្នាក់ និងក្រៅថ្នាក់
- ជួយគ្រូឱ្យធ្វើផែនការរយៈពេលខ្លី សម្រាប់កែលម្អឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀន និងបង្រៀនទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។

### ៦.៥- ការវាយតម្លៃជាការរៀនបន្ត

**ការវាយតម្លៃជាការរៀនបន្ត** ជាដំណើរការស្វែងយល់អំពីខ្លួនឯង និងតាមដានវឌ្ឍនភាពរបស់សិស្សដោយសិស្សក្នុងន័យស្វ័យវាយតម្លៃ និងឆ្លុះបញ្ចាំងពីការសម្រេចលទ្ធផលសិក្សា និងបង្កើតផែនការរៀនបន្តឱ្យសម្រេចលទ្ធផលសិក្សាកំណត់ក្នុងកម្មវិធីសិក្សា។

- សិស្សបានរៀនអ្វីខ្លះ ? មិនទាន់ចាំអ្វីខ្លះ មិនទាន់អាចភ្ជាប់លទ្ធផលសិក្សាទៅនឹងជីវភាពប្រចាំថ្ងៃ ?
- សិស្សអាចជួយខ្លួនឯង ជួយសិស្សគ្នាឯង និងត្រូវការជំនួយអ្វីបន្ថែម ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់ខ្លួនសម្រាប់ការរៀនបន្ត និងសម្រាប់រកទិសដៅរៀនទៅមុខទៀត ឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា
- សិស្សមាន ឬនៅខ្វះឥរិយាបថ ទម្លាប់ វិធី សកម្មភាព និងត្រូវការធាតុចូលអ្វីខ្លះដើម្បីជាជំនួយក្នុងការរៀនបន្តឱ្យទទួលបានលទ្ធផល ដូចការរំពឹងទុកក្នុងកម្មវិធីសិក្សា

លទ្ធផលទាំងនេះគឺសម្រាប់ជួយគ្រូបង្រៀន និងសិស្សក្នុងការធ្វើផែនការសិក្សាបន្តរយៈពេលខ្លី និងមធ្យមក្នុងការផ្គត់ផ្គង់ធាតុចូល និងតម្រូវការរបស់សិស្ស និងគ្រូ ក្នុងការបង្រៀន និងរៀនបន្ត ឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុកដូចមានចែងក្នុងកម្មវិធីសិក្សា។

### ៦.៦- ការវាយតម្លៃនៃការរៀន

**ការវាយតម្លៃនៃការរៀន** ជាដំណើរការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស តាមកាលកំណត់ជាក់លាក់មួយមាន ត្រីមាស ឆមាស និងប្រចាំឆ្នាំ គឺក្រោយពេលរៀន និងបង្រៀនបញ្ចប់បណ្តុំនៃលទ្ធផលសិក្សាក្នុងកម្មវិធីសិក្សាកម្រិតណាមួយ។ ការវាយតម្លៃនៃការរៀនជាការទទួលខុសត្រូវរបស់សាលារៀន ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា និងមានទិសដៅ ៖

- ផ្តល់ភស្តុតាងឱ្យគ្រូ សាលា និងប្រព័ន្ធអប់រំតាមកម្រិតនីមួយៗ វាស់លទ្ធផលសិក្សារបស់សិស្ស ធៀបនឹងលទ្ធផលសិក្សាកំណត់ក្នុងកម្មវិធីសិក្សាជាតិ
- បញ្ជូនព័ត៌មានដល់មាតាបិតា អាណាព្យាបាល និយោជក និងសាធារណៈ អំពីការសម្រេចលទ្ធផលសិក្សារំពឹងទុករបស់សិស្ស
- ផ្តល់ទិន្នន័យចាំបាច់សម្រាប់ស្ថាប័នទទួលបន្ទុកកិច្ចការអប់រំ និងក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធសម្រាប់រៀបចំផែនការរយៈពេលមធ្យម និងវែងក្នុងការកែលម្អកម្មវិធីសិក្សា និងបណ្តុះបណ្តាលគ្រូ។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី ៧

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១ : ប្រវត្តិសាស្ត្រកម្ពុជានិងអរិយធម៌** | | |
| **មេរៀនទី១ : ប្រវត្តិវិទ្យា និងការសិក្សាចងក្រង**<br>**សិក្សាបញ្ញត្តិ** : បុរាណវិទ្យា ប្រវត្តិវិទ្យា ប្រវត្តិសាស្ត្រ កាលវេលា ភស្តុតាង<br>**មាតិកា** :<br>១.១- អត្ថប្រយោជន៍នៃការអប់រំប្រវត្តិសាស្ត្រ<br>ក. អត្តសញ្ញាណជាតិ<br>ខ. ការអប់រំអន្តរវប្បធម៌<br>គ. ការអប់រំសន្តិភាព<br>**សំណួរត្រិះរិះ** :<br>• តើការសិក្សាពីប្រវត្តិសាស្ត្រផ្តល់ផលប្រយោជន៍អ្វីខ្លះ ?<br>១.២- ការងាររបស់បុរាណវិទូ<br>ក. សួរសំណួរស្តីពីអតីតកាល<br>ខ. ប្រមូលឯកសារ និងភស្តុតាង<br>គ. សិក្សាស្វែងយល់ | **វិជ្ជាសម្បទា**<br>- ពន្យល់ពីការប្រើប្រាស់កាលវិទ្យាខុសៗគ្នាក្នុងការកត់ត្រាចំណាំព្រឹត្តិការណ៍<br>- បង្ហាញពីសារៈសំខាន់នៃភស្តុតាង និងឯកសារសម្រាប់ការស្វែងយល់ពីប្រវត្តិសាស្ត្រ។<br>**បំណិនសម្បទា**<br>- ពន្យល់ពីកិច្ចការរបស់បុរាណវិទូ និងប្រវត្តិវិទូ<br>- ប្រៀបធៀបកាលដែលប្រើប្រាស់ក្នុងប្រវត្តិសាស្ត្រទៅនឹងគ្រិស្តសករាជ<br>**ចរិយាសម្បទា**<br>- វាយតម្លៃពីសារៈសំខាន់នៃប្រវត្តិវិទ្យា។<br>- តែងអត្ថបទប្រវត្តិសាស្ត្រខ្លីតាមរយៈ. ឯកសារ ឬភស្តុតាង។ | ៦ ម៉ |

| | | |
|---|---|---|
| ឃ. សន្និដ្ឋាន<br>**សំណួរត្រិះរិះ** :<br>• តើបុរាណវិទូត្រូវធ្វើអ្វីខ្លះក្នុងការចងក្រងរឿងរ៉ាវពីអតីតកាល?<br>១.៣- ការងាររបស់ប្រវត្តិវិទូ<br>ក. សួរសំណួរស្ដីពីអតីតកាល<br>ខ. ប្រមូលឯកសារ និងភស្តុតាង<br>• ឯកសារចិន<br>• សិលាចារឹក<br>• ពង្សាវតារ<br>• ទិន្នន័យដើម និងទិន្នន័យបន្ទាប់បន្សំ<br>• ផែនទី<br>គ. សិក្សាស្វែងយល់<br>ឃ. សន្និដ្ឋាន<br>**សំណួរត្រិះរិះ** :<br>• តើប្រវត្តិវិទូចងក្រងចំណេះដឹងស្ដីពីអតីតកាលដោយរបៀបណា?<br>១.៤- កាលវិទ្យា<br>ក. សករាជ<br>• ពុទ្ធសករាជ<br>• គ្រិស្តសករាជ<br>• មហាសករាជ<br>• មហាម៉ាត់សករាជ<br>• ចុល្លសករាជ<br>ខ. បំណែងចែកកាល<br>**សំណួរត្រិះរិះ** :<br>• តើបុព្វបុរសខ្មែរប្រើសករាជអ្វីខ្លះក្នុងការកត់ចំណាំព្រឹត្តិការណ៍?<br>១.៥- វិធីគណនាកាល<br>**សំណួរត្រិះរិះ** :<br>• តើត្រូវគណនាកាលប្រវត្តិសាស្ត្រធៀបនឹងគ្រិស្តសករាជដោយរបៀបណា?<br>១.៦- ចូរត្រិះរិះ<br>**សំណួរត្រិះរិះ** : | | |

| | | |
|---|---|---|
| • ចូរតែងអត្ថបទប្រវត្តិសាស្ត្រខ្លីក្នុងសម័យកាលណាមួយតាមរយៈឯកសារ ឬ ភស្តុតាង។ | | |
| **មេរៀនទី២ : បុរេប្រវត្តិ និងការផ្លាស់ប្តូរទីកន្លែងរស់នៅ**<br>**សិក្សាបញ្ញត្តិ** : បដិវត្តន៍កសិកម្ម ជំនឿ ប្រពៃណី ជីវភាពរស់នៅ ការស្លៀកពាក់ ភាសា<br>**មាតិកា** :<br>២.១- ទម្រង់សង្គមមនុស្ស<br>សំណួរត្រិះរិះ :<br>• តើមនុស្សខ្មែរសម័យបុរេប្រវត្តិសាស្ត្ររស់នៅក្នុងទម្រង់សង្គមរបៀបណា?<br>២.២- ពីចរកជន មកជានិសិទ្នជន<br>ក. ជីវភាពចរកជន<br>ខ. ជីវភាពតំបន់ភ្នំ<br>គ. ជីវភាពខ្ពង់រាប<br>ឃ. ជីវភាពវាលទំនាប<br>សំណួរត្រិះរិះ :<br>• តើជីវភាពរស់នៅរបស់មនុស្សខ្មែរក្នុងសម័យបុរេប្រវត្តិសាស្ត្រមានការវិវត្តយ៉ាងដូចម្តេចខ្លះ និងបណ្តាលមកពីមូលហេតុអ្វី?<br>២.៣- ជំនឿ<br>សំណួរត្រិះរិះ :<br>• តើប្រជាជនខ្មែរសម័យបុរេប្រវត្តិប្រតិបត្តិជំនឿអ្វីខ្លះ?<br>២.៤- ប្រពៃណី និងទំនៀមទម្លាប់<br>សំណួរត្រិះរិះ :<br>• តើប្រជាជនខ្មែរសម័យបុរេប្រវត្តិមានប្រពៃណី និងទំនៀមទម្លាប់អ្វីខ្លះដែលគួរឱ្យកត់សម្គាល់?<br>២.៥- បដិវត្តន៍កសិកម្ម<br>សំណួរត្រិះរិះ :<br>• តើកត្តាអ្វីខ្លះដែលធ្វើឱ្យមានបដិវត្តន៍ | **វិជ្ជាសម្បទា**<br>- ប្រាប់អំពីសង្គមមនុស្ស ជំនឿ និងប្រពៃណីទំនៀមទម្លាប់។<br>**បំណិនសម្បទា**<br>- ពន្យល់អំពីការផ្លាស់ប្តូររបៀបរបបរស់នៅរបស់ជនជាតិខ្មែរដើម ពីចរកជនមកជានិសិទ្នជន<br>- វិភាគពីបដិវត្តន៍កសិកម្មបុរេប្រវត្តិសាស្ត្រដោយផ្អែកលើសមុច្ច័យបុរាណវិទ្យា។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមអំពីគោលប្រយោជន៍នៃវប្បធម៌កសិកម្មក្នុងបុរេប្រវត្តិសាស្ត្រមកផ្សារភ្ជាប់ទៅនឹងទម្លាប់កសិកម្មបច្ចុប្បន្ន។ | ៧ ម៉ |

| | | |
|---|---|---|
| កសិកម្ម ?<br>• តើបដិវត្តន៍កសិកម្មមានឥទ្ធិពលអ្វីខ្លះទៅលើជីវភាពរស់នៅរបស់មនុស្ស ?<br>២.៦- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើកសិកម្មសម័យបុរេប្រវត្តិសាស្ត្រកម្ពុជាមានភាពស្រដៀង ឬភាពផ្សេងគ្នាអ្វីខ្លះនឹងកសិកម្មបច្ចុប្បន្ន ? | | |
| **មេរៀនទី៣ : ហ្វូណន និងឥទ្ធិពលឥណ្ឌា**<br>**សិក្សាបញ្ញត្តិ** : ការកត់ត្រា ការច្នៃប្រឌិត ការទទួលខុសត្រូវ មណ្ឌល សុខដុមភាព លំនៅឋាន វិជ្ជា<br>**មាតិកា** :<br>៣.១- រដ្ឋ និងការគ្រប់គ្រង<br>ក. ព្រះនាងលីវយី និងរដ្ឋខ្មែរដំបូង<br>ខ. ការគ្រប់គ្រងបែបមណ្ឌល<br>សំណួរត្រិះរិះ :<br>• តើទម្រង់នៃការគ្រប់គ្រងរដ្ឋហ្វូណនមានលក្ខណៈដូចម្ដេច ?<br>៣.២- ហ្វូណន និងវប្បធម៌រុងរឿង<br>ក. សាសនា<br>ខ. ប្រពៃណី ទំនៀមទម្លាប់<br>គ. សិល្បៈ<br>ឃ. អក្សរសិល្ប៍ និងអក្សរសាស្ត្រ<br>សំណួរត្រិះរិះ :<br>• តើភស្តុតាងបុរាណវិទ្យាអ្វីខ្លះបញ្ជាក់អំពីភាពរុងរឿងផ្នែកវប្បធម៌របស់ខ្មែរសម័យហ្វូណន ?<br>៣.៣- ហ្វូណន និងវឌ្ឍនភាពសេដ្ឋកិច្ច<br>ក. កសិកម្ម<br>ខ. សិប្បកម្ម<br>គ. ពាណិជ្ជកម្ម<br>សំណួរត្រិះរិះ :<br>• តើភស្តុតាងអ្វីខ្លះដែលបញ្ជាក់ពីភាពរីកចម្រើនផ្នែកកសិកម្ម សិប្បកម្ម និងពាណិជ្ជកម្មក្នុងសម័យហ្វូណន ? | **វិជ្ជាសម្បទា**<br>- ប្រាប់អំពីស្ថានភាពប្រជាជន និងសង្គមក្នុងសម័យកាលហ្វូណន<br>- ប្រាប់អំពីវប្បធម៌ និងការជឿនលឿនផ្នែកអក្សរ និងការរៀនសូត្ររបស់ខ្មែរសម័យកាលហ្វូណន<br>- រៀបរាប់អំពីបម្រែបម្រួល និងភាពរុងរឿងផ្នែកកសិកម្ម សិប្បកម្ម និងពាណិជ្ជកម្ម<br>- បង្ហាញពីតួនាទីស្ត្រីក្នុងការអភិវឌ្ឍនគរហ្វូណន។<br>**បំណិនសម្បទា**<br>- វិភាគអំពីភាពស្រដៀងគ្នា និងភាពដោយឡែកនៃរបៀបរបបរស់នៅរបស់ប្រជាជនខ្មែរសម័យហ្វូណន ទៅនឹងបច្ចុប្បន្ន។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍការគិត វាចា ទម្លាប់ និងទង្វើក្នុងការថែរក្សាមរតកប្រវត្តិសាស្ត្រ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ | ៧ ម៉ |

| | | |
|---|---|---|
| ៣.៤- ជីវភាពរស់នៅ<br>សំណួរត្រិះរិះ :<br>• តើប្រជាជនខ្មែរក្នុងសម័យកាលហ្វូណនរស់នៅដូចម្ដេច និងប្រកបរបរអ្វីចិញ្ចឹមជីវិត ?<br>៣.៥- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើកូនខ្មែរត្រូវធ្វើអ្វីខ្លះក្នុងការចូលរួមថែរក្សាមរតកប្រវត្តិសាស្ត្រដែលបន្សល់ទុកពីសម័យហ្វូណន ?<br>• ក្នុងនាមជាពលរដ្ឋសកលម្នាក់ តើអ្នកគួរដាំបណ្ដុះការគិត វាចា ទម្លាប់ និងទង្វើអ្វីខ្លះក្នុងការចូលរួមថែរក្សាមរតកប្រវត្តិសាស្ត្រ ? | | |
| **មេរៀនទី៤ :** **ចេនឡា និងសុខដុមភាព**<br>**សិក្សាបញ្ញត្តិ** : វិជ្ជា ការច្នៃប្រឌិត ការទទួលខុសត្រូវ សុខដុមភាព<br>**មាតិកា** :<br>៤.១- រដ្ឋ និងការគ្រប់គ្រង<br>ក. ទម្រង់គ្រប់គ្រង និងឥទ្ធិពល<br>ខ. រាជ្យព្រះនាងជ័យទេវី និងការរួបរួមជាតិ<br>សំណួរត្រិះរិះ :<br>• តើការគ្រប់គ្រងរដ្ឋសម័យចេនឡាមានទម្រង់បែបណា និងមានចំណុចខ្លាំង និងចំណុចខ្សោយអ្វីខ្លះ ?<br>៤.២- ចេនឡាទឹក និងចេនឡាគោក<br>ក. កត្តាភូមិសាស្ត្រ និងភាពខុសគ្នា<br>ខ. ប្រភពសិលាចារឹក និងឯកសារចិន<br>សំណួរត្រិះរិះ :<br>• តើនគរចេនឡាបែកបាក់ជាពីរឬយ៉ាងណា ?<br>៤.៣- សុខដុមនីយកម្ម និងការរីកចម្រើន<br>ក. សាសនា<br>ខ. ប្រពៃណី<br>គ. ទំនៀមទម្លាប់<br>សំណួរត្រិះរិះ :<br>• តើមានភស្តុតាងអ្វីខ្លះបញ្ជាក់អំពី | **វិជ្ជាសម្បទា**<br>- ប្រាប់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃទម្រង់គ្រប់គ្រងរដ្ឋក្នុងសម័យកាលចេនឡា<br>- ពន្យល់អំពីការលេចឡើងនូវចេនឡាទឹក និងចេនឡាគោក។<br>**បំណិនសម្បទា**<br>- វិភាគអំពីសុខដុមភាពខាងទឹកដី ជំនឿ និងប្រពៃណី និងភាពរីកចម្រើននៃការអប់រំ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមអំពីសមត្ថភាពច្នៃប្រឌិត និងបង្កើតថ្មីរបស់ប្រជាជនខ្មែរសម័យកាលចេនឡា ក្នុងផ្នែកសិល្បៈ សិប្បកម្ម កសិកម្ម ស្ថាបត្យកម្ម និងវិទ្យាសាស្ត្រ។ | ៧ ម៉ |

| | | |
|---|---|---|
| សុខដុមនីយកម្មក្នុងការប្រតិបត្តិសាសនា ជំនឿ និងប្រពៃណីរបស់ខ្មែរសម័យចេនឡា?<br>៤.៤- ការអប់រំ និងគំនិតច្នៃប្រឌិត<br>ក. អក្សរសិល្ប៍ និងអក្សរសាស្ត្រ<br>ខ. សិល្បៈ និងការកសាងប្រាសាទ<br>គ. ប្រាសាទសំបូរព្រៃគុក<br>ឃ. កសិកម្ម និងសិប្បកម្ម<br>សំណួរត្រិះរិះ :<br>• តើការអប់រំមានទំនាក់ទំនងយ៉ាងដូចម្ដេចខ្លះចំពោះការរីកចម្រើនក្នុងសម័យចេនឡា?<br>៤.៥- ប្រជាជន និងជីវភាពរស់នៅ<br>សំណួរត្រិះរិះ :<br>• តើមានភស្តុតាងអ្វីខ្លះបញ្ជាក់អំពីទម្រង់លំនៅឋាន និងជីវភាពរស់នៅរបស់ប្រជាជនខ្មែរក្នុងសម័យចេនឡា?<br>៤.៦- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើភស្តុតាងអ្វីខ្លះដែលបញ្ជាក់ពីគំនិតច្នៃប្រឌិត និងបង្កើតថ្មីរបស់ប្រជាជនខ្មែរក្នុងសម័យចេនឡា?<br>• ចូរបង្កើតវត្ថុ ឬសកម្មភាពអ្វីមួយប្រកបដោយគំនិតច្នៃប្រឌិត ដែលមានលក្ខណៈជាខ្មែរ។ | | |
| **មេរៀនទី៥ : អង្គរ និងអរិយធម៌ខ្ពង់ខ្ពស់**<br>**សិក្សាបញ្ញត្តិ** : អរិយធម៌រុងរឿង សិល្បៈដឹកនាំ ទម្រង់គ្រប់គ្រងរដ្ឋ មណ្ឌល សុខដុមនីយកម្ម ប្រាសាទ ស្នាដៃ និរន្តរភាព យោគយល់ អត់ឱន កត្តញ្ញូ សមាហរណកម្ម<br>**មាតិកា** :<br>៥.១- ការកសាងអរិយធម៌អង្គរ<br>ក. ការគ្រប់គ្រងរដ្ឋ និងលទ្ធិទេវរាជ<br>ខ. ការគ្រប់គ្រងអំណាច និងសាសនា | **វិជ្ជាសម្បទា**<br>- ពន្យល់ពីកត្តាដែលធ្វើឱ្យចក្រភពអង្គរមានអរិយធម៌រុងរឿង<br>- បង្ហាញពីកត្តាដែលធ្វើឱ្យចក្រភពអង្គររក្សាភាពរុងរឿងពីសតវត្សរ៍ទី៩ ដល់ទី១៥។<br>**បំណិនសម្បទា**<br>- ចង្អុលបង្ហាញពីសម្មតិកម្មដែលបញ្ជាក់ថាចក្រភពអង្គរមានអរិយធម៌រុងរឿង<br>- វិភាគពីកត្តាដែលធ្វើឱ្យចក្រភពអង្គរមិនអាច | ៨ ម៉ |

| | | |
|---|---|---|
| គ. ការបង្រួបបង្រួមជាតិ និងការផ្តល់ឋាននន្តរសក្តិ<br>ឃ. ការរក្សាសន្តិភាព និងស្ថិរភាព<br>សំណួរត្រិះរិះ :<br>• តើព្រះបាទជ័យវរ្ម័នទី២មានយុទ្ធសាស្ត្រ និងសិល្បៈអ្វីខ្លះក្នុងការដឹកនាំ និងកសាងចក្រភពអង្គរ?<br>៥.២- ការរក្សានិរន្តរភាពអង្គរ<br>ក. វិសាលភាពទឹកដី<br>ខ. សុខដុមភាពសាសនា<br>គ. វប្បធម៌កត្តញ្ញូ<br>ឃ.ការកសាងប្រាសាទ និងហេដ្ឋារចនាសម្ពន្ធ<br>ង. ការបន្តកសាងស្នាដៃ<br>ច. សារៈសំខាន់នៃការបន្តនិរន្តរភាព របស់បុព្វបុរស<br>ឆ. ព្រះបាទជ័យវរ្ម័នទី៧ និងសមាហរណកម្មសាសនា<br>ជ. តួនាទី និងការចូលរួមរបស់ពលរដ្ឋខ្មែរ<br>ឈ. យោធាខ្មែរនៅសម័យអង្គរ<br>សំណួរត្រិះរិះ :<br>• តើចក្រភពអង្គរអាចបន្ត និងរក្សាបាននូវការរីកចម្រើនពីសតវត្សរ៍៩ ដល់ទី១៥ យ៉ាងដូចម្តេច?<br>៥.៣- អរិយធម៌អង្គរ<br>ក. ភាសា<br>ខ. អក្សរ និងសិលាចារឹក<br>គ. វិទ្យាសាស្ត្រ និងស្ថាបត្យកម្ម<br>ឃ. សិល្បៈ ល្បែង<br>ង. ជំនឿ និងសាសនា<br>ច. ប្រពៃណី ទំនៀមទម្លាប់<br>ឆ. ច្បាប់<br>ជ. ការអប់រំ (សាកលវិទ្យាល័យដំបូងក្នុងតំបន់)<br>ឈ. ផលផលិត (កសិកម្ម សិប្បកម្ម) និង | រក្សាបាននូវវឌ្ឍនភាពក្នុងដំណាក់កាលចុងក្រោយ។<br>**ចរិយាសម្បទា**<br>- ស្ងើ និងការពារគម្រោងក្នុងការចូលរួមអភិវឌ្ឍកម្ពុជាក្នុងសតវត្សរ៍ទី២១។ | |

| | | |
|---|---|---|
| ពាណិជ្ជកម្ម<br>សំណួរត្រិះរិះ :<br>• តើអ្វីខ្លះជាសម្មតិកម្មនៃអរិយធម៌រុងរឿងរបស់ខ្មែរ?<br>៥.៤- ឱនភាពនៃការរីកចម្រើន?<br>ក. ជ័យវរ្ម័នទី៤ និងកោះកេរ<br>ខ. ជ័យវរ្ម័នទី៨ និងការបែកខ្ញែក<br>គ. ពុទ្ធសាសនា និងអវត្តមានសំណង់ប្រសាទ<br>ឃ. ប្រព័ន្ធធារាសាស្ត្រ និងផលិតផលកសិកម្ម<br>សំណួរត្រិះរិះ :<br>• តើមានបម្រែបម្រួលអ្វីខ្លះដែលធ្វើឱ្យប្រវត្តិវិទូមួយចំនួនសន្និដ្ឋានថាអរិយធម៌អង្គរចាប់ផ្ដើមមានឱនភាពចាប់ពីសតវត្សរ៍ទី១៥?<br>៥.៥- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើប្អូនផ្ទាល់អាចចូលរួមយ៉ាងដូចម្ដេចខ្លះដើម្បីបន្តការរីកចម្រើនរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងសតវត្សរ៍ទី២១? | | |
| **ជំពូកទី២ : ប្រវត្តិសាស្ត្រតំបន់"យុគ និងការវិវត្ត"** | | |
| **មេរៀនទី១: បុរេប្រវត្តិសាស្ត្រ (៦៨០ ០០០ឆ្នាំ-១០០ ឆ្នាំមុន គ.ស.)**<br>**សិក្សាបញ្ញត្តិ** : យុគថ្មបំបែក យុគថ្មរំលីង យុគសំរឹទ្ធ ភាសា សញ្ញាឧបករណ៍ បច្ចេកវិទ្យា ជំនឿ សីលធម៌ ការរស់នៅ សិល្បៈ កសិកម្ម<br>**មាតិកា** :<br>**១.១- ឧបករណ៍ និងជីវភាពរស់នៅ**<br>ក. អរិយធម៌ខ្មែរ<br>ខ. អរិយធម៌មន<br>គ. អរិយធម៌ចាម្ប៉ា<br>ឃ.អរិយធម៌ជ្វា<br>**សំណួរត្រិះរិះ** :<br>• តើមនុស្សក្នុងអរិយធម៌បុរាណបានបង្កើត | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឧបករណ៍ប្រើប្រាស់ និងជីវភាពរស់នៅរបស់មនុស្ស ក្នុងយុគថ្មបំបែក យុគថ្មរំលីង និងយុគសំរឹទ្ធនៅអាស៊ីអាគ្នេយ៍បុរាណ<br>- ប្រាប់ពីវត្ថុសិល្បៈបែបសូនរូបនិងគំនូរដែលបានបន្សល់ទុកពីបុរេប្រវត្តិសាស្ត្រតាមអរិយធម៌បុរាណនៅអាស៊ីអាគ្នេយ៍<br>- ប្រាប់ពីការប្រើប្រាស់សញ្ញា និងភាសាសម្រាប់ទំនាក់ទំនងមនុស្ស នៅអាស៊ីអាគ្នេយ៍បុរាណ។<br>**បំណិនសម្បទា**<br>- វិភាគពីការវិវត្តផ្នែកកសិកម្ម និងបច្ចេកវិទ្យា | ៦ ម៉ |

| | | |
|---|---|---|
| ឧបករណ៍អ្វីខ្លះសម្រាប់ជីវភាពប្រចាំថ្ងៃ ?<br>**១.២- វត្ថុសិល្បៈ និងគំនូរ**<br>ក. សូនរូប<br>ខ. គំនូរ<br>គ. ស្នាដៃសិល្បៈ<br>**សំណួរត្រិះរិះ** :<br>• តើស្ធូនវត្ថុ គំនូរ និងស្នាដៃសិល្បៈបន្សល់ទុកតាមអរិយធម៌អាស៊ីអាគ្នេយ៍បុរាណ ផ្តល់ផលប្រយោជន៍អ្វីខ្លះដល់បច្ចុប្បន្ន ?<br>**១.៣- សញ្ញា និងភាសា**<br>ក. សញ្ញាទំនាក់ទំនងមនុស្ស<br>ខ. ភាសា<br>**សំណួរត្រិះរិះ** :<br>• តើមនុស្សក្នុងអរិយធម៌បុរាណបានប្រើសញ្ញា និងភាសាបែបណាខ្លះដើម្បីបង្កើតទំនាក់ទំនង ?<br>**១.៤- កសិកម្ម និងបច្ចេកវិទ្យា**<br>ក. បច្ចេកវិទ្យា និងការដាំដុះ<br>ខ. ការប្រមាញ់ និងផ្សាំងសត្វ<br>គ. ការច្នៃប្រឌិត និងការផ្លាស់ទីកន្លែង<br>**សំណួរត្រិះរិះ** :<br>• តើមនុស្សក្នុងអរិយធម៌បុរាណបានបង្កើតវិធីធ្វើកសិកម្ម និងបច្ចេកវិទ្យាសម្រាប់ប្រកបរបរចិញ្ចឹមជីវិតដោយរបៀបណា ?<br>• តើហេតុអ្វីបានជាមនុស្សក្នុងអរិយធម៌បុរាណ បានច្នៃប្រឌិតឧបករណ៍កសិកម្ម និងបច្ចេកវិទ្យាសម្រាប់ជីវភាពប្រចាំថ្ងៃ ?<br>**១.៥- សីលធម៌ និងជំនឿ**<br>ក. សីលធម៌ និងមនុស្ស<br>ខ. ជំនឿ និងការប្រតិបត្តិ<br>**សំណួរត្រិះរិះ** :<br>• តើការប្រតិបត្តិសីលធម៌ និងជំនឿផ្តល់ | សម្រាប់ជីវភាពប្រចាំថ្ងៃ ក្នុងអរិយធម៌អាស៊ីអាគ្នេយ៍បុរាណ។<br>**ចរិយាសម្បទា**<br>- វាយតម្លៃពីគោលការណ៍សីលធម៌ និងជំនឿរបស់អរិយធម៌អាស៊ីអាគ្នេយ៍បុរាណដែលបានប្រតិបត្តិដល់បច្ចុប្បន្ន។ | |

| | | |
|---|---|---|
| ប្រយោជន៍អ្វីខ្លះដល់មនុស្សគ្រប់ជំនាន់ ? | | |
| **មេរៀនទី២** : **រដ្ឋដំបូងៗ** ( **ស.វ.ទី១-ស.វ.ទី៨** )<br>**សិក្សាបញ្ញត្តិ** : ភូមិសាស្ត្រ ការតាំងលំនៅ ធារាសាស្ត្រ កសិកម្ម ជំនឿ ការអប់រំ ពាណិជ្ជកម្ម ឥណ្ឌា ចិន ព្រះពុទ្ធសាសនា<br>**មាតិកា** :<br>**២.១- ការតាំងលំនៅ និងកសិកម្ម**<br>ក. តំបន់ដីគោក និងការដាំដុះ<br>ខ. ទឹក និងដំណាំស្រូវ<br>គ. ដងទន្លេ និងប្រជាជន<br>**សំណួរត្រិះរិះ** :<br>• តើប្រជាជនតាំងលំនៅ និងប្រកបរបរចិញ្ចឹមជីវិតដោយរបៀបណា ?<br>**២.២- ជំនឿ និងការអប់រំ**<br>ក. សាសនា និងការរួបរួម<br>ខ. អក្សរ និងភាសា<br>គ. ប្រាសាទ និងបច្ចេកវិទ្យា<br>**សំណួរត្រិះរិះ** :<br>• តើជំនឿ សាសនា និងការអប់រំទទួលឥទ្ធិពលមកពីប្រភពណា និងដោយរបៀបណា ?<br>• ហេតុអ្វីបានជាប្រជាជាតិនៃរដ្ឋមួយអាចទទួលយកជំនឿ ឬសាសនាពីប្រភពផ្សេងៗ ?<br>**២.៣- ពាណិជ្ជកម្ម និងអន្តរទំនាក់ទំនង**<br>ក. ឆ្នេរសមុទ្រ និងពាណិជ្ជកម្ម<br>ខ. ចិន និងជំនួញ<br>**សំណួរត្រិះរិះ** :<br>• តើការរស់នៅតាមឆ្នេរសមុទ្រនិងដងទន្លេផ្ដល់ប្រយោជន៍អ្វីខ្លះដល់ជីវភាពរបស់ប្រជាជន ?<br>• ហេតុអ្វីបានជាប្រជាជននៃរដ្ឋនានាត្រូវបង្កើតទំនាក់ទំនងល្អជាមួយគ្នា ? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបតាំងលំនៅ និងរាជធានីនៃរដ្ឋដំបូងៗរបស់អាស៊ីអាគ្នេយ៍<br>- ពន្យល់ពីនយោបាយទឹក និងវិធីធ្វើកសិកម្ម<br>- រៀបរាប់ពីរបៀបនៃការផ្សព្វផ្សាយព្រះពុទ្ធសាសនា នៅអាស៊ីអាគ្នេយ៍។<br>**បំណិនសម្បទា**<br>- វិភាគពីតួនាទីនៃជំនឿ និងការអប់រំក្នុងការអភិវឌ្ឍសង្គម<br>- វិភាគពីឥទ្ធិពលឥណ្ឌា និងចិន លើបម្រែបម្រួលសង្គមរបស់អាស៊ីអាគ្នេយ៍<br>- ភ្ជាប់សារប្រយោជន៍នៃស្ថាបត្យកម្មសម្រាប់មនុស្សជំនាន់ក្រោយ<br>- វិនិច្ឆ័យពីទំនាក់ទំនង រវាងរដ្ឋនានានៅអាស៊ីអាគ្នេយ៍ និងបរទេស ក្នុងគោលបំណងពាណិជ្ជកម្ម។<br><br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីភាពរួមនៃដំណាំស្រូវ និងគ្រឿងទេសនៅអាស៊ីអាគ្នេយ៍។ | ៦ ម៉ |

| ជំពូកទី៣ : ប្រវត្តិសាស្ត្រពិភពលោក និងអរិយធម៌ | | |
|---|---|---|
| **មេរៀនទី១ : បុរេប្រវត្តិសាស្ត្រ និងកំណើតអរិយធម៌ពិភពលោក**<br>**សិក្សាបញ្ញត្តិ** : មនុស្ស ភស្តុតាង យុគ ការរស់នៅ ការច្នៃប្រឌិត ជំនឿ ផែនដី<br>**មាតិកា** :<br>**១.១- មនុស្ស និងផែនដី**<br>ក. តំបន់រស់នៅ និងបរិស្ថានភូមិសាស្ត្រ<br>ខ. ការវិវត្ត និងគំនិតច្នៃប្រឌិត<br>**សំណួរត្រិះរិះ** :<br>• តើបុរាណវិទូពន្យល់ពីសកម្មភាពរបស់មនុស្ស និងព្រឹត្តិការណ៍ក្នុងបុរេប្រវត្តិសាស្ត្រដោយរបៀបណា?<br>**១.២- ការច្នៃប្រឌិតតាមយុគ**<br>ក. យុគថ្មបំបែក<br>ខ. យុគថ្មរំលីង<br>គ. យុគលោហៈ<br>**សំណួរត្រិះរិះ** :<br>• តើឧបករណ៍ប្រើចិញ្ចឹមជីវិត និងសម្ភារសិល្បៈដែលមនុស្សបុរេប្រវត្តិសាស្ត្របានច្នៃប្រឌិត ក្នុងយុគនីមួយៗមានសារៈសំខាន់យ៉ាងដូចម្ដេចខ្លះ?<br>**១.៣- ជំនឿ និងតំបន់ក្នុងពិភពលោក**<br>ក. សាសនា និងអាស៊ី<br>ខ. សាសនា និងអឺរ៉ុប<br>គ. សាសនា និងអាហ្វ្រិក<br>ឃ.សាសនា និងអាមេរិក<br>**សំណួរត្រិះរិះ** :<br>• តើតាមតំបន់នីមួយៗ មនុស្សភាគច្រើនគោរពនិងប្រតិបត្តិសាសនាអ្វី?<br>• តើក្រុមមនុស្សគោរពសាសនាផ្សេងៗគ្នាមានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្ដេច?<br>**១.៤- វប្បធម៌ និងមនុស្ស** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការកកើតមនុស្សលើផែនដី ការរស់នៅ និងការវិវត្តនៃមនុស្សក្នុងសម័យបុរេប្រវត្តិសាស្ត្រ<br>- ពន្យល់ពីសារសំខាន់ នៃការច្នៃប្រឌិតរបស់មនុស្សតាមយុគថ្មបំបែក យុគថ្មរំលីង និងយុគលោហៈ ។<br><br>**បំណិនសម្បទា**<br>- សង្ខេបពីការគោរពសាសនាតាមតំបន់ នៃពិភពលោកក្នុងសម័យបុរេប្រវត្តិសាស្ត្រ ។<br>**ចរិយាសម្បទា**<br>- វាយតម្លៃពីអរិយធម៌បុរាណរបស់មនុស្សក្នុងសម័យបុរេប្រវត្តិសាស្ត្រ ។ | ៣ ម៉ |

| | | |
|---|---|---|
| ក. ការរស់នៅ និងរបបចិញ្ចឹមជីវិត<br>ខ. តម្រូវការ និងការច្នៃប្រឌិត<br>គ. សង្គម និងការវិវត្ត<br>**សំណួរត្រិះរិះ** :<br>• តើវប្បធម៌នៃសង្គមមនុស្ស ក្នុងបុរេប្រវត្តិសាស្ត្រ មានការវិវត្តយ៉ាងដូចម្តេចខ្លះ ? | | |
| **មេរៀនទី២ : អេហ្ស៊ីបបុរាណ និងអរិយធម៌**<br>**សិក្សាបញ្ញត្តិ**: ភូមិសាស្ត្រ អក្សរ សិល្បៈ អក្សរសិល្ប៍ សង្គម ស្ថាបត្យកម្ម ជំនឿ សាសនា ពីរ៉ាមីត មាំមី<br>**មាតិកា** :<br>**២.១- កំណើតប្រទេសអេហ្ស៊ីប**<br>ក. ភូមិសាស្ត្រ និងប្រជាជន<br>ខ. សង្គម និងសិទ្ធិស្ត្រី<br>**សំណួរត្រិះរិះ** :<br>• ហេតុអ្វីបានជាទន្លេនីល និងភូមិសាស្ត្ររបស់អេហ្ស៊ីបជាអំណោយដល់ប្រជាជនអេហ្ស៊ីប ?<br>• តើសង្គមអេហ្ស៊ីបបែងចែកវណ្ណៈយ៉ាងដូចម្តេចខ្លះ និងផ្តល់ឋានៈក្នុងសង្គមដល់ស្ត្រីយ៉ាងដូចម្តេចខ្លះ និងស្ត្រីមានសិទ្ធិអ្វីខ្លះ ?<br>**២.២- ការវិវត្ត និងអរិយធម៌អេហ្ស៊ីបបុរាណ**<br>ក. ការរៀនសូត្រ និងយុវជន<br>ខ. សិល្បៈ និងអក្សរសិល្ប៍<br>គ. ស្ថាបត្យកម្ម និងវិទ្យាសាស្ត្រ<br>**សំណួរត្រិះរិះ** :<br>• តើមានភស្តុតាងអ្វីបញ្ជាក់ពីភាពជឿនលឿនផ្នែកអក្សរ សិល្បៈ អក្សរសិល្ប៍ គណិតវិទ្យា ស្ថាបត្យកម្ម និងវិទ្យាសាស្ត្ររបស់អេហ្ស៊ីបបុរាណ ?<br>• តើប្រជាជាតិអេហ្ស៊ីបបានបន្សល់មរតកអ្វីខ្លះសម្រាប់ពិភពលោកមកដល់បច្ចុប្បន្ន ?<br>**២.៣- មរតកនៃអរិយធម៌អេហ្ស៊ីប**<br>ក. សាសនា និងការរស់នៅ<br>ខ. ជំនឿ និងជីវិតជាតិក្រោយ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលដីសណ្ត និងទន្លេនីល ដល់ការកកើតអេហ្ស៊ីបបុរាណ<br>- រៀបរាប់ពីរបៀបដែលអេហ្ស៊ីបបុរាណរៀបចំសង្គម និងសិទ្ធិស្ត្រីក្នុងការងារ ។<br>**បំណិនសម្បទា**<br>- ភ្ជាប់ភាពជឿនលឿនលើការរៀនសូត្រ សិល្បៈ និងអក្សរសិល្ប៍របស់អេហ្ស៊ីបបុរាណសម្រាប់ជីវភាពរស់នៅរបស់មនុស្សជំនាន់ក្រោយ<br>**ចរិយាសម្បទា**<br>- វាយតម្លៃពីឥទ្ធពលនៃជំនឿ និងសាសនាទៅលើជីវភាពប្រជាជនអេហ្ស៊ីបបុរាណ ។<br>- សន្និដ្ឋានរួមពីតម្លៃនៃស្ថាបត្យកម្ម និងវិទ្យាសាស្ត្ររបស់អេហ្ស៊ីបបុរាណ។ | ៣ ម៉ |

| | | |
|---|---|---|
| **សំណួរត្រិះរិះ** :<br>• តើការប្រតិបត្តិសាសនា និងជំនឿលើជីវិតជាតិក្រោយរបស់ប្រជាជនអេហ្ស៊ីប មានលក្ខណៈ រួមនិងដោយឡែកពីកម្ពុជាអ្វីខ្លះ ? | | |
| **មេរៀនទី៣ : ពិភពក្រិក និងលទ្ធិប្រជាធិបតេយ្យ**<br>**សិក្សាបញ្ញត្តិ** : មីន័រ ក្រុងទ្រ័រ ស្ប៉ាក អាតែន ច្បាប់ អរិយធម៌ នយោបាយ ប្រជាធិបតេយ្យ អំណាច វិទ្យាសាស្ត្រ គណិតវិទ្យា ទស្សនវិជ្ជា តារាសាស្ត្រ<br>**៣.១- ដើមកំណើតក្រិក និងភូមិសាស្ត្រ**<br>ក. មីន័រ និងភាពរុងរឿង<br>ខ. ពាណិជ្ជកម្ម និងទំនាក់ទំនងសង្គម<br>**សំណួរត្រិះរិះ** :<br>• តើមីន័រជាអ្វី និងមានទីតាំងភូមិសាស្ត្រនៅកន្លែងណានៃប្រទេសក្រិកបច្ចុប្បន្ន ?<br>• តើទំនាក់ទំនងពាណិជ្ជកម្មរវាងមីន័រ និងសង្គមខាងក្រៅកើតឡើងដោយរបៀបណា ?<br>**៣.២- រដ្ឋបុរី និងការគ្រប់គ្រង**<br>ក. រដ្ឋបុរីស្ប៉ាក និងយោធា<br>ខ. រដ្ឋបុរីអាតែន និងប្រជាធិបតេយ្យ<br>គ. ភាពខុសគ្នារវាង អាតែន និងស្ប៉ាក<br>**សំណួរត្រិះរិះ** :<br>• តើរដ្ឋបុរីសំខាន់ៗរបស់ក្រិកបុរាណ មានអ្វីខ្លះ និងបន្សល់ទុកអ្វីខ្លះ ?<br>• តើអរិយធម៌ក្រិកមានឥទ្ធិពលមកពីណា ?<br>• តើហេតុអ្វីបានជាអរិយធម៌ក្រិកមានភាពរុងរឿងខ្លាំង ?<br>• តើអាតែន និងស្ប៉ាកមានគោលការណ៍គ្រប់គ្រងរដ្ឋខុសគ្នា និងដូចគ្នាអ្វីខ្លះ ?<br>**៣.៣- ពិភពក្រិក និងជម្លោះ**<br>ក. សង្គ្រាមពែរ្ស<br>ខ. សង្គ្រាមប៉េឡូប៉ូណែរ<br>គ. សង្គ្រាមក្រុងទ្រ័រ<br>**សំណួរត្រិះរិះ** : | **វិជ្ជាសម្បទា**<br>- ប្រាប់ពីមីន័រ និងភូមិសាស្ត្រ មុនកកើតចក្រភពក្រិក<br>- ប្រាប់ពីបុព្វហេតុនាំឱ្យអរិយធម៌មីន័ររុងរឿង<br>- រៀបរាប់ពីរដ្ឋបុរីសំខាន់ៗ ភាពរុងរឿង និងប្រភេទ និងទម្រង់នៃការគ្រប់គ្រងរដ្ឋបុរីក្នុងពិភពក្រិក<br>- រៀបរាប់ពីភាពគួរឱ្យស្ញប់ស្ញែងនៃ ប្រជាជនអាតែន។<br>**បំណិនសម្បទា**<br>- វិភាគពីដើមហេតុ និងផលប៉ះពាល់នៃជម្លោះក្នុងពិភពក្រិក<br>- ភ្ជាប់មរតករបស់អាឡិចហ្សង់មហារាជសម្រាប់ការប្រើប្រាស់ក្នុងសង្គមមនុស្សបច្ចុប្បន្ន។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីតម្លៃ នៃសេចក្តីស្រលាញ់ចំពោះចំណេះដឹង សម្រាប់ភាពរុងរឿងរបស់សង្គមមនុស្ស។ | ៣ ម៉ |

| | | |
|---|---|---|
| • តើជម្លោះក្នុងពិភពក្រិកផ្ដល់វិបាកអ្វីខ្លះ ?<br>• តើបំណិនចម្បងៗសម្រាប់យុវជនក្រិកត្រូវផ្ដោតលើអ្វីខ្លះ ?<br>**៣.៤- អាទ្បិចហ្សង់មហារាជ**<br>ក. ប៉ែរីក្លាក និងច្បាប់<br>ខ. វិទ្យាសាស្ត្រ និងសិល្បៈ<br>**សំណួរត្រិះរិះ** :<br>• តើស្នាព្រះហស្តរបស់អាទ្បិចហ្សង់មហារាជត្រូវបានប្រើជាប្រយោជន៍ដល់មនុស្សជំនាន់ក្រោយយ៉ាងដូចម្ដេចខ្លះ ? | | |
| **មេរៀនទី៤** : **ចក្រភពរ៉ូម និងសាធារណរដ្ឋ**<br>**សិក្សាបញ្ញត្តិ** : សង្គមរ៉ូម អរិយធម៌ រដ្ឋអំណាច អំណាច សាធារណរដ្ឋ សិល្បៈ វិស្វកម្ម អក្សរសាស្ត្រ វិទ្យាសាស្ត្រ ទស្សនវិជ្ជា សាសនា ឱនភាព<br>**មាតិកា** :<br>**៤.១- ដើមកំណើតរ៉ូម និងភូមិសាស្ត្រ**<br>ក. អ៊ីតាលី និងប្រជាជន<br>ខ. សង្គម និងវប្បធម៌<br>គ. តួនាទីស្ត្រី និងសិទ្ធិមនុស្ស<br>**សំណួរត្រិះរិះ** :<br>• តើជនជាតិអ៊ីតាលីដែលបានមកតាំងលំនៅដំបូងបានបង្កើតចក្រភពរ៉ូមយ៉ាងដូចម្ដេច ?<br>• ហេតុអ្វីបានជាប្រជាជនរ៉ូម ប្រឹងពង្រីកការអប់រំដល់កុមារយ៉ាងខ្លាំង ?<br>• តើការលើកតម្លៃស្ត្រី និងសិទ្ធិមនុស្សធ្វើឱ្យសង្គមរ៉ូមមានការប្រែប្រួលយ៉ាងដូចម្ដេច ?<br>**៤.២- សាធារណរដ្ឋរ៉ូម និងការពង្រីកអំណាច**<br>ក. អំណាច និងអភិបាលកិច្ច<br>ខ. កងទ័ពរ៉ូម និងសញ្ជ័យ<br>គ. សាធារណរដ្ឋ និងចក្រភពរ៉ូម<br>**សំណួរត្រិះរិះ** :<br>• អរិយធម៌រុងរឿងរបស់រ៉ូម កើតឡើងដោយសារកត្តារួបផ្សំអ្វីខ្លះ ?<br>• តើកត្តាអ្វីជំរុញឱ្យសាធារណរដ្ឋរ៉ូមខ្លាំង និង | **វិជ្ជាសម្បទា**<br>- ប្រាប់ពីកំណើតក្រុងរ៉ូម និងប្រជាជន<br>- ប្រាប់ពីធាតុចម្បងៗដែលបង្កើតបានសង្គមរ៉ូមខ្លាំងពូកែ ពីតួនាទី និងសិទ្ធិស្ត្រី និងការប្រតិបត្តិសាសនា<br>- រៀបរាប់ពីកត្តានាំឱ្យសាធារណរដ្ឋរ៉ូមខ្លាំង។<br>**បំណិនសម្បទា**<br>- វិភាគពីរបៀបពង្រីកអំណាច និងការផ្លាស់ប្ដូររបបគ្រប់គ្រងពីសាធារណរដ្ឋ ទៅជាចក្រភពរ៉ូម<br>- វិភាគពីមូលហេតុនៃការធ្លាក់ចុះ និងការដួលរលំនៃចក្រភពរ៉ូម ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីសារៈសំខាន់នៃកេរដំណែលរ៉ូម ដូចជា សាសនា ស្ថាបត្យកម្ម វិស្វកម្ម ច្បាប់ និងទម្រង់រដ្ឋាភិបាលសម្រាប់មនុស្សជាតិមកដល់បច្ចុប្បន្ន។ | ៣ ម៉ |

| | | |
|---|---|---|
| សញ្ជ័យយកដែនដី និងមនុស្ស?<br>**៤.៣- មរតកសម្រាប់មនុស្សជាតិ**<br>ក. សាសនា និងច្បាប់<br>ខ. វិស្វកម្ម និងស្ថាបត្យកម្ម<br>គ. ច្បាប់ និងទម្រង់រដ្ឋាភិបាល<br>**សំណួរត្រិះរិះ** :<br>• តើទម្រង់នៃរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នមានភាពស្រដៀងគ្នា និងផ្សេងគ្នាយ៉ាងដូចម្តេចខ្លះពីរដ្ឋាភិបាលប្រជាធិបតេយ្យចក្រភពរ៉ូម?<br>• តើរ៉ូមបានបន្សល់ទុកមរតកសាសនាអ្វីខ្លះសម្រាប់មនុស្សជាតិ? | | |
| **មេរៀនទី ៥** : **ឥណ្ឌាបុរាណ និងអរិយធម៌**<br>**សិក្សាបញ្ញត្តិ** : ឥណ្ទុស ដ្រាវីដ អារ្យ៉ន សាសនា ទំនៀមទម្លាប់ សិទ្ធិមនុស្ស វណ្ណៈសង្គម<br>**មាតិកា** :<br>**៥.១- ឧបទ្វីបឥណ្ឌា និងអរិយធម៌ដំបូង**<br>ក. ឥណ្ទុស<br>ខ. ដ្រាវីដ<br>គ. អារ្យ៉ន<br>**សំណួរត្រិះរិះ** :<br>• តើប្រវត្តិវិទូបានស្គាល់ច្បាស់អំពីអរិយធម៌ដំបូងរបស់ឥណ្ឌាដោយរបៀបណា និងមានអ្វីខ្លះជាភស្តុតាង?<br>**៥.២- ចក្រភពឥណ្ឌាបុរាណ និងការដឹកនាំ**<br>ក. ចន្ទ្រគុប្តៈមោរ្យ និងការដឹកនាំរដ្ឋ<br>ខ. ចន្ទ្រគុប្តៈ និងការដឹកនាំរដ្ឋ<br>**សំណួរត្រិះរិះ** :<br>• តើអ្នកយល់យ៉ាងដូចម្តេចពីការដឹកនាំរដ្ឋរបស់អធិរាជចន្ទ្រគុប្តៈមោរ្យ និងអធិរាជចន្ទ្រគុប្តៈ?<br>**៥.៣- សាសនាព្រះពុទ្ធ និងហិណ្ឌូ**<br>ក. ហិណ្ឌូសាសនា និងប្រជាជនឥណ្ឌា<br>ខ. ព្រះពុទ្ធសាសនា និងប្រជាជនឥណ្ឌា<br>គ. ព្រះបាទអសោក និងព្រះពុទ្ធសាសនា | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឧបទ្វីបឥណ្ឌា និងការកកើតរដ្ឋ<br>- ប្រាប់ពីអរិយធម៌ឥណ្ទុស ដ្រាវីដ និងអារ្យ៉ន<br>- រៀបរាប់ពីចក្រភពឥណ្ឌាបុរាណ ក្នុងសម័យមោរ្យ និងគុប្តៈ<br>- រៀបរាប់ពីឥទ្ធិពលនៃសាសនាព្រះពុទ្ធ និងសាសនាហិណ្ឌូ លើជីវិតរបស់ប្រជាជនឥណ្ឌា។<br>**បំណិនសម្បទា**<br>- ភ្ជាប់ទស្សនាទានរបស់ព្រះបាទអសោ ក្នុងការដឹកនាំរដ្ឋ និងបង្កើតវប្បធម៌អត់ឱនដោយប្រើគោលការណ៍ព្រះពុទ្ធសាសនា<br>- វិភាគពីការបែងចែកស្រទាប់មក្នុងសង្គវណ្ណៈ។ឥណ្ឌា<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមអំពីឥទ្ធិពលអក្សរសិល្ប៍ឥណ្ឌា សាសនាព្រះពុទ្ធ និងហិណ្ឌូមកលើកម្ពុជា។ | ៣ ម៉ |

| | | |
|---|---|---|
| **សំណួរត្រិះរិះ** :<br>• តើសាសនាហិណ្ឌូ និងព្រះពុទ្ធមានឥទ្ធិពលលើប្រជាជនឥណ្ឌាយ៉ាងដូចម្ដេចខ្លះ ?<br>• តើហេតុអ្វីបានជាព្រះបាទអសោក យកគោលការណ៍ព្រះពុទ្ធសាសនាដឹកនាំរដ្ឋ ?<br>**៥.៤- ឥទ្ធិពលឥណ្ឌា និងកម្ពុជា**<br>ក. អក្សរសិល្ប៍ឥណ្ឌា និងកម្ពុជា<br>ខ. សាសនាព្រះពុទ្ធ និងកម្ពុជា<br>គ. សាសនាហិណ្ឌូ និងកម្ពុជា<br>**សំណួរត្រិះរិះ** :<br>• តើឥទ្ធិពលអក្សរសិល្ប៍ សាសនាព្រះពុទ្ធ និងសាសនាហិណ្ឌូ ធ្វើឱ្យកម្ពុជាមានការកែប្រែសង្គមយ៉ាងដូចម្ដេចខ្លះ ? | | |
| **មេរៀនទី ៦ : ចិនបុរាណ និងអរិយធម៌**<br>**សិក្សាបញ្ញត្តិ** : អធិរាជសាង រាជវង្សជូ រាជវង្សហាន វប្បធម៌ លទ្ធិតៅ លទ្ធិខុងជឺ ជំនឿ<br>**មាតិកា** :<br>**៦.១- ភូមិសាស្ត្រ និងសង្គមមនុស្ស**<br>ក. ទន្លេ និងមនុស្ស<br>ខ. ការតាំងលំនៅ និងជីវភាព<br>**សំណួរត្រិះរិះ** :<br>• ហេតុអ្វីបានជាប្រជាជនចិនសម័យបុរាណច្រើនស្វែងរកភូមិសាស្ត្ររស់នៅតាមដងទន្លេ ?<br>• តើប្រជាជនចិនក្នុងសម័យបុរាណ មានរបៀបរបបរស់នៅយ៉ាងដូចម្ដេច ?<br>**៦.២- រាជវង្ស និងអរិយធម៌ដំបូង**<br>ក. រាជវង្សសាង និងទម្រង់នៃការគ្រប់គ្រងរដ្ឋ<br>ខ. រាជវង្សសាង និងវណ្ណៈសង្គម<br>គ. រាជវង្សជូ និងជំនឿឋានសួគ៌<br>ឃ. រាជវង្សជូ និងការពង្រីកទឹកដី<br>**សំណួរត្រិះរិះ** :<br>• តើអរិយធម៌ដំបូងរបស់ចិន មានអ្វីខ្លះ ?<br>• តើរាជវង្សសាង និងជូគ្រប់គ្រងចិនក្នុង | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការតាំងលំនៅ និងរបៀបរបបរស់នៅរបស់ប្រជាជនចិន ក្នុងសម័យបុរាណ<br>- រៀបរាប់ពីការបង្កើតរដ្ឋាភិបាលនិងការបែងចែកវណ្ណៈសង្គមក្នុងរាជវង្សសាង<br>- ប្រាប់ពីការបង្កើតរដ្ឋ ជំនឿឋានសួគ៌ និងការគ្រប់គ្រងប្រទេសនៃរាជវង្សជូ<br>- ពន្យល់ពីយុទ្ធសាស្ត្រ នៃការពង្រីកទឹកដីក្នុងរាជវង្សជូ ។<br>**បំណិនសម្បទា**<br>- វិភាគពីឥទ្ធិពលនៃជំនឿសាសនាលើកសិកម្ម របស់ប្រជាជនចិន បុរាណ<br>- ភ្ជាប់ឥទ្ធិពលនៃលទ្ធិខុងជឺ និងលទ្ធិតៅ ជាប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយ ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីឥទ្ធិពលនៃគតិបណ្ឌិត និងគុណធម៌ធ្វើឱ្យរាជវង្សហានខ្លាំង បង្រួបបង្រួមជាតិសាសន៍ និងពង្រីកទឹកដី។ | ៣ ម៉ |

| | | |
|---|---|---|
| សម័យបុរាណយ៉ាងដូចម្ដេច?<br>**៦.៣- រាជវង្សឈីង និងច្បាប់**<br>ក. ច្បាប់ និងឯកភាពជាតិ<br>ខ. មហាកំពែង និងពលិកម្ម<br>គ. ពន្ធដារ និងអំពើឃោរឃៅ<br>**សំណួរត្រិះរិះ** :<br>• ហេតុអ្វីបានជារាជវង្សឈីង ចាត់ទុកច្បាប់ជាគោលចម្បងសម្រាប់ឱ្យប្រទេសខ្លាំង?<br>• តើកត្តាអ្វីខ្លះនាំឱ្យរាជវង្សឈីងដួលរលំ?<br>**៦.៤- រាជវង្សហាន និងវិបុលភាព**<br>ក. អធិរាជវូទី គតិបណ្ឌិត និងគុណធម៌<br>ខ. ចិន និងផ្លូវសូត្រ<br>គ. រដ្ឋបាលសាធារណៈ និងតួនាទីស្ត្រី<br>ឃ. រាជវង្សហាន និងយុគមាស<br>**សំណួរត្រិះរិះ** :<br>• តើរាជវង្សហានបានបន្សល់ទុកសមិទ្ធផលអ្វីខ្លះសម្រាប់មនុស្សជំនាន់ក្រោយ?<br>• តើការដឹកនាំនៃរាជវង្សហានឈរលើគោលការណ៍អ្វី ធ្វើឱ្យប្រទេសខ្លាំង និងបង្កើតវិបុលភាពសម្រាប់មនុស្សជំនាន់ក្រោយ? | | |
| **មេរៀនទី៧** : **អាមេរិកកណ្ដាល និងអរិយធម៌**<br>**សិក្សាបញ្ញត្តិ** : ម៉ាយ៉ា អាស្តែក អាំងកា ភូមិកសិកម្ម សង្គមមនុស្ស អក្សរ គណិតវិទ្យា រាជធានី<br>**មាតិកា** :<br>**៧.១- អរិយធម៌ម៉ាយ៉ា**<br>ក. ភូមិកសិកម្ម និងពាណិជ្ជកម្ម<br>ខ. សាសនា និងគណិតវិទ្យា<br>គ. អក្សរ និងគំនិតអភិវឌ្ឍន៍<br>ឃ. ប្រជាជន និងស្ថាបត្យកម្ម<br>ង. ឱនភាព និងការបោះបង់រាជធានី<br>**សំណួរត្រិះរិះ** :<br>• តើប្រជាជនម៉ាយ៉ាមានរជីវភាពរស់នៅយ៉ាងដូចម្ដេច និងពឹងអាស្រ័យលើមុខរបរអ្វីជាសំខាន់? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការតាំងលំនៅ និងរបៀបរបបរស់នៅរបស់ប្រជាជនម៉ាយ៉ា អាស្តែក និងអាំងកា<br>- រៀបរាប់ពីការប្រើប្រាស់អក្សរ គណិតវិទ្យា វិទ្យាសាស្ត្រ និងការប្រតិបត្តិសាសនារបស់អរិយធម៌ម៉ាយ៉ា អាស្តែក និងអាំងកាសម្រាប់វឌ្ឍនភាពសង្គម ។<br>**បំណិនសម្បទា**<br>- វិភាគពីកត្តានាំឱ្យអរិយធម៌ម៉ាយ៉ា អាស្តែក និងអាំងកា ឈានដល់រុងរឿង និងឱនភាព<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីកត្តាជំនឿ និងកសិកម្មធ្វើឱ្យអរិយធម៌អាមេរិកកណ្ដាលមានភាពរុងរឿង។ | ២ ម៉ |

| | | |
|---|---|---|
| • តើជំនឿ សាសនា គណិតវិទ្យា អក្សរ និង វិទ្យាសាស្ត្ររបស់អរិយធម៌ម៉ាយ៉ាជំរុញដល់ភាពរុងរឿងរបស់ម៉ាយ៉ា យ៉ាងដូចម្ដេចខ្លះ ?<br>**៧.២- អរិយធម៌អាស្តែក**<br>ក. ការតាំងលំនៅ និងកសិកម្ម<br>ខ. ជំនឿ និងសាសនា<br>គ. ភាពរុងរឿង និងឱនភាព<br>**សំណួរត្រិះរិះ** :<br>• តើផលិតកម្មស្បៀងអាហាររបស់ប្រជាជនអាស្តែកធានាឱ្យការរស់នៅមានភាពជឿនលឿនយ៉ាងដូចម្ដេចខ្លះ ?<br>• តើជំនឿនិងសាសនាដែលប្រតិបត្តិដោយប្រជាជនអាស្តែក រួមចំណែកដល់ភាពល្អប្រសើរនៃជីវភាពរស់នៅ និងមុខរបររបស់ប្រជាជនយ៉ាងដូចម្ដេចខ្លះ ?<br>**៧.៣- អរិយធម៌អាំងកា**<br>ក. សាសនា និងប្រជាជន<br>ខ. ចក្រភព និងរដ្ឋាភិបាល<br>គ. ជំនឿ និងការរក្សាសព<br>**សំណួរត្រិះរិះ** :<br>• តើកត្តាជម្លោះផ្ទៃក្នុងអ្វីខ្លះបានធ្វើឱ្យអរិយធម៌អាំងកា ធ្លាក់ចុះខ្លាំង ?<br>• តើចក្រភពអាំងកាត្រូវបានបង្កើតឡើងដោយរបៀបណា ? | | |
| **មេរៀនទី៨** : **មជ្ឈិមបូព៌ា និងអរិយធម៌បុរាណ**<br>**សិក្សាបញ្ញត្តិ** : ភូមិសាស្ត្រ សង្គមមនុស្ស ការដឹកនាំ អរិយធម៌ ជំនឿ សាសនា ស្ថាបត្យកម្ម នយោបាយ<br>**មាតិកា** :<br>**៨.១- អរិយធម៌មេសូប៉ូតាមី**<br>ក. ទីតាំងភូមិសាស្ត្រ និងកុលសម្ពន្ធ<br>ខ. រដ្ឋសំខាន់ៗ និងនយោបាយវាតទី<br>គ. រដ្ឋស៊ុយមែរ<br>ឃ. រដ្ឋកាល់ដេ ឬអាកាត<br>ង. រដ្ឋអាស៊ីរី | **វិជ្ជាសម្បទា**<br>- អធិប្បាយពីទីតាំងភូមិសាស្ត្រ កុលសម្ពន្ធ រដ្ឋសំខាន់ៗ និងនយោបាយវាតទី<br>- កំណត់ពីមូលហេតុនៃការដណ្ដើមគ្នាកាន់កាប់ទឹកដី និងជនជាតិទាំងនេះ<br>- រៀបរាប់ពីប្រវត្តិទឹកដី ជនជាតិហេប្រឺ រដ្ឋសំខាន់ៗ និងសម័យរុងរឿង<br>- អធិប្បាយពីទីតាំងភូមិសាស្ត្រ ជីវភាព នយោបាយ និងអរិយធម៌ផេនីស៊ី។<br>**បំណិនសម្បទា** | ៣ ម៉ |

| | | |
|---|---|---|
| **សំណួរត្រិះរិះ** :<br>• តើអរិយធម៌មេសូប៉ូតាមី បន្សល់ទុកមរតកអ្វីខ្លះ សម្រាប់មនុស្សជំនាន់ក្រោយ?<br>**៨.២- អរិយធម៌ហេប្រឺ**<br>ក. ប្រវត្តិទឹកដីនិងជនជាតិ<br>ខ. សម័យកាលសំខាន់ៗ<br>គ. សម័យកាលរុងរឿង<br>ឃ. សម័យចុះខ្សោយ<br>**សំណួរត្រិះរិះ** :<br>• តើអរិយធម៌ហេប្រឺផ្ដល់ធាតុសំខាន់អ្វីខ្លះ សម្រាប់ភាពរុងរឿងក្នុងមជ្ឈិមបូព៌ា?<br>**៨.៣- អរិយធម៌ផេនីស៊ី**<br>ក. ទីតាំងភូមិសាស្ត្រ<br>ខ. ជីវភាពនយោបាយ<br>គ. អរិយធម៌ប្រទេសផេនីស៊ី<br>**សំណួរត្រិះរិះ** :<br>• តើអរិយធម៌ផេនីស៊ីបង្ហាញភាពខ្លាំង ក្នុងតំបន់យ៉ាងដូចម្ដេចខ្លះ? | - វិភាគពីមូលហេតុនៃការរុងរឿងនិងការចុះខ្សោយនៃអរិយធម៌មេសូប៉ូតាមី<br>- វិភាគពីមូលហេតុនៃការរុងរឿងនិងការចុះខ្សោយនៃអរិយធម៌ហេប្រឺ<br>- ប្រៀបធៀបអរិយធម៌ហេប្រឺ និងអរិយធម៌ផេនីស៊ី។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីមរតកនៃអរិយធម៌មេសូប៉ូតាមី និងហេប្រឺ សម្រាប់មនុស្សជំនាន់ក្រោយ | |

### ៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៨

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១ : ប្រវត្តិសាស្ត្រកម្ពុជា និងអរិយធម៌** | | |
| **មេរៀនទី១ : ចតុមុខ និងអត្តសញ្ញាណ**<br>**សិក្សាបញ្ញត្តិ** : អត្តសញ្ញាណ សាមគ្គីភាព ការផ្លាស់ប្ដូរ និរន្តរភាព ឥទ្ធិពល សាសនា ជំនឿ សន្តិវិធី<br>**មាតិកា** :<br>១.១- ចតុមុខ និងនិរន្តរភាពវប្បធម៌<br>ក. ការដាក់ឈ្មោះរាជធានី<br>• ឈ្មោះរាជធានីស្រីសន្ធរ<br>• ឈ្មោះរាជធានីចតុមុខ<br>ខ. ស្ថលរាជធានី<br>គ. អង្គរ-រាជធានីសក្ការបូជា<br>**សំណួរត្រិះរិះ** :<br>• តើការអភិវឌ្ឍសម័យចតុមុខបានអភិរក្ស | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃសាសនា និងជំនឿទៅលើការសម្រេចចិត្តផ្នែកនយោបាយ ការអប់រំ និងប្រពៃណី<br>- សម្គាល់សកម្មភាពដែលរក្សាបាននូវនិរន្តរភាពនៃអត្តសញ្ញាណជាតិ។<br>**បំណិនសម្បទា**<br>- វិភាគពីមូលហេតុនៃជម្លោះផ្ទៃក្នុង និងផលវិបាក<br>- វិភាគពីវិធីបង្រួបបង្រួមជាតិ និងដោះស្រាយវិបត្តិផ្ទៃក្នុងប្រទេស<br>- រិះគន់លើប្រភពឯកសារដែលបង្ហាញពី | ៦ ម៉ |

| | | |
|---|---|---|
| អត្តសញ្ញាណអ្វីខ្លះ និងយ៉ាងដូចម្ដេច?<br>១.២- ពុទ្ធសាសនាថេរវាទ និងឥទ្ធិពល<br>ក. ការផ្លាស់ប្ដូរសាសនា<br>ខ. ពុទ្ធសាសនាថេរវាទ និងនយោបាយ<br>គ. ពុទ្ធសាសនាថេរវាទ និងទម្រង់ថ្មីនៃសាមគ្គីភាព (ការកសាងផ្លូវ វត្ត ស្ពាន ស្រះទឹក និងអវត្តមានប្រាសាទថ្ម)<br>ឃ. ពុទ្ធសាសនាថេរវាទ និងការអប់រំ<br>ង. ពុទ្ធសាសនាថេរវាទ និងទំនៀមទម្លាប់ប្រពៃណី<br>**សំណួរត្រិះរិះ** :<br>• តើការផ្លាស់ប្ដូរពីពុទ្ធសាសនាមហាយានមកពុទ្ធសាសនាថេរវាទបានធ្វើឱ្យកម្ពុជាមានការផ្លាស់ប្ដូរយ៉ាងដូចម្ដេចខ្លះ?<br>១.៣- វិបត្តិរាជវង្ស : ស្រីរាជា ធម្មរាជា និងស្រីសុរិយោទ័យ<br>ក. ទម្រង់នៃការគ្រប់គ្រងរដ្ឋ<br>ខ. អំណាច និងវិសាលភាពដែនដី<br>គ. ច្បាប់ និងការអនុវត្ត<br>ឃ. សន្តតិវង្ស និងការផ្ទេររាជ្យសម្បត្តិ<br>**សំណួរត្រិះរិះ** :<br>• តើមូលហេតុអ្វីខ្លះដែលបង្កឱ្យខ្មែរបែកបាក់សាមគ្គី និងមានវិបត្តិរាជវង្សក្នុងសម័យចតុមុខ?<br>១.៤- វិបត្តិរាជវង្ស និងដំណោះស្រាយ<br>ក. ប្រយោជន៍រួម និងការលះបង់<br>ខ. ឱកាស និងភាពវៃឆ្លាត<br>**សំណួរត្រិះរិះ** :<br>• តើកម្ពុជាអាចបង្រួបបង្រួមជាតិបានយ៉ាងដូចម្ដេច?<br>១.៥- វិបត្តិរាជវង្ស និងផលប៉ះពាល់<br>ក. ព្រះមហាក្សត្រ៣ អាណាចក្រ៣<br>ខ. អធិបតេយ្យភាព និងអស្ថិរភាព<br>គ. ប្រជាជន និងស្មារតី | ប្រវត្តិសាស្ត្រសម័យចតុមុខ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីការចូលរួមសម្រេចចិត្តដោយប្រើភស្តុតាង និងការវិភាគគ្រប់ជ្រុងជ្រោយ។ | |

| | | |
|---|---|---|
| **សំណួរត្រិះរិះ** :<br>• តើការខ្វះសាមគ្គីភាព និងវិបត្តិរាជវង្សបង្កផលប៉ះពាល់អ្វីខ្លះដល់ប្រជាជន និងសង្គមជាតិ?<br>១.៦- វិបត្តិរាជ្យបល្ល័ង្ក: ស្រីសុគន្ធបទ និងស្តេចកន<br>ក. អបិយជំនឿ និងការខ្វះវិចារណញាណ<br>ខ. អំណាច និងសុវត្ថិភាពផ្ទាល់ខ្លួន<br>**សំណួរត្រិះរិះ** :<br>• តើអ្វីជាបុព្វហេតុចម្បងនៃវិបត្តិរាជ្យបល្ល័ង្ករវាងព្រះបាទស្រីសុគន្ធបទនិងស្តេចកន?<br>១.៧- ចន្ទរាជា និងការបន្តនិរន្តរភាពសន្តតិវង្ស<br>ក. សង្គ្រាមដណ្តើមអំណាច<br>ខ. ព្រះបាទស្រីសុគន្ធបទ និងសម្ពតិកម្ម<br>**សំណួរត្រិះរិះ** :<br>• តើព្រះបាទចន្ទរាជាអាចបន្តនិរន្តរភាពនៃសន្តតិវង្សរបស់ព្រះអង្គយ៉ាងដូចម្តេច?<br>១.៨- ចូរត្រិះរិះ<br>**សំណួរត្រិះរិះ** :<br>• ប្រសិនបើប្អូនជាព្រះបាទចន្ទរាជា តើប្អូនគួរសម្រេចចិត្តយ៉ាងដូចម្តេចចំពោះដំណោះស្រាយជម្លោះដណ្តើមរាជ្យ? | | |
| **មេរៀនទី២** : **លង្វែក និងការពង្រឹងអំណាចឡើងវិញ**<br>**សិក្សាបញ្ញត្តិ** : អត្តសញ្ញាណ ការផ្លាស់ប្តូរ និរន្តរភាព មូលហេតុ សាមគ្គីភាព<br>**មាតិកា** :<br>២.១- ការស្តារប្រទេស<br>ក. ជំនឿ និងការដឹកនាំ<br>ខ. អង្គរ និងការគោរពបូជា<br>គ. ច្បាប់ និងក្បួនខ្នាត<br>ឃ.សិល្បៈ អក្សរសាស្ត្រ និងអក្សរសិល្ប៍<br>ង. ការពង្រីកអំណាច<br>ច. លង្វែក: មជ្ឈមណ្ឌលផ្សព្វផ្សាយវប្បធម៌<br>សំណួរត្រិះរិះ : | **វិជ្ជាសម្បទា**<br>- បង្ហាញពីការរក្សានិរន្តរភាពប្រទេសរបស់ព្រះមហាក្សត្រខ្មែរសម័យលង្វែក។<br>**បំណិនសម្បទា**<br>- វិភាគពីដំណើរការស្តារប្រទេស ដោយឈរលើគោលការណ៍ច្បាប់ និងសាសនា<br>- ភ្ជាប់ទំនាក់ទំនងនៃការសម្រេចចិត្តរបស់ព្រះបាទសត្ថាទី១ ជាមួយនឹងការធ្លាក់ចុះនៃអំណាចដឹកនាំរបស់ព្រះអង្គ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីផលវិបាកនៃការបែកបាក់បន្ទាយលង្វែក។ | ៧ ម៉ |

| | | |
|---|---|---|
| • ព្រះរាជាខ្មែរបន្តនិរន្តរភាពប្រទេសដោយរបៀបណា ?<br>២.២- នយោបាយ និងការដឹកនាំទៅរកការអភិវឌ្ឍ<br>ក. ចន្ទរាជា និងឥស្សរភាព<br>ខ. បរមីន្ទរាជា និងការដាក់សៀមជាសាមន្តរដ្ឋ<br>សំណួរត្រិះរិះ :<br>• មូលហេតុអ្វីខ្លះដែលព្រះបាទចន្ទរាជា និងព្រះបាទបរមីន្ទរាជាអាចការពារអាណាចក្រខ្មែរពីការឈ្លានពានរបស់សៀមបាន ?<br>២.៣- ព្រះបាទសត្ថាទី១ និងការបែកបាក់លង្វែក<br>សំណួរត្រិះរិះ :<br>• មូលហេតុអ្វីខ្លះដែលធ្វើឱ្យខ្មែរមិនអាចការពារបន្ទាយលង្វែកបានក្នុងដំណាក់កាលចុងក្រោយ ?<br>២.៤- ផលវិបាកនៃការបែកបាក់បន្ទាយលង្វែក<br>ក. ការបែកបាក់ និងឱនភាពក្នុងការដឹកនាំ<br>ខ. ការបែកបាក់ និងឥទ្ធិពលសៀម<br>គ. ការបែកបាក់ និងក្តីសង្ឃឹម<br>សំណួរត្រិះរិះ :<br>• តើកម្ពុជាស្ថិតក្នុងស្ថានភាពបែបណាក្រោយការបែកបាក់បន្ទាយលង្វែក ? | | |
| **មេរៀនទី ៣** : **ឧដុង្គ និងការរក្សានិរន្តរភាព**<br>**សិក្សាបញ្ញត្តិ** : ជម្លោះ ការគ្រប់គ្រង អក្សរសិល្ប៍ សាសនា វប្បធម៌ នយោបាយ សង្គម អន្តរាគមន៍<br>**មាតិកា** :<br>**៣.១- ឧដុង្គ និងឱនភាព**<br>ក. ការបាក់បែកបន្ទាយលង្វែក និងឥទ្ធិពលលើសម័យឧដុង្គ<br>• ការគ្រប់គ្រងរដ្ឋ និងបញ្ហាប្រឈម<br>• ប្រជាជន និងមូលធម៌នៃចំណេះដឹង និងអនាគតជាតិ<br>ខ. ជម្លោះដណ្តើមរាជ្យ<br>គ. ទម្រង់គ្រប់គ្រងរដ្ឋបែប “ មណ្ឌល” | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីកត្តាដែលនាំឱ្យមានជម្លោះដណ្តើមរាជ្យ<br>- វិភាគអំពីឥទ្ធិពលនៃទម្រង់គ្រប់គ្រងរដ្ឋបែប “មណ្ឌល” លើនយោបាយខ្មែរ<br>**បំណិនសម្បទា**<br>- វិនិច្ឆ័យអំពីនិរន្តរភាពនៃប្រពៃណីខ្មែរក្នុងសម័យឧដុង្គបន្តមកដល់បច្ចុប្បន្ន<br>- វិនិច្ឆ័យពីស្ថានភាពសេដ្ឋកិច្ចសម័យឧដុង្គ<br>- វិភាគពីផលប៉ះពាល់យូរអង្វែងនៃការបែកបាក់បន្ទាយលង្វែកទៅលើសង្គមខ្មែរ។<br>**ចរិយាសម្បទា** | ៨ ម៉ |

| | | |
|---|---|---|
| ឃ. វប្បធម៌ពឹងប្រទេសជិតខាងដើម្បីអំណាច<br>• ច្បាប់ក្រុងវ៉ា និងរាជការខ្មែរ<br>• ឥទ្ធិពលសៀម និងរាជវង្សខ្មែរ<br>ង. ការបែកបាក់សង្គមខ្មែរ និងឥទ្ធិពលប្រទេសជិតខាង<br>• ចំណងមេត្រីភាពរវាងខ្មែរ និងយួន<br>• សៀម និងគោរម្យងារសម្រាប់ខ្មែរ<br>សំណួរត្រិះរិះ ៖<br>• តើកត្តាអ្វីខ្លះដែលជំរុញឱ្យកម្ពុជាធ្លាក់ក្នុងវិបត្តិ និងឱនភាពក្នុងសម័យឧដុង្គ?<br>**៣.២- ពុទ្ធសាសនា និងការអប់រំ**<br>ក. វត្តអារាម និងការអប់រំ<br>ខ. ស្នាដៃនិពន្ធ និងជំបូន្មាន<br>គ. អក្សរសាស្ត្រ និងអក្សរសិល្ប៍ខ្មែរ<br>សំណួរត្រិះរិះ :<br>• តើពុទ្ធសាសនាបានចូលរួមចំណែកយ៉ាងដូចម្តេចខ្លះក្នុងការអប់រំនៅកម្ពុជាក្នុងសម័យឧដុង្គ?<br>**៣.៣- ពុទ្ធសាសនា និងការដឹកនាំប្រទេស**<br>ក. ទស្សនវិជ្ជា និងការដឹកនាំ<br>ខ. ពុទ្ធសាសនា និងភាពជាអ្នកដឹកនាំ<br>សំណួរត្រិះរិះ :<br>• តើពុទ្ធសាសនាបានចូលរួមចំណែកយ៉ាងដូចម្តេចខ្លះក្នុងការដឹកនាំកម្ពុជាក្នុងសម័យឧដុង្គ?<br>**៣.៤- ឧដុង្គ និងសេដ្ឋកិច្ចជាតិ**<br>ក. ហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ច<br>ខ. រូបិយវត្ថុ និងសេដ្ឋកិច្ចកម្ពុជា<br>សំណួរត្រិះរិះ :<br>• តើហេដ្ឋារចនាសម្ព័ន្ធសម័យឧដុង្គ និងរូបិយវត្ថុបានបម្រើប្រយោជន៍សេដ្ឋកិច្ចយ៉ាងដូចម្តេច?<br>**៣.៥- ការរក្សាព្រលឹងជាតិ**<br>ក. ជំនឿ ប្រពៃណី និងទំនៀមទម្លាប់ | - សន្និដ្ឋានរួមអំពីការពង្រីកតម្លៃនៃការអប់រំ និងការដឹកនាំប្រទេសតាមបែបពុទ្ធសាសនា<br>- បណ្តុះទម្លាប់គោរពតម្លៃបញ្ញវន្តក្នុងការរួមចំណែកដល់អភិវឌ្ឍប្រទេស។ | |

| | | |
|---|---|---|
| ខ. ហេដ្ឋារចនាសម្ពន្ធ<br>គ. ស្នាដៃនិពន្ធ និងសាស្ត្រាល្បែង<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាប្រពៃណីមួយចំនួនបានបន្តនិរន្តរភាពមកដល់បច្ចុប្បន្ន ហើយមួយចំនួនទៀតត្រូវបាត់បង់ ?<br>**៣.៦- ចូរត្រិះរិះ**<br>• តើព្រះរាជាសម័យឧដុង្គបានឱ្យតម្លៃចំពោះការអប់រំ និងបញ្ញវន្តយ៉ាងដូចម្ដេចខ្លះ ?<br>• តើបញ្ញវន្តបានរួមចំណែកដល់ការរក្សាតម្លៃនៃប្រពៃណី និងច្បាប់យ៉ាងដូចម្ដេចខ្លះ ? | | |
| **មេរៀនទី ៤ : អាណាព្យាបាលបារាំង និងអភិក្រមទំនើបកម្ម**<br>**សិក្សាបញ្ញត្តិ** : អាណាព្យាបាល អភិក្រមទំនើបកម្ម អំណាច ស្ថានភាពនយោបាយ សង្គម បះបោរ<br>**មាតិកា** :<br>**៤.១- ការទទួលយកអំណាចបារាំងលើទឹកដីខ្មែរ**<br>ក. ខ្មែរក្រោមគំនាបយួន និងសៀម<br>ខ. អំណាចបារាំងក្នុងទស្សនៈខ្មែរ<br>គ. ផលប្រយោជន៍ខ្មែរក្នុងទស្សនៈបារាំង<br>• ទីតាំងភូមិសាស្ត្រ<br>• ធនធានធម្មជាតិ<br>• កិត្យានុភាពរបស់កម្ពុជា<br>• តំបន់ទ្រនាប់<br>ឃ. ការស្វែងរកកិច្ចការពារពីបារាំង<br>ង. ការដាក់អាណាព្យាបាល<br>សំណួរត្រិះរិះ :<br>• តើហេតុអ្វីបានជាកម្ពុជាស្វែងរកកិច្ចការពារពីបារាំង ? តើមូលហេតុអ្វីបានជាបារាំងងាកមកចាប់អារម្មណ៍ដាក់អាណាព្យាបាលលើកម្ពុជា ?<br>**៤.២- អាណាព្យាបាល**<br>ក. អាណាព្យាបាល<br>ខ. អាណានិគម | **វិជ្ជាសម្បទា**<br>- ពន្យល់ពីមូលហេតុដែលនាំឱ្យកម្ពុជាក្លាយជាប្រទេសក្រោមអាណាព្យាបាលបារាំង<br>- ពន្យល់ពីទម្រង់នៃការគ្រប់គ្រងរបស់បារាំងលើកម្ពុជា<br>- បង្ហាញពីបញ្ហាប្រឈម និងវិធីដែលបារាំងធ្វើឱ្យប្រទេសជិតខាងទទួលស្គាល់អំណាចរបស់ខ្លួនលើទឹកដីកម្ពុជា។<br><br>**បំណិនសម្បទា**<br>- វាយតម្លៃពីអភិក្រមទំនើបកម្ម និងផលវិបាកក្នុងអំឡុងសម័យអាណាព្យាបាល<br>- វិភាគអំពីចលនាតស៊ូ និងការទាមទារឯករាជ្យ ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានអំពីផលវិបាកនៃរបបអាណាព្យាបាលបារាំងលើទឹកដីកម្ពុជាក្នុងអំឡុងពេល៩០ឆ្នាំ។ | ១៤ ម៉ |

| | | |
|---|---|---|
| គ. ករណីកម្ពុជា<br>សំណួរត្រិះរិះ :<br>• តើការគ្រប់គ្រងរបស់បារាំងនៅឥណ្ឌូចិនមានទម្រង់បែបណាខ្លះ?<br>• តើកម្ពុជាស្ថិតនៅក្នុងទម្រង់នៃការគ្រប់គ្រងបែបអាណាព្យាបាល ឬអាណានិគម?<br>**៤.៣- អាណាព្យាបាលចាស់ និងអាណាព្យាបាលថ្មី**<br>ក. សៀម និងបារាំងក្នុងបរិបទកម្ពុជា<br>ខ. យួន និងបារាំងក្នុងបរិបទកម្ពុជា<br>សំណួរត្រិះរិះ :<br>• តើបារាំងប្រឈមនឹងបញ្ហាអ្វីខ្លះក្នុងការធ្វើឱ្យប្រទេសជិតខាងទទួលស្គាល់អំណាចខ្លួនលើទឹកដីខ្មែរ?<br>• តើបារាំងប្រើមធ្យោបាយអ្វីខ្លះក្នុងការឱ្យប្រទេសជិតខាងទទួលស្គាល់អំណាចខ្លួនលើទឹកដីខ្មែរ?<br>**៤.៤- អរិយធម៌ដ៏ចំណាស់ និងទំនើបកម្ម**<br>ក. ពី«រាជាធិរាជ»ទៅជា «រដ្ឋទំនើប»<br>ខ. ពីរាជានិយមផ្តាច់ការទៅជាប្រជាធិបតេយ្យ<br>គ. ពីទម្លាប់ទៅជាច្បាប់<br>ឃ. ពីសួយសាអាករទៅជាពន្ធអាករ<br>ង. ពីការបួសរៀនទៅជាការរៀននៅសាលា<br>ច. ពីការចងចាំទៅជាការចងក្រង<br>ឆ. ពីគ្រូហ្មទៅជាគ្រូពេទ្យ<br>ជ. ពីកសិកម្មប្រពៃណីទៅជាកសិកម្មទំនើប<br>ឈ. ពីកម្លាំងកាយទៅជាកម្លាំងម៉ាស៊ីន<br>សំណួរត្រិះរិះ :<br>• តើអភិក្រមទំនើបកម្មដែលបារាំងបាននាំមកកម្ពុជាជួបនឹងកត្តាប្រឈមអ្វីខ្លះ និងបានផ្តល់នូវលទ្ធផលវិជ្ជមាន ឬផលប៉ះពាល់អ្វីខ្លះក្នុងសង្គមខ្មែរ?<br>**៤.៥- ចលនាតស៊ូ និងការទាមទារឯករាជ្យ**<br>ក. ចលនាប្រជាជន | | |

| | | |
|---|---|---|
| ខ. ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើកម្ពុជាទទួលឯករាជ្យពីបារាំងដោយរបៀបណា?<br>**៤.៦- អាណាព្យាបាលបារាំង និងផលវិបាក**<br>សំណួរត្រិះរិះ :<br>• តើរបបអាណាព្យាបាលបារាំងផ្តល់នូវផលវិបាកអ្វីខ្លះ? | | |
| **ជំពូកទី ២ : ប្រវត្តិសាស្ត្រតំបន់ "អាស៊ីអាគ្នេយ៍ និងឥទ្ធិពលខាងក្រៅ(ស.វទី៨-ស.វទី១៥)"** | | |
| **មេរៀនទី១: អាស៊ីអាគ្នេយ៍ និងឥទ្ធិពលម៉ុងហ្គោល**<br>**សិក្សាបញ្ញត្តិ** : ភូមិសាស្ត្រ ឥទ្ធិពល ចិន ឥណ្ឌា អង្គរ អយុធ្យា ដាយវៀត ភូមា ឡានសាង ពាណិជ្ជកម្ម សៃលេន្ទ្រ ស្រីវិជ័យ<br>**មាតិកា**:<br>**១.១- ភូមិសាស្ត្រអាស៊ីអាគ្នេយ៍**<br>សំណួរត្រិះរិះ:<br>• តើអាស៊ីអាគ្នេយ៍ដែនដីកោះ និងដែនដីគោកស្ថិតនៅត្រង់ណានៃភូមិសាស្ត្រអាស៊ីអាគ្នេយ៍បច្ចុប្បន្ន?<br>**១.២- ឥទ្ធិពលវប្បធម៌ឥណ្ឌា និងចិន**<br>សំណួរត្រិះរិះ:<br>• តើបណ្តារដ្ឋនៅអាស៊ីអាគ្នេយ៍ទទួលឥទ្ធិពលវប្បធម៌ឥណ្ឌា និងចិនដោយរបៀបណាខ្លះ?<br>• ហេតុអ្វីបានជាឥណ្ឌា និងចិនមានឥទ្ធិពលខ្លាំងនៅតាមបណ្តារដ្ឋនៅអាស៊ីអាគ្នេយ៍?<br>**១.៣- រាជាណាចក្រអាស៊ីអាគ្នេយ៍ដីគោក**<br>ក. ចក្រភពអង្គរ<br>ខ. អយុធ្យា<br>គ. ដាយវៀត<br>ឃ. ភូមា<br>ង. ឡានសាង<br>សំណួរត្រិះរិះ:<br>• តើរាជាណាចក្រអាស៊ីអាគ្នេយ៍បុរាណបង្កើតរដ្ឋក្រោមឥទ្ធិពលនៃវប្បធម៌ណាខ្លះ? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីភូមិសាស្ត្រអាស៊ីអាគ្នេយ៍<br>- ពន្យល់ពីឥទ្ធិពលវប្បធម៌ ឥណ្ឌា-ចិននៅអាស៊ីអាគ្នេយ៍។<br>**បំណិនសម្បទា**<br>- វិភាគពីការបង្កើតរដ្ឋនៅអាស៊ីអាគ្នេយ៍ និងរដ្ឋពាណិជ្ជកម្ម។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីឥទ្ធិពលម៉ុងហ្គោលមកលើតំបន់អាស៊ីអាគ្នេយ៍។ | ៤ម៉ |

| | | |
|---|---|---|
| **១.៤- រាជាណាចក្រពាណិជ្ជកម្មដែនដីកោះ**<br>ក. ស្រីវិជ័យ<br>ខ. ម៉ាចាប៉ាហ៊ីត<br>សំណួរគ្រិះរិះ:<br>• តើច្រកម៉ាឡាកា ឋិតនៅឯណានៃផែនទីអាស៊ីអាគ្នេយ៍?<br>• ហេតុអ្វីបានជាច្រកម៉ាឡាកាមានលក្ខណៈពិសេសចំពោះពាណិជ្ជកម្មសមុទ្រ?<br>• តើរាជាណាចក្រស្រីវិជ័យ និងម៉ាចាប៉ាហ៊ីតបានក្លាយជារដ្ឋស្តុកស្តម្ភ និងជាមហាអំណាចពាណិជ្ជកម្មដែនកោះដោយរបៀបណា?<br>**១.៥- អាស៊ីអាគ្នេយ៍ និងឥទ្ធិពលម៉ុងហ្គោល**<br>សំណួរគ្រិះរិះ:<br>• ហេតុអ្វីបានជាអ្នកគិតថាម៉ុងហ្គោលមានឥទ្ធិពលខ្លាំងនៅតំបន់អាស៊ីអាគ្នេយ៍? | | |
| **មេរៀនទី២** : **ឥទ្ធិពលវប្បធម៌ចិន និងផ្លូវពាណិជ្ជកម្ម**<br>**សិក្សាបញ្ញត្តិ** : ចិន ទេសន្តប្រវេសន៍ ផ្លូវសូត្រពាណិជ្ជកម្ម នយោបាយ សួយសាអាករ កាទូត យោធា<br>**មាតិកា**:<br>**២.១- ទេសន្តប្រវេសន៍ និងពាណិជ្ជកម្ម**<br>សំណួរគ្រិះរិះ:<br>• តើអ្វីខ្លះជាមូលហេតុនៃទេសន្តប្រវេសន៍ និងពាណិជ្ជកម្មចិននៅអាស៊ីអាគ្នេយ៍?<br>**២.២- ឥទ្ធិពលនយោបាយ និងសួយសារអាករ**<br>សំណួរគ្រិះរិះ:<br>• តើចិនបានប្រើឥទ្ធិពលនយោបាយដោយវិធីអ្វីខ្លះដើម្បីទទួលបានសួយសាអាករពីបណ្តារដ្ឋនៅអាស៊ីអាគ្នេយ៍?<br>**២.៣- ពាណិជ្ជកម្ម និងតួនាទីផ្លូវសូត្រ**<br>សំណួរគ្រិះរិះ:<br>• តើពាណិជ្ជកម្មផ្លូវសូត្របានដើរតួនាទីយ៉ាងសំខាន់ដូចម្តេចខ្លះក្នុងការពង្រីកឥទ្ធិពលវប្ប | **វិជ្ជាសម្បទា**<br>- ប្រាប់ពីមូលហេតុនៃទេសន្តប្រវេសន៍ និងពាណិជ្ជកម្មចិននៅអាស៊ីអាគ្នេយ៍<br>- បង្ហាញពីឥទ្ធិពលនយោបាយចិន។<br>**បំណិនសម្បទា**<br>- វិភាគពីតួនាទីពាណិជ្ជកម្មផ្លូវសូត្រនៅអាស៊ីអាគ្នេយ៍<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីចំណាងកាទូត និងវត្តមានយោធាចិនក្នុងការពង្រីកឥទ្ធិពលវប្បធម៌។ | ៤ម៉ |

| | | |
|---|---|---|
| ធម៌ចិននៅអាស៊ីអាគ្នេយ៍?<br>**២.៤- ជំនួញ និងពាណិជ្ជករចិន**<br>សំណួរត្រិះរិះ:<br>• ហេតុអ្វីបានជាអ្នកជំនួញចិនទទួលបាននូវផលចំណេញដ៏ច្រើនសន្ធឹកសន្ធាប់ពីផ្លូវជំនួញនេះ?<br>**២.៥- ចំណងការទូត និងវត្ថុមានយោធាចិន**<br>សំណួរត្រិះរិះ:<br>• តើហេតុអ្វីបានជាអ្នកគិតថាការត្រួតត្រាផ្លូវជំនួញពីចិនទៅកាន់តំបន់អាស៊ីអាគ្នេយ៍ និងពីចិនទៅឥណ្ឌាជាការពង្រីកឥទ្ធិពលនៃវប្បធម៌ចិន? | | |
| **មេរៀនទី៣: អាស៊ីអាគ្នេយ៍ និងសាសនាឥស្លាម**<br>**សិក្សាបញ្ញត្តិ** : ឥស្លាម ពាណិជ្ជកម្ម ហិណ្ឌូ ម៉ាឡាកា<br>**មាតិកា** :<br>**៣.១- ពាណិជ្ជកម្មសមុទ្រ និងសាសនាឥស្លាម**<br>**សំណួរត្រិះរិះ**:<br>• តើភូមិសាស្ត្រនៃឧបទ្វីបអារ៉ាប់បានផ្តល់ប្រយោជន៍អ្វីខ្លះ និងដោយរបៀបណាសម្រាប់ជំនួញត្រីទ្វីប?<br>• តើពួកឥស្លាមអាចផ្សព្វផ្សាយវប្បធម៌របស់ខ្លួននៅអាស៊ីអាគ្នេយ៍ដោយរបៀបណា?<br>• តើការរកឃើញផ្លូវពាណិជ្ជកម្មថ្មីនៅសមុទ្រចិនខាងត្បូងជាមូលដ្ឋាននៃការធ្វើជំនួញរបស់ពួកឥស្លាមឬយ៉ាងណា?<br>**៣.២- សាសនាឥស្លាម និងហិណ្ឌូនិយម**<br>សំណួរត្រិះរិះ:<br>• តើមានភស្តុតាងអ្វីខ្លះបញ្ជាក់ថា ឥទ្ធិពលសាសនាឥស្លាមដើរតួនាទីជំនួសសាសនាហិណ្ឌូនៅម៉ាឡាកា?<br>**៣.៣- ម៉ាឡាកា និងឥទ្ធិពលសាសនាឥស្លាម**<br>សំណួរត្រិះរិះ:<br>• តើវត្តមានសាសនាឥស្លាមនៅម៉ាឡាកាកើត | **វិជ្ជាសម្បទា**<br>- ប្រាប់ពីភូមិសាស្ត្រ និងវប្បធម៌សាសនាឥស្លាម និងផ្លូវពាណិជ្ជកម្ម។<br>**បំណិនសម្បទា**<br>- វិភាគពីឥទ្ធិពលនៃសាសនាឥស្លាមមកលើសាសនាហិណ្ឌូ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីឥទ្ធិពលឥស្លាមមកលើម៉ាឡាកា។ | ៤ម៉ |

| | | |
|---|---|---|
| ឡើងតាមរបៀបណា ?<br>• តើមានភស្តុតាងអ្វីខ្លះដែលបង្ហាញថាម៉ាឡាកាជាមជ្ឈមណ្ឌលសិក្សាសាសនាឥស្លាម និងពាណិជ្ជកម្មសមុទ្រ ? | | |
| **មេរៀនទី៤ : អាស៊ីអាគ្នេយ៍ និងឥទ្ធិពលអឺរ៉ុប**<br>**សិក្សាបញ្ញត្តិ :** យុគសម័យរបកគំហើញ អឺរ៉ុប ព័រទុយហ្គាល់ អេស្ប៉ាញ ហូឡង់<br>**មាតិកា :**<br>**៤.១- របកគំឃើញ**<br>សំណួរត្រិះរិះ:<br>• របកគំហើញជាអ្វី និងកើតឡើងពេលណា ?<br>**៤.២- របកគំហើញរបស់ពួកព័រទុយហ្គាល់**<br>សំណួរត្រិះរិះ:<br>• តើហេតុអ្វីបានជាពួកព័រទុយហ្គាល់ធ្វើការរុករកគ្រឿងទេសនៅអាស៊ីអាគ្នេយ៍ ?<br>**៤.៣- ការរុករករបស់ពួកអេស្ប៉ាញ**<br>សំណួរត្រិះរិះ:<br>• តើមានមូលហេតុអ្វីខ្លះបានជាមានការរុក រករបស់ពួកអេស្ប៉ាញនៅអាស៊ីអាគ្នេយ៍ ?<br>**៤.៤- ការរុករករបស់ពួកហូឡង់**<br>សំណួរត្រិះរិះ:<br>• តើមានបុព្វហេតុអ្វីខ្លះបានជាមានការរុករករបស់ពួកហូឡង់នៅអាស៊ីអាគ្នេយ៍ ?<br>**៤.៥- រាជាណាចក្រថៃ**<br>សំណួរត្រិះរិះ:<br>• តើព្រះរាជាថៃធ្វើដូចម្តេចដើម្បីរក្សាអធិបតេយ្យភាពរបស់ខ្លួនក្នុងខណៈផ្នែកខ្លះនៃអាស៊ីអាគ្នេយ៍ស្ថិតនៅក្រោមការត្រួតត្រារបស់ពួកអឺរ៉ុប ?<br>• តើព្រះរាជាថៃបានសម្រេចចិត្តយ៉ាងដូចម្តេច និងធ្វើអ្វីខ្លះ ដើម្បីរក្សាអធិបតេយ្យភាព និងធានាឱ្យប្រទេសរួចផុតពីការត្រួតត្រារបស់ពួកអឺរ៉ុប ? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីនិយមន័យ និងដំណើរនៃការរុករករបស់ពួកអឺរ៉ុបនៅអាស៊ីអាគ្នេយ៍។<br>**បំណិនសម្បទា**<br>- វិភាគពីមូលហេតុនៃការរុករករបស់ពួកព័រទុយហ្គាល់ អេស្ប៉ាញ និងហូឡង់នៅអាស៊ីអាគ្នេយ៍។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីការរក្សាអធិបតេយ្យភាពរបស់ថៃឱ្យរួចផុតពីការត្រួតត្រារបស់ពួកអឺរ៉ុប។ | ៤ម៉ |

| | | |
|---|---|---|
| **មេរៀនទី៥ : អាស៊ីអាគ្នេយ៍ និងសាសនាគ្រិស្ត**<br>**សិក្សាបញ្ញត្តិ** : សាសនាគ្រិស្ត អឺរ៉ុប អំណាច ឥទ្ធិពល សេដ្ឋកិច្ច<br>**មាតិកា** :<br>**៥.១- ការមកដល់របស់ពួកអឺរ៉ុប**<br>**សំណួរត្រិះរិះ**:<br>• តើការមកដល់របស់ពួកអឺរ៉ុបនៅអាស៊ីអាគ្នេយ៍ជាសញ្ញាណដូចម្តេច?<br>**៥.២- ការពង្រីកអំណាចរបស់ពួកអឺរ៉ុប**<br>**សំណួរត្រិះរិះ**:<br>• ក្រោយពីពួកអឺរ៉ុបបានគ្រប់គ្រងទាំងអំណាចនយោបាយ និងសេដ្ឋកិច្ចពេញលេញនៅអាស៊ីអាគ្នេយ៍ តើពួកអឺរ៉ុបបានធ្វើអ្វីបន្តទៀតដើម្បីសម្រេចបេសកកម្ម និងគោលដៅរបស់ខ្លួន?<br>**៥.៣- អាស៊ីអាគ្នេយ៍ និងឥទ្ធិពលសាសនាគ្រិស្ត**<br>**សំណួរត្រិះរិះ**:<br>• តើមានភស្តុតាងអ្វីខ្លះបញ្ជាក់ពីឥទ្ធិពលសាសនាគ្រិស្តមកលើនយោបាយ សេដ្ឋកិច្ច និងជីវភាពប្រជាជន? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការមកដល់របស់ពួកអឺរ៉ុបនៅអាស៊ីអាគ្នេយ៍។<br>**បំណិនសម្បទា**<br>- វិភាគពីការពង្រីកអំណាចរបស់ពួកអឺរ៉ុបនៅអាស៊ីអាគ្នេយ៍។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីឥទ្ធិពលសាសនាគ្រិស្តគ្របដណ្តប់លើនយោបាយ សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន។ | ៤ម៉ |
| **ជំពូកទី៣ : ប្រវត្តិសាស្ត្រពិភពលោក "របកគំហើញដែនដីថ្មី និងបម្រែបម្រួលសង្គម"** | | |
| **មេរៀនទី១ : មជ្ឈិមសម័យនៅអឺរ៉ុប និងរបកគំហើញដែនដី**<br>**សិក្សាបញ្ញត្តិ** : សក្តិភូមិ រាជាធិបតេយ្យ ការប្រមូលផ្តុំ សេដ្ឋកិច្ចបិទ បណ្តូរសេរី មូលធននិយម របកគំហើញ បុនសម័យ<br>**មាតិកា** :<br>**១.១- ដើមមជ្ឈិមសម័យ និងកំណើតរដ្ឋសក្តិភូមិ**<br>ក. អឺរ៉ុប និងកំណើតរដ្ឋសក្តិភូមិ<br>ខ. អឺរ៉ុប និងស្ថានភាពសេដ្ឋកិច្ច<br>គ. អឺរ៉ុប និងស្ថានភាពសង្គម<br>**សំណួរត្រិះរិះ** :<br>• តើបុព្វហេតុអ្វីខ្លះដែលបណ្តាលឱ្យលេច | **វិជ្ជាសម្បទា**<br>- បង្ហាញពីការលេចឡើងនូវរដ្ឋសក្តិភូមិនៅអឺរ៉ុប<br>- កត់សម្គាល់ពីការវិវត្តនៃសង្គម សេដ្ឋកិច្ច និងនយោបាយនៅអឺរ៉ុបនាមជ្ឈិមសម័យ<br>- ពន្យល់ពីការកកើតឡើងនូវទីក្រុងក្នុងពិភពលោក។<br>**បំណិនសម្បទា**<br>- វិភាគពីការវិវត្តនៃរាជាធិបតេយ្យប្រមូលផ្តុំទៅជាការរំលែកអំណាច<br>- ប្រៀបធៀបពីលក្ខណៈទូទៅនៃរដ្ឋសក្តិភូមិ និងរដ្ឋមូលធននិយម | ៤ ម៉ |

| | | |
|---|---|---|
| ឡើងនូវរបបសក្តិភូមិនៅអឺរ៉ុប ?<br>• តើរបបគ្រប់គ្រងនៃរដ្ឋសក្តិភូមិមានលក្ខណៈបែបណា ?<br>• តើសង្គម និងសេដ្ឋកិច្ចនៅអឺរ៉ុបនាមជ្ឈិមសម័យមានការវិវត្តយ៉ាងដូចម្តេចខ្លះ ?<br>**១.២- កណ្តាលមជ្ឈិមសម័យ និងកំណើតទីក្រុង**<br>ក. កំណើតទីក្រុង<br>ខ. រាជាធិបតេយ្យប្រមូលផ្តុំ<br>គ. ចលនាតស៊ូ និងលទ្ធផល<br>**សំណួរត្រិះរិះ** :<br>• តើមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យមានការកកើតទីក្រុង ?<br>• តើរាជាធិបតេយ្យប្រមូលផ្តុំ និងការរំលែកអំណាចមានលក្ខណៈយ៉ាងដូចម្តេចខ្លះ ?<br>• ហេតុអ្វីបានជាមានការផ្លាស់ប្តូរពីរាជាធិបតេយ្យប្រមូលផ្តុំទៅជាការរំលែកអំណាចនៅកណ្តាលមជ្ឈិមសម័យនៅអឺរ៉ុប ?<br>• មូលហេតុអ្វីខ្លះដែលបណ្តាលឱ្យមានការវិវត្តពីរបបសក្តិភូមិទៅជាមូលធននិយមនៅកណ្តាលមជ្ឈិមសម័យនៅអឺរ៉ុប ?<br>**១.៣- ចុងមជ្ឈិមសម័យ និងរបកគំហើញ**<br>ក. ដំណើររុករកពិភពលោក<br>ខ. កំណើតមូលធន<br>គ. បុនសម័យ<br>**សំណួរត្រិះរិះ** :<br>• បុព្វហេតុអ្វីខ្លះដែលបណ្តាលឱ្យពួកអឺរ៉ុបរុករកដីថ្មី និងបានរកឃើញអ្វីខ្លះ ?<br>• តើរបកគំហើញនេះបានផ្តល់នូវផលវិបាកអ្វីខ្លះចំពោះប្រជាជាតិដែលពួកអឺរ៉ុបទៅដល់ ?<br>• ដើម្បីរៀបចំសង្គមមួយឱ្យជឿនលឿន តើពួកអឺរ៉ុបបានកែទម្រង់សាសនា និងវប្បធម៌ដោយរបៀបណានៅចុងមជ្ឈិមសម័យ ?<br>• នៅចុងមជ្ឈិមសម័យនៅអឺរ៉ុប តើកម្ពុជាបានស្តារវប្បធម៌របស់ខ្លួនរបៀបណា ? | - វិភាគពីដំណើររុករកពិភពលោក និងផលវិបាកនៃរបកគំហើញភូមិសាស្ត្រ<br>- វាយតម្លៃពីចលនាតស៊ូ និងផលវិបាកនៃចលនាទាំងនោះ<br>- ប្រៀបធៀបពីការរស់ឡើងវិញនូវវប្បធម៌បុរាណនៅអឺរ៉ុបទៅនឹងការស្តារឡើងវិញនៃវប្បធម៌នៅកម្ពុជាក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីការវិវត្តនៃសង្គម និងវប្បធម៌នៅអឺរ៉ុប និងការរកឃើញថ្មី ។ | |

| | | |
|---|---|---|
| **១.៤- ចូរត្រិះរិះ**<br>សំណួរត្រិះរិះ:<br>• តើអឺរ៉ុបនាមជ្ឈិមសម័យបានបន្សល់នូវមរតកអ្វីខ្លះដល់ពិភពលោក?<br>• តើការរុករក និងរបកគំហើញបានបណ្ដុះស្មារតីអ្វីខ្លះដល់មនុស្សជំនាន់ក្រោយ? | | |
| **មេរៀនទី ២ : បដិវត្តន៍គហបតីអង់គ្លេស និង អត្ថន័យជាប្រវត្តិសាស្ត្រ**<br>**សិក្សាបញ្ញត្តិ** : បដិវត្តន៍ គហបតី សាធារណរដ្ឋ រាជាធិបតេយ្យ ផ្ដាច់ការ ប្រជាធិបតេយ្យ សភា<br>**មាតិកា** :<br>**២.១- ការផ្ទុះបដិវត្តន៍គហបតី**<br>សំណួរត្រិះរិះ:<br>• តើមូលហេតុអ្វីខ្លះដែលជំរុញឱ្យបដិវត្តន៍គហបតីផ្ទុះឡើង និងមានទិសដៅអ្វីខ្លះ?<br>**២.២- ការវិវត្តនៃបដិវត្តន៍**<br>ក. ដំណើរនៃបដិវត្តន៍<br>ខ. ដំណាក់កាលចុងក្រោយនៃបដិវត្តន៍<br>សំណួរត្រិះរិះ:<br>• ហេតុអ្វីបានជាគេចាត់ទុកថាបដិវត្តន៍នៅអង់គ្លេសជាបដិវត្តន៍គហបតី?<br>• តើបដិវត្តន៍គហបតីនៅអង់គ្លេសផ្ទុះឡើងយ៉ាងដូចម្ដេច?<br>• តើបដិវត្តន៍គហបតីអង់គ្លេសចែកជាប៉ុន្មានដំណាក់កាល?អ្វីខ្លះ?<br>**២.៣- អង់គ្លេសក្រោយបដិវត្តន៍ និង លទ្ធិប្រជាធិបតេយ្យ**<br>សំណួរត្រិះរិះ:<br>• ចូរបង្ហាញពីការផ្លាស់ប្ដូរទម្រង់គ្រប់គ្រងរដ្ឋនៅអង់គ្លេសទាំងមុនបដិវត្តន៍ ក្នុងពេលបដិវត្តន៍ និងក្រោយបដិវត្តន៍<br>• ទម្រង់គ្រប់គ្រងរដ្ឋនៅអង់គ្លេសក្រោយបដិវត្តន៍នេះឥទ្ធិពលដូចម្ដេចខ្លះទៅលើពិភពលោក? | **វិជ្ជាសម្បទា**<br>- ពន្យល់ពីមូលហេតុនៃបដិវត្តន៍គហិបតីនៅអង់គ្លេស<br>- ពិពណ៌នាពីដំណើរបដិវត្តន៍នៅអង់គ្លេស។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបពីទម្រង់គ្រប់គ្រងនៅអង់គ្លេសមុនបដិវត្តន៍ និងក្រោយបដិវត្តន៍<br>- វាយតម្លៃពីការវិវត្តនៃលទ្ធិប្រជាធិបតេយ្យនៅអង់គ្លេស។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីការដឹកនាំជាតិតាមនីតិរដ្ឋឆ្ពោះទៅរកការអភិវឌ្ឍ។ | ៤ ម៉ |

| | | |
|---|---|---|
| **២.៤- អត្ថន័យជាប្រវត្តិសាស្ត្រ**<br>សំណួរត្រិះរិះ:<br>• តើលទ្ធិប្រជាធិបតេយ្យនៅអង់គ្លេសបានចាប់ផ្តើមតាំងពីពេលណាមក?<br>• តើលទ្ធិប្រជាធិបតេយ្យនៅអង់គ្លេសមានលក្ខណៈបរិសុទ្ធដែរឬទេក្រោយចប់បដិវត្តន៍? ព្រោះអ្វី?<br>• ដើម្បីទទួលបានជារដ្ឋប្រជាធិបតេយ្យពេញលេញ តើប្រជាជន និងរដ្ឋាភិបាលអង់គ្លេសបានរៀបចំកម្មវិធីនយោបាយដោយរបៀបណា?<br>**២.៥- ចូរត្រិះរិះ**<br>សំណួរត្រិះរិះៈ<br>• តើបដិវត្តន៍គហបតីអង់គ្លេសបានផ្តល់អត្ថន័យជាប្រវត្តិសាស្ត្រយ៉ាងដូចម្តេចខ្លះចំពោះអង់គ្លេស និងពិភពលោក?<br>• តើការផ្លាស់ប្តូរផ្នត់គំនិតពីការកែទម្រង់គ្រប់គ្រងរដ្ឋតាមបែបបដិវត្តន៍ទៅរកការកែទម្រង់គ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យបានឈរលើគោលការណ៍អ្វី និងហេតុអ្វី? | | |
| **មេរៀនទី ៣ : សង្គ្រាមដណ្តើមឯករាជ្យ និងការបង្កើតសហរដ្ឋអាមេរិក**<br>**សិក្សាបញ្ញត្តិ** : និគមជន សង្គ្រាម ឯករាជ្យ សេរីភាព សិទ្ធិមនុស្ស រដ្ឋសហព័ន្ធ រដ្ឋធម្មនុញ្ញ<br>**មាតិកា** :<br>**៣.១- ស្ថានភាពទូទៅនៃអាណានិគមទាំង១៣**<br>សំណួរត្រិះរិះ:<br>• តើរដ្ឋទាំង១៣ នៅសហរដ្ឋអាមេរិកមុនការមកដល់របស់ពួកអង់គ្លេសមានស្ថានភាពនយោបាយ សេដ្ឋកិច្ច និងសង្គមយ៉ាងដូចម្តេច?<br>**៣.២- បុព្វហេតុនៃការផ្ទុះសង្គ្រាម**<br>សំណួរត្រិះរិះ :<br>• តើការមកដល់របស់អាណានិគមអង់គ្លេស | **វិជ្ជាសម្បទា**<br>- បង្ហាញពីស្ថានភាពរដ្ឋដំបូងទាំង១៣ នៅអាមេរិកតាមមាត់សមុទ្រអាត្លង់ទិក<br>- រៀបរាប់ពីការតាំងអាណានិគមអង់គ្លេសនៅលើទឹកដីអាមេរិក។<br>**បំណិនសម្បទា**<br>- វិភាគពីមូលហេតុនៃការទាមទារឯករាជ្យរបស់ប្រជាជនអាមេរិក<br>- វិភាគពីអត្ថន័យជាប្រវត្តិសាស្ត្រនៃការប្រកាសឯករាជ្យរបស់រដ្ឋដំបូងនៅអាមេរិក<br>- ប្រៀបធៀបពីសិទ្ធិសេរីភាពរបស់ពលរដ្ឋអាមេរិកមុន និងក្រោយឯករាជ្យ<br>- វិភាគពីសារៈសំខាន់នៃរដ្ឋធម្មនុញ្ញ និងការបង្កើតរដ្ឋាភិបាលសហព័ន្ធ។ | ៤ ម៉ |

| | | |
|---|---|---|
| បាននាំមកនូវផលវិបាកអ្វីខ្លះចំពោះប្រជាជនអាមេរិក?<br>**៣.៣- ដំណើរប្រព្រឹត្តទៅនៃសង្គ្រាម**<br>សំណួរត្រិះរិះ :<br>• តើសង្គ្រាមទាមទារឯករាជ្យចែកជាប៉ុន្មានដំណាក់កាល និងកើតឡើងដោយសារមូលហេតុអ្វី?<br>**៣.៤- លទ្ធផល និងអត្ថន័យជាប្រវត្តិសាស្ត្រ**<br>សំណួរត្រិះរិះ:<br>• តើរដ្ឋណាដែលប្រកាសឯករាជ្យមុនគេក្នុងចំណោមរដ្ឋទាំង១៣?<br>• តើការប្រកាសឯករាជ្យនេះបានផ្តល់អត្ថន័យជាប្រវត្តិសាស្ត្រយ៉ាងដូចម្តេចខ្លះចំពោះរដ្ឋទាំង១៣ និងអាមេរិកទាំងមូល?<br>**៣.៥- ការបង្កើតសហរដ្ឋអាមេរិក និងសិទ្ធិមនុស្ស**<br>សំណួរត្រិះរិះ :<br>• តើការគោរពសិទ្ធិ និងសេរីភាពបានចូលរួមយ៉ាងដូចម្តេចខ្លះក្នុងការអភិវឌ្ឍសហរដ្ឋអាមេរិក?<br>**៣.៦- រដ្ឋធម្មនុញ្ញ**<br>សំណួរត្រិះរិះ :<br>• តើរដ្ឋធម្មនុញ្ញអាមេរិកមានឥទ្ធិពលលើការផ្លាស់ប្តូរសង្គម ក្នុងប្រទេស និងលើពិភពលោកយ៉ាងដូចម្តេចខ្លះ?<br>• តើទម្រង់គ្រប់គ្រងរដ្ឋសហព័ន្ធមានលក្ខណៈដូចម្តេចខ្លះ?<br>**៣.៧- ចូរត្រិះរិះ**<br>សំណួរត្រិះរិះ :<br>• តើការសាមគ្គីរបស់ប្រជាពលរដ្ឋផ្តល់ប្រយោជន៍អ្វីខ្លះដល់ការអភិវឌ្ឍជាតិ?<br>• តើការគោរពសិទ្ធិមនុស្ស និងការដឹកនាំជាតិតាមនីតិរដ្ឋមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះចំពោះប្រទេសជាតិ? | **ចរិយាសម្បទា**<br>- សន្និដ្ឋានពីកម្លាំងសាមគ្គីភាព និងការគោរពសិទ្ធិមនុស្សដែលនាំទៅរកការអភិវឌ្ឍជាតិ និងសន្តិភាព។ | |

| | | |
|---|---|---|
| **មេរៀនទី ៤ : បដិវត្តន៍គហបតីបារាំង និង របបសាធារណរដ្ឋ**<br>**សិក្សាបញ្ញត្តិ** : សមោធានវិជ្ជា សកររាជពន្លឺ រាជានិយមផ្តាច់ការ សាធារណរដ្ឋ សកររាជថ្មី បដិវត្តន៍ គហបតី<br>**មាតិកា**:<br>**៤.១- ស្ថានភាពប្រទេសបារាំងមុនបដិវត្តន៍**<br>ក. សកររាជពន្លឺ និងការរៀបចំមនោគមវិជ្ជា<br>ខ. ស្ថានភាពនយោបាយ និងសង្គម<br>សំណួរត្រិះរិះ :<br>• តើសមោធានវិជ្ជាជាអ្វី និងលេចឡើងក្នុងបរិបទបែបណា ?<br>**៤.២- ការផ្ទុះបដិវត្តន៍**<br>ក. មូលហេតុនៃការផ្ទុះបដិវត្តន៍<br>ខ. ដំណើរនៃការផ្ទុះបដិវត្តន៍<br>គ. លទ្ធផល និងអត្ថន័យជាប្រវត្តិសាស្ត្រ<br>សំណួរត្រិះរិះ:<br>• តើបដិវត្តន៍នៅប្រទេសបារាំងលេចឡើងដោយសារមូលហេតុអ្វី ? ដោយរបៀបណា និងមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះចំពោះប្រជាជាតិបារាំង ?<br>**៤.៣- ប្រទេសបារាំងក្រោយបដិវត្ត**<br>ក. រដ្ឋធម្មនុញ្ញ និងទម្រង់គ្រប់គ្រងរដ្ឋ<br>ខ. សង្គម និងសេដ្ឋកិច្ច<br>សំណួរត្រិះរិះ :<br>• តើបដិវត្តន៍គហបតីបារាំងនាំមកនូវការផ្លាស់ប្តូរអ្វីខ្លះនៅប្រទេសបារាំង ?<br>**៤.៤- ចូរត្រិះរិះ**:<br>សំណួរត្រិះរិះ:<br>• តើ**សមោធានវិជ្ជា**នាំមកនូវកាផ្លាស់ប្តូរយ៉ាងដូចម្តេចខ្លះចំពោះការសម្រេចចិត្តរបស់បញ្ញវន្ត និងនយោបាយរបស់បារាំង ? | **វិជ្ជាសម្បទា**<br>- បង្ហាញពីការលេចឡើងនូវមនោគមវិជ្ជាមុនបដិវត្តន៍<br>- ប្រាប់ពីស្ថានភាពនយោបាយនៅបារាំងមុនបដិវត្តន៍<br>- រៀបរាប់ពីដំណើរប្រព្រឹត្តទៅនៃបដិវត្តន៍គហបតី និងលទ្ធផល។<br>**បំណិនសម្បទា**<br>- វិភាគពីតម្លៃនៃរដ្ឋធម្មនុញ្ញក្នុងការបង្កើតរបបសាធារណរដ្ឋនៅបារាំង<br>- វាយតម្លៃលើការផ្លាស់ប្តូររបបនយោបាយនៅបារាំង។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍទម្លាប់ទទួលយកគំនិតច្នៃប្រឌិត និងទង្វើវិជ្ជមានដើម្បីរក្សាប្រយោជន៍មនុស្សជាតិ | ៣ ម៉ |

### ៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៩

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១ : ប្រវត្តិសាស្ត្រកម្ពុជា និងអរិយធម៌** | | |
| **មេរៀនទី ១ : សង្គមរាស្ត្រនិយម និងយុគមាស**<br>**សិក្សាបញ្ញត្តិ** : នយោបាយ អព្យាក្រឹត សន្តិភាព យុគមាស កិត្យានុភាព អត្តសញ្ញាណ កសិកម្ម ឧស្សាហកម្ម សមាជជាតិ<br>**មាតិកា** :<br>**១.១- កម្ពុជា និងនយោបាយអព្យាក្រឹត**<br>ក. ព្រះបាទ នរោត្តម សីហនុ និង នយោបាយ<br>ខ. សមាជជាតិ និងគោលនយោបាយ សាធារណៈ<br>គ. អព្យាក្រឹត និងអធិបតេយ្យភាព<br>• កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ<br>• ឥទ្ធិពលកុម្មុយនីស្ត<br>• អធិបតេយ្យភាព និងសន្តិភាព<br>សំណួរត្រិះរិះ :<br>• តើមូលហេតុអ្វីបានជា ព្រះបាទ នរោត្តម សីហនុ បានដាក់រាជ្យជូនព្រះបិតា និង បង្កើតសង្គមរាស្ត្រនិយម?<br>• តើការប្រឡូកក្នុងនយោបាយរបស់ព្រះបាទ នរោត្តម សីហនុ នាំមកនូវផលអ្វីខ្លះ?<br>• តើមូលហេតុអ្វីបានជាកម្ពុជាប្រកាន់យក នយោបាយអព្យាក្រឹត?<br>• តើការប្រកាន់នយោបាយអព្យាក្រឹតរបស់ កម្ពុជាត្រូវប្រឈមបញ្ហាអ្វីខ្លះ?<br>• តើនយោបាយអព្យាក្រឹតផ្តល់ផលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះដល់កម្ពុជា?<br>**១.២- ពុទ្ធសាសនា និងការអភិវឌ្ឍ**<br>សំណួរត្រិះរិះ :<br>• តើពុទ្ធសាសនាបានដើរតួនាទីអ្វីខ្លះក្នុងការ កសាងជាតិ?<br>• តើទ្រឹស្តីសង្គមនិយមពុទ្ធសាសនាត្រូវបាន | **វិជ្ជាសម្បទា**<br>- ពន្យល់ពីបម្រែបម្រួលស្ថានភាពនយោបាយ កម្ពុជា ក្រោយឯករាជ្យ ១៩៥៣-១៩៥៥<br>- រៀបរាប់ពីបញ្ហាប្រឈម និងការសម្រេចចិត្ត របស់កម្ពុជា ក្នុងការប្រកាន់យកនយោបាយ អព្យាក្រឹត។<br>**បំណិនសម្បទា**<br>- វិនិច្ឆ័យពីតួនាទីពុទ្ធសាសនាក្នុងនយោបាយ កម្ពុជា សម័យសង្គមរាស្ត្រនិយម<br>- ចង្អុលបង្ហាញពីភាពជឿនលឿនរបស់កម្ពុជា ក្នុងសង្គមរាស្ត្រនិយម។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីការកសាងអត្តសញ្ញាណជាតិខ្មែរ សម័យសង្គមរាស្ត្រនិយម<br>- អភិវឌ្ឍទម្លាប់ដាក់ខ្លួន និងបំពេញកិច្ចការ តាមសន្យា។ | ៧ ម៉ |

| | | |
|---|---|---|
| អនុវត្តជាប៉ុន្មានដំណាក់កាល?<br>**១.៣- សង្គមរាស្ត្រនិយម និងភាពជឿនលឿន**<br>ក. កសិកម្ម និងកសិឧស្សាហកម្ម<br>ខ. ឧស្សាហកម្ម<br>គ. នគរូបនីយកម្ម<br>សំណួរត្រិះរិះ :<br>• តើវិស័យឧស្សាហកម្ម និងកសិកម្មក្នុងសម័យសង្គមរាស្ត្រនិយមមានភាពជឿនលឿនយ៉ាងដូចម្ដេចខ្លះ?<br>**១.៤- កម្ពុជា និងភាពស៊ីវីល័យ**<br>ក. រដ្ឋបាល សន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម<br>ខ. ហិរញ្ញវត្ថុ<br>គ. ហេដ្ឋារចនាសម្ពន្ធ<br>ឃ. អប់រំ និងសុខាភិបាល<br>ង. ច្បាប់ និងប្រព័ន្ធយុត្តិធម៌<br>សំណួរត្រិះរិះ :<br>• តើហេដ្ឋារចនាសម្ពន្ធមានការអភិវឌ្ឍយ៉ាងដូចម្ដេចខ្លះ?<br>• តើភាពជឿនលឿនក្នុងការអភិវឌ្ឍមូលធនមនុស្សមានអ្វីខ្លះ?<br>• តើវិស័យសុខាភិបាល មានការអភិវឌ្ឍយ៉ាងដូចម្ដេចខ្លះ?<br>• តើសម័យសង្គមរាស្ត្រនិយមបានកសាងវប្បធម៌សាមគ្គីជាតិយ៉ាងដូចម្ដេចដែរ?<br>• តើប្រទេសជឿនលឿនត្រូវការការអនុវត្តច្បាប់ និង ការកសាងទំនុកចិត្តដល់ប្រជារាស្ត្រដោយវិធីណា?<br>**១.៥- អត្តសញ្ញាណ និងគំនិតច្នៃប្រឌិត**<br>ក. សញ្ញាសម្គាល់<br>ខ. ខេមរយានកម្ម<br>គ. វប្បធម៌ និងសិល្បៈ (របាំប្រជាប្រិយ បុណ្យ សម្លៀកបំពាក់ ការប្រតិបត្តិ...)<br>ឃ. អក្សរសិល្ប៍ | | |

| | | |
|---|---|---|
| សំណួរត្រិះរិះ :<br>• តើរបបសង្គមរាស្ត្រនិយមបានពង្រឹងអត្តសញ្ញាណជាតិឡើងវិញតាមវិធីអ្វីខ្លះ ?<br>• តើឥរិយាបថនិងទម្លាប់វិជ្ជមាន និងការដាក់ខ្លួនរបស់អ្នកដឹកនាំប្រទេស ផ្តល់ប្រយោជន៍អ្វីខ្លះដល់ប្រទេស និងប្រជាជន ? | | |
| **មេរៀនទី ២** : **សាធារណរដ្ឋខ្មែរ និងសង្គ្រាមស៊ីវិល**<br>**សិក្សាបញ្ញត្តិ** : រដ្ឋប្រហារ អំពើពុករលួយ រំលោភសិទ្ធិ បក្សពួកនិយម ជំហរមិនច្បាស់លាស់ ច្បាប់អតិផរណា ចក្ខុវិស័យ<br>**មាតិកា** :<br>**២.១- ការផ្លាស់ប្តូរមេដឹកនាំ**<br>ក. វិបត្តិនយោបាយ<br>ខ. វិបត្តិសេដ្ឋកិច្ច<br>គ. វិបត្តិសង្គម<br>សំណួរត្រិះរិះ :<br>• តើមានបុព្វហេតុអ្វីខ្លះដែលធ្វើឱ្យមានការផ្លាស់ប្តូរមេដឹកនាំនៅឆ្នាំ១៩៧០ ?<br>**២.២- ទម្រង់នៃការផ្លាស់ប្តូររបបនយោបាយ**<br>ក. និយមន័យរដ្ឋប្រហារ<br>ខ. រដ្ឋធម្មនុញ្ញ និងសេចក្តីសម្រេចរបស់សភា<br>សំណួរត្រិះរិះ :<br>• តើការទម្លាក់សម្តេចព្រះនរោត្តមសីហនុពីប្រមុខរដ្ឋអាចចាត់ទុកថាជារដ្ឋប្រហារដែរឬទេ ? ហេតុអ្វី ?<br>**២.៣- ការគ្រប់គ្រងរដ្ឋបែបសាធារណរដ្ឋ**<br>សំណួរត្រិះរិះ :<br>• តើការគ្រប់គ្រងរដ្ឋបែបសាធារណរដ្ឋរបស់កម្ពុជាមានលក្ខណៈបែបណា ?<br>**២.៤- ប្រជាជន និងសេដ្ឋកិច្ច**<br>ក. ការផ្លាស់ប្តូរ និងប្រតិកម្មប្រជាជន<br>ខ. អសន្តិសុខ និងសកម្មភាពសេដ្ឋកិច្ច<br>សំណួរត្រិះរិះ : | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីបុព្វហេតុដែលនាំឱ្យមានការផ្លាស់ប្តូរមេដឹកនាំនៅថ្ងៃទី១៨ មីនា ១៩៧០<br>- ពន្យល់ពីការផ្លាស់ប្តូររបបនយោបាយក្នុងបរិបទកម្ពុជាឆ្នាំ១៩៧០។<br>**បំណិនសម្បទា**<br>- វិភាគពីឥទ្ធិពលនៃចលនា និងស្ថានភាពប្រជាជនក្នុងរបបសាធារណរដ្ឋខ្មែរលើវិស័យសេដ្ឋកិច្ច<br>- វិភាគពីផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធលើវិស័យអប់រំ សេដ្ឋកិច្ច និងច្បាប់។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីចក្ខុវិស័យដឹកនាំប្រទេស។ | ៦ ម៉ |

| | | |
|---|---|---|
| • តើប្រជាជនមានប្រតិកម្មយ៉ាងដូចម្ដេចខ្លះចំពោះការផ្លាស់ប្ដូរមេដឹកនាំ និងរបបនយោបាយ?<br>• តើជម្លោះប្រដាប់អាវុធប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចយ៉ាងដូចម្ដេចខ្លះ?<br>**២.៥- សង្គ្រាម និងការអប់រំ**<br>សំណួរគ្រិះ :<br>• តើជម្លោះប្រដាប់អាវុធប៉ះពាល់យ៉ាងដូចម្ដេចខ្លះដល់វិស័យអប់រំ?<br>**២.៦- សង្គ្រាម និងការអនុវត្តច្បាប់**<br>សំណួរគ្រិះ :<br>• តើជម្លោះប្រដាប់អាវុធប៉ះពាល់យ៉ាងដូចម្ដេចខ្លះដល់ការអនុវត្តច្បាប់?<br>**២.៧- សាធារណរដ្ឋខ្មែរ និងចក្ខុវិស័យ**<br>សំណួរគ្រិះ :<br>• តើចក្ខុវិស័យរបស់មេដឹកនាំសម័យសាធារណរដ្ឋឆ្លើយតបនឹងស្ថានភាពកម្ពុជាដែរឬទេ? ព្រោះអ្វី?<br>សំណួរគ្រិះ :<br>• តើសន្តិភាពមានសារៈសំខាន់យ៉ាងដូចម្ដេចក្នុងការអភិវឌ្ឍប្រទេស? | | |
| **មេរៀនទី ៣ : កម្ពុជាប្រជាធិបតេយ្យ និងបដិវត្តន៍**<br>**សិក្សាបញ្ញត្តិ** : ការគ្រប់គ្រងរដ្ឋ ជីវភាពរស់នៅ បដិវត្តន៍ ប្រជាជនថ្មី ប្រជាជនចាស់ សហករណ៍ សមូហភាព ប្រល័យពូជសាសន៍ មនោគមវិជ្ជា ការជម្លៀស កំហឹងវណ្ណៈ អត្តសញ្ញាណ<br>**មាតិកា** :<br>**៣.១- ខ្មែរក្រហម និងការចូលកាន់អំណាច**<br>ក. ខ្មែរក្រហម និងការគ្រប់គ្រងរដ្ឋ<br>សំណួរគ្រិះ :<br>• តើខ្មែរក្រហមជានរណា?<br>• តើការគ្រប់គ្រងរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យអនុវត្តតាមលទ្ធិនយោបាយអ្វី និងមានលក្ខណៈបែបណា? | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីទម្រង់នៃការគ្រប់គ្រងរដ្ឋ និងអង្គការចាត់តាំងនៃរបបកម្ពុជាប្រជាធិបតេយ្យ<br>- ពន្យល់ពីនយោបាយគ្រប់គ្រងប្រជាជននិងសមូហភាពនិយមនៃរបបកម្ពុជាប្រជាធិបតេយ្យ<br>- ប្រាប់ពីមនោគមវិជ្ជាខ្មែរក្រហមតាមរយៈពាក្យស្លោក<br>- ពន្យល់ពីយុទ្ធសាស្ត្រអភិវឌ្ឍឿនសេដ្ឋកិច្ចជាតិរបស់ខ្មែរក្រហម។<br>**បំណិនសម្បទា**<br>- វិភាគពីមូលហេតុនៃការយកមនុស្សទៅ | ៨ ម៉ |

<table>
<tr>
<td>ខ. ការហៅឈ្មោះកម្ពុជាប្រជាធិបតេយ្យ<br>សំណួរត្រិះរិះ :<br>• តើប្រជាធិបតេយ្យក្នុងរបបខ្មែរក្រហមមានអត្ថន័យដូចម្ដេច?<br>គ. រចនាសម្ពន្ធ<br>សំណួរត្រិះរិះ :<br>• តើអង្គការចាត់តាំងនៃរបបកម្ពុជាប្រជាធិបតេយ្យមានរចនាសម្ពន្ធដូចម្ដេច?<br>ឃ. ទម្រង់នៃសហករណ៍ប្រមូលផ្ដុំ<br>សំណួរត្រិះរិះ :<br>• តើទម្រង់នៃសហករណ៍ប្រមូលផ្ដុំត្រូវបានគ្រប់គ្រងដោយរបៀបណា?<br>ង. ការដាក់ទិស និងឥទ្ធិពលលើប្រជាជន<br>សំណួរត្រិះរិះ :<br>• តើការដាក់ទិស និងស្នើរបស់អង្គការចាត់តាំងនៃរបបកម្ពុជាប្រជាធិបតេយ្យមានឥទ្ធិពលយ៉ាងដូចម្ដេចខ្លះលើប្រជាជន?<br>៣.២- ខ្មែរក្រហម និងបដិវត្តន៍ មហាលោតផ្លោះ មហាអស្ចារ្យ<br>ក. ការជម្លៀសប្រជាជនពីទីប្រជុំជន<br>ខ. ការបែងចែកប្រជាជនថ្មី និងប្រជាជនចាស់<br>គ. ការលុបបំបាត់កម្មសិទ្ធិឯកជន និងបង្កើតសហករណ៍<br>ឃ. ពីសញ្ញាបត្រទៅជាសញ្ញាឃើញ<br>ង. ខ្មែរក្រហម និងការផ្លាស់ប្ដូរគ្រប់វិស័យ<br>សំណួរត្រិះរិះ :<br>• តើរបបកម្ពុជាប្រជាធិបតេយ្យមានយុទ្ធសាស្ត្រអ្វីខ្លះដើម្បីដឹកនាំប្រទេស និងគ្រប់គ្រងប្រជាជន?<br>៣.៣- ពាក្យស្លោក និងទិដ្ឋភាពច្បាប់<br>សំណួរត្រិះរិះ :<br>• តើពាក្យស្លោកសម័យខ្មែរក្រហមបង្ហាញពីទិដ្ឋភាពច្បាប់យ៉ាងដូចម្ដេច?</td>
<td>កសាង ទៅរៀនសូត្រ បង្អត់អាហារ ទារុណកម្ម និងសម្លាប់<br>- វិភាគពីនយោបាយខ្មែរក្រហមលើវប្បធម៌ និងអត្តសញ្ញាណខ្មែរ ។<br>ចរិយាសម្បទា<br>- សន្និដ្ឋានពីផលប៉ះពាល់នៃការជម្លៀសប្រជាជន អំពើហិង្សា ការបំបាត់កម្មសិទ្ធិឯកជន និងការប្រល័យពូជសាសន៍របស់ខ្មែរក្រហមលើផ្លូវចិត្តរបស់ប្រជាជនខ្មែរ។</td>
<td></td>
</tr>
</table>

| | | |
|---|---|---|
| **៣.៤- ផែនការបួនឆ្នាំ និងការអភិវឌ្ឍសេដ្ឋកិច្ច**<br>ក. ផែនការបួនឆ្នាំ និងទិសដៅ<br>សំណួរត្រិះរិះ :<br>• តើផែនការបួនឆ្នាំនៃរបបកម្ពុជាប្រជាធិបតេយ្យមានទិសដៅយ៉ាងដូចម្ដេច?<br>ខ. ផែនការបួនឆ្នាំ និងយុទ្ធសាស្ត្រ<br>សំណួរត្រិះរិះ :<br>• ដើម្បីអនុវត្តផែនការបួនឆ្នាំ តើរបបកម្ពុជាប្រជាធិបតេយ្យបានប្រើយុទ្ធសាស្ត្រអ្វីខ្លះ<br>**៣.៥- ខ្មែរក្រហម និងការសម្រិតសម្រាំង**<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្ស?<br>**៣.៦- វប្បធម៌ និងអត្តសញ្ញាណខ្មែរ**<br>ក. ខ្មែរក្រហម និងការអភិរក្ស<br>សំណួរត្រិះរិះ :<br>• តើខ្មែរក្រហមរក្សាកេរមរតក ឬអត្តសញ្ញាណអ្វីខ្លះ ដែលបុព្វបុរសបានបន្សល់ទុក?<br>ខ. ខ្មែរក្រហម និងអត្តសញ្ញាណថ្មី<br>សំណួរត្រិះរិះ :<br>• តើខ្មែរក្រហមបង្កើតអត្តសញ្ញាណថ្មីអ្វីខ្លះ?<br>គ. អត្តសញ្ញាណ និងផលវិបាកក្នុងសង្គម<br>សំណួរត្រិះរិះ :<br>• តើការបង្កើតអត្តសញ្ញាណថ្មី ផ្ដល់ផលវិបាកអ្វីខ្លះដល់សង្គមខ្មែរ?<br>**៣.៧- របបកម្ពុជាប្រជាធិបតេយ្យ និងការដួលរលំ**<br>សំណួរត្រិះរិះ :<br>• តើសកម្មភាពដែលខ្មែរក្រហមបានប្រព្រឹត្តផ្ដល់លទ្ធផលយ៉ាងដូចម្ដេចខ្លះចំពោះប្រទេសជាតិ ប្រជាជន និងចំពោះខ្លួនឯង?<br>សំណួរត្រិះរិះ :<br>• តើការជម្លៀសប្រជាជន ពលកម្មដោយបង្ខំ និងការបំបាត់កម្មសិទ្ធិឯកជនផ្ដល់ផលវិបាកអ្វីខ្លះដល់ប្រជាជនខ្មែរក្នុងសម័យខ្មែរក្រហម និងរហូតមកដល់បច្ចុប្បន្ន? | | |

| | | |
|---|---|---|
| • តើការលុបបំបាត់សាលារៀន ប្រពៃណី និង ជំនឿក្នុងរបបកម្ពុជាប្រជាធិបតេយ្យបង្កផល វិបាកអ្វីខ្លះដល់សង្គមខ្មែរក្នុងសម័យខ្មែរ ក្រហម និងរហូតមកដល់បច្ចុប្បន្ន ? | | |
| **មេរៀនទី ៤ : សាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា**<br>**សិក្សាបញ្ញត្តិ** : រណសិរ្ស សង្គ្រោះជាតិ ការគ្រប់គ្រងរដ្ឋ គុណភាពជីវិត ជំនឿ ការអប់រំ សេរីភាព កម្មសិទ្ធិ ស្ថិរភាព ការលះបង់ ការចរចា<br>**មាតិកា** :<br>**៤.១- រណសិរ្សសាមគ្គីសង្គ្រោះជាតិ និងការរំដោះជាតិ**<br>ក. កំណើតរណសិរ្ស<br>ខ. ដំណើរការរំដោះជាតិ<br>សំណួរត្រិះរិះ :<br>• តើរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ទទួលជ័យជម្នះលើខ្មែរក្រហមដោយរបៀប ណា ?<br>**៤.២- ការគ្រប់គ្រងរដ្ឋ**<br>ក. សាធារណរដ្ឋប្រជាមានិតកម្ពុជា<br>ខ. រដ្ឋកម្ពុជា<br>សំណួរត្រិះរិះ :<br>• តើទម្រង់នៃការគ្រប់គ្រងរដ្ឋតាមបែបសង្គម និយម និងបែបសាធារណរដ្ឋប្រជាមានិត កម្ពុជាមានលក្ខណៈស្រដៀងគ្នា និងផ្សេង គ្នាយ៉ាងដូចម្តេចខ្លះ ?<br>**៤.៣- ការកសាងជាតិឆ្ពោះទៅរកកំណែទម្រង់**<br>ក. ពីការដោះដូរ ទៅជាការលក់ដូរ<br>សំណួរត្រិះរិះ :<br>• តើការផ្លាស់ប្តូរពីការដោះដូរ ទៅការលក់ដូរ ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ ផ្តល់លទ្ធផល វិជ្ជមានដូចម្តេចខ្លះចំពោះប្រជាជនខ្មែរ ?<br>ខ. ពីកម្មសិទ្ធិរដ្ឋ ទៅកម្មសិទ្ធិឯកជន<br>សំណួរត្រិះរិះ : | **វិជ្ជាសម្បទា**<br>- ពន្យល់ពីដំណើរឈានទៅរកជ័យជម្នះក្នុង ការផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបពីទម្រង់គ្រប់គ្រងរដ្ឋបែបសង្គម និយមក្នុងសម័យរបបសាធារណរដ្ឋ ប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា<br>- ចង្អុលបង្ហាញពីការផ្លាស់ប្តូរសង្គម សេដ្ឋកិច្ច កម្ពុជាដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ ប្រជាជនខ្មែរ<br>- វិភាគពីយុទ្ធសាស្ត្រទប់ស្កាត់ការវិលត្រឡប់ របស់ខ្មែរក្រហមមកកាន់អំណាចវិញ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីការលះបង់របស់ភាគីទាំង៤ ក្នុងការស្វែងរកសន្តិភាពនៅកម្ពុជា។ | ៨ ម៉ |

| | | |
|---|---|---|
| • តើការផ្តល់កម្មសិទ្ធិឯកជនផ្តល់លទ្ធផលវិជ្ជមានដូចម្តេចខ្លះចំពោះប្រជាជនខ្មែរ?<br>គ. ពីការរឹតបន្តឹងសេរីភាពទៅការបើកទូលាយ<br>សំណួរត្រិះរិះ :<br>• តើការផ្តល់សេរីភាពជំនឿ និងទំនាក់ទំនងផ្តល់លទ្ធផលវិជ្ជមានដូចម្តេចខ្លះចំពោះប្រជាជនខ្មែរ?<br>ឃ. ពីសាលាស្លឹក ទៅជាសាលាក្បឿង<br>សំណួរត្រិះរិះ :<br>• ការអភិវឌ្ឍក្នុងវិស័យអប់រំផ្តល់ប្រយោជន៍អ្វីខ្លះដល់ប្រជាជន និងសង្គមជាតិ?<br>**៤.៤- ការទប់ស្កាត់ការវិលត្រឡប់របស់ខ្មែរក្រហម**<br>ក. យុទ្ធសាស្ត្រក្នុងការទប់ស្កាត់<br>សំណួរត្រិះរិះ :<br>• តើរដ្ឋាភិបាលទីក្រុងភ្នំពេញប្រើយុទ្ធសាស្ត្រអ្វីខ្លះក្នុងការទប់ស្កាត់ការវិលត្រឡប់របស់ខ្មែរក្រហម?<br>ខ. ប្រជាជន និងការចូលរួម<br>សំណួរត្រិះរិះ :<br>• តើប្រជាជនចូលរួមក្នុងការទប់ស្កាត់ការវិលត្រឡប់របស់ខ្មែរក្រហមដោយរបៀបណា?<br>**៤.៥- ការលះបង់ និងការបង្រួបបង្រួមជាតិ**<br>ក. ភាគីទាំងបួន និងការលះបង់<br>សំណួរត្រិះរិះ :<br>• តើភាគីទាំងបួនបានលះបង់អ្វីខ្លះដើម្បីសន្តិភាព និងការបង្រួបបង្រួមជាតិ?<br>ខ. មូលហេតុ និងការចូលតុចរចា<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាភាគីទាំងបួនសុខចិត្តចូលតុចរចា? | | |

| | | |
|---|---|---|
| **មេរៀនទី៥ : ព្រះរាជាណាចក្រទី២ និងស្ថិរភាព**<br>**សិក្សាបញ្ញត្តិ** : ការគ្រប់គ្រងរដ្ឋ ទីផ្សារសេរី ស្ថិរភាព សមាហរណកម្ម ការបង្រួបបង្រួមជាតិ ច្បាប់ យុត្តិធម៌ សន្តិភាព អភិវឌ្ឍន៍ ការចូលរួម សង្គមស៊ីវិល<br>**មាតិកា** :<br>**៥.១- កម្ពុជា និងរបបនយោបាយថ្មី**<br>សំណួរត្រិះរិះ :<br>• តើក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៣ កម្ពុជាបានប្រកាន់យករបបនយោបាយអ្វី និងមានលក្ខណៈបែបណា?<br>**៥.២- កម្ពុជា និងមាគ៌ាឆ្ពោះទៅរកស្ថិរភាព នយោបាយ**<br>ក. វិសោធនកម្មរដ្ឋធម្មនុញ្ញ<br>ខ. នីតិរដ្ឋ និងស្ថិរភាពនយោបាយ<br>គ. សមាហរណកម្មក្រុមខ្មែរក្រហម<br>ឃ. រដ្ឋាភិបាលសហនាយករដ្ឋមន្ត្រី<br>សំណួរត្រិះរិះ :<br>• តើកម្ពុជាមានយុទ្ធសាស្ត្រអ្វីខ្លះដើម្បីរក្សា ស្ថិរភាពនយោបាយ?<br>**៥.៣- កម្ពុជា និងមាគ៌ាឆ្ពោះទៅរកការអភិវឌ្ឍ**<br>ក. ការអប់រំ និងចីរភាពអភិវឌ្ឍ<br>ខ. សេដ្ឋកិច្ច និងទីផ្សារសេរី<br>គ. ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល<br>សំណួរត្រិះរិះ :<br>• តើកម្ពុជាមានយុទ្ធសាស្ត្រអ្វីខ្លះដើម្បីអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ច? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការផ្លាស់ប្តូរទម្រង់នយោបាយ និង ការគ្រប់គ្រងរដ្ឋក្រោយការបោះឆ្នោត១៩៩៣<br>- ពន្យល់ពីដំណើរការធានាឱ្យមាន សមាហរណកម្មក្រុមខ្មែរក្រហម និងស្ថិរភាព នយោបាយ<br>- រៀបរាប់ពីការផ្លាស់ប្តូរទម្រង់សេដ្ឋកិច្ចពី សេដ្ឋកិច្ចផែនការមកសេដ្ឋកិច្ចទីផ្សារសេរី ក្រោយការបោះឆ្នោត១៩៩៣<br>- រៀបរាប់ពីការចូលរួមរបស់ប្រជាពលរដ្ឋ និង សង្គមស៊ីវិល ក្នុងការលើកកម្ពស់ការអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ច<br>- រៀបរាប់ពីវឌ្ឍនភាពក្នុងវិស័យអប់រំ និង បណ្តុះបណ្តាលក្នុងទសវត្សរ៍១៩៩០។<br>**បំណិនសម្បទា**<br>- ជ្រើសរើសវិធីបង្រួបបង្រួមជាតិដែលបានប្រើ ក្រោយជាប់គាំងនយោបាយ១៩៩៣ និង ១៩៩៨<br>- វិភាគពីវិបត្តិនៃការបែកបាក់ការដឹកនាំរដ្ឋបែប សហនាយករដ្ឋមន្ត្រី។<br>**ចរិយាសម្បទា**<br>- វិនិច្ឆ័យពីវឌ្ឍនភាពនៃការអនុវត្តច្បាប់ តាម រដ្ឋធម្មនុញ្ញ១៩៩៣។ | ៥ ម៉ |
| **ជំពូកទី ២ : ប្រវត្តិសាស្ត្រតំបន់ "ពាណិជ្ជកម្ម និងបម្រែបម្រួលសង្គម និងសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ (សតវត្សរ៍ទី១៥-១៨)"** | | |
| **មេរៀនទី១: វប្បធម៌ថ្មី និងពាណិជ្ជកម្មអឺរ៉ុប**<br>**សិក្សាបញ្ញត្តិ** : គោលនយោបាយ ពាណិជ្ជកម្ម គ្រឿងទេស សព្វាវុធ ទំនិញ ទាហានស៊ីឈ្នួល ឈ្មួញចិន ឈ្មួញព័រទុយហ្គាល់ ឈ្មួញ ហូឡង់ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃគោលនយោបាយជំនួញ របស់ចិន ព័រទុយហ្គាល់ ហូឡង់ និង អង់គ្លេសមកលើតំបន់អាស៊ីអាគ្នេយ៍។ | ៥ ម៉ |

| | | |
|---|---|---|
| ក្រុមហ៊ុនឥណ្ឌាខាងកើត ឈ្មួញអង់គ្លេស<br>**មាតិកា**:<br>**១.១- គោលនយោបាយពាណិជ្ជកម្មចិន**<br>សំណួរត្រិះរិះ :<br>• តើចិនមានគោលនយោបាយជំនួញដូចម្តេចចំពោះអាស៊ីអាគ្នេយ៍ ?<br>**១.២- ពាណិជ្ជកម្មចិន និងអាស៊ីអាគ្នេយ៍**<br>សំណួរត្រិះរិះ :<br>• តើសកម្មភាពជំនួញអន្តរសកម្មរវាងចិននិងអាស៊ីអាគ្នេយ៍មានលក្ខណៈដូចម្តេច ?<br>**១.៣- គោលការណ៍ពាណិជ្ជកម្មរបស់ព័រទុយហ្គាល់**<br>សំណួរត្រិះរិះ :<br>• តើព័រទុយហ្គាល់អនុវត្តគោលការណ៍អ្វីខ្លះដើម្បីគ្រប់គ្រងពាណិជ្ជកម្មគ្រឿងទេសនៅអាស៊ីអាគ្នេយ៍ ?<br>**១.៤- គោលនយោបាយពាណិជ្ជកម្មហូឡង់**<br>សំណួរត្រិះរិះ :<br>• តើហូឡង់អនុវត្តគោលការណ៍ពាណិជ្ជកម្មអ្វីខ្លះនៅអាស៊ីអាគ្នេយ៍ ?<br>**១.៥- គោលនយោបាយជំនួញអង់គ្លេស**<br>សំណួរត្រិះរិ :<br>• តើអង់គ្លេសមានគោលនយោបាយជំនួញដូចម្តេចនៅអាស៊ីអាគ្នេយ៍ ?<br>**១.៦- សាសនា និងជម្រើសរបស់ប្រជាជនអាស៊ីអាគ្នេយ៍**<br>សំណួរត្រិះរិះ :<br>• តើប្រជាជនអាស៊ីអាគ្នេយ៍មានការប្រែប្រួលសេដ្ឋកិច្ចនិងសាសនាដូចម្តេចដោយសារអន្តរសកម្មខាងជំនួញអន្តរជាតិ ? | **បំណិនសម្បទា**<br>- វិនិច្ឆ័យមូលហេតុនៃការពង្រីកអំណាច និងឥទ្ធិពលជំនួញចិន ព័រទុយហ្គាល់ ហូឡង់ និងអង់គ្លេសនៅអាស៊ីអាគ្នេយ៍<br>- វាយតម្លៃការចូលរួមរបស់អ្នកស្រុកអាយក្នុងសកម្មភាពជំនួញជាមួយពួកអឺរ៉ុប និងមូស្លីម និងឥទ្ធិពលអឺរ៉ុប និងមូស្លីម។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីផលប្រយោជន៍នៃអន្តរទំនាក់ទំនងខាងជំនួញជាមួយបរទេសរបស់មនុស្សនៅក្នុងតំបន់<br>- ផ្តល់ការពន្យល់ស្តីពីសារៈសំខាន់ចាំបាច់ខាងជំនួញជាមួយបរទេស ដើម្បីការអភិវឌ្ឍក្នុងប្រទេស។ | |
| **មេរៀនទី២: អាស៊ីអាគ្នេយ៍ និងពាណិជ្ជកម្មចិន**<br>**សិក្សាបញ្ញត្តិ**: ម៉ាឡាកា កំពង់ផែកណ្តាល សហគមន៍ ពាណិជ្ជកម្ម អណ្តូងរ៉ែ ឥណ្ឌូណេស៊ី សំណាបាហាំងភូមា ឈើ សំណង់ អយុធ្យា | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃគោលនយោបាយជំនួញរបស់ចិនមកលើតំបន់អាស៊ីអាគ្នេយ៍។<br>**បំណិនសម្បទា** | ៥ ម៉ |

| | | |
|---|---|---|
| **មាតិកា**:<br>**២.១- កំពង់ផែកណ្ដាលម៉ាឡាកា និងចិន**<br>សំណួរត្រិះរិះ :<br>• តើកំពង់ផែម៉ាឡាកាមានសកម្មភាព និងផលប្រយោជន៍ដូចម្ដេចខ្លះ បន្ទាប់ពីចិនទទួលស្គាល់ជាកំពង់ផែកណ្ដាលនៃអាស៊ីអាគ្នេយ៍នៅឆ្នាំ១៤០៤?<br>**២.២- ពាណិជ្ជកម្មចិននៅជ្រោយម៉ាឡាយូ**<br>សំណួរត្រិះរិះ :<br>• តើពាណិជ្ជកម្មចិននៅជ្រោយម៉ាឡាយូធ្វើឱ្យសេដ្ឋកិច្ចសង្គមនៃប្រទេសនេះមានការប្រែប្រួលដូចម្ដេច?<br>**២.៣- ពាណិជ្ជកម្មចិននៅភូមា**<br>សំណួរត្រិះរិះ :<br>• តើពាណិជ្ជកម្មចិនជាមួយភូមាមានលក្ខណៈដូចម្ដេច?<br>**២.៤- ពាណិជ្ជកម្មចិននៅអយុធ្យា**<br>សំណួរត្រិះរិះ :<br>• តើពាណិជ្ជកម្មចិននៅអយុធ្យាបាននាំឱ្យមានការប្រែប្រួល នយោបាយ សេដ្ឋកិច្ច និងសង្គមដូចម្ដេចខ្លះ?<br>**២.៥- ពាណិកម្មចិននៅឥណ្ឌូណេស៊ី**<br>សំណួរត្រិះរិះ :<br>• តើពាណិជ្ជកម្មចិននៅឥណ្ឌូណេស៊ីបានផ្ដល់ឥទ្ធិពល និងការប្រែប្រួលនយោបាយ សេដ្ឋកិច្ច និងសង្គមដូចម្ដេចខ្លះ? | - វិនិច្ឆ័យមូលហេតុនៃការពង្រីកអំណាច និងឥទ្ធិពលជំនួញចិននៅអាស៊ីអាគ្នេយ៍<br>- វាយតម្លៃការចូលរួមរបស់អ្នកស្រុកអាយក្នុងសកម្មភាពជំនួញជាមួយពួកឈ្មួញចិន។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីផលប្រយោជន៍នៃអន្តរទំនាក់ទំនងខាងជំនួញរបស់ប្រជាជនក្នុងតំបន់ជាមួយចិន | |
| **មេរៀនទី៣ : អាស៊ីអាគ្នេយ៍ និងពាណិជ្ជកម្មព័រទុយហ្គាល់**<br>**សិក្សាបញ្ញត្តិ** : សព្វាវុធ ពាណិជ្ជកម្ម គ្រឿងទេស ទំនិញ ទាហានស៊ីឈ្នួល ឈ្មួញព័រទុយហ្គាល់ កោះគ្រឿងទេស សង្គ្រាម សង្គ្រាមឈ្លានពាន ការប្រកួតប្រជែង សន្ធិសញ្ញា កិច្ចព្រមព្រៀង<br>**មាតិកា**:<br>**៣.១- ព័រទុយហ្គាល់នៅម៉ាឡាយ៉ា** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃគោលនយោបាយជំនួញរបស់ព័រទុយហ្គាល់មកលើតំបន់អាស៊ីអាគ្នេយ៍។<br>**បំណិនសម្បទា**<br>- វិនិច្ឆ័យមូលហេតុនៃការពង្រីកអំណាច និងឥទ្ធិពលជំនួញព័រទុយហ្គាល់នៅអាស៊ីអាគ្នេយ៍ | ៥ ម៉ |

| | | |
|---|---|---|
| សំណួរត្រិះរិះ :<br>• តើក្នុងហេតុផលអ្វីខ្លះទើបព័រទុយហ្គាល់ជំរុញការកាន់កាប់កំពង់ផែម៉ាឡាកា?<br>**៣.២- ព័រទុយហ្គាល់ និងឥណ្ឌូណេស៊ី**<br>សំណួរត្រិះរិះ :<br>• តើឥទ្ធិពលពាណិជ្ជកម្មព័រទុយហ្គាល់នៅឥណ្ឌូណេស៊ីមានលក្ខណៈដូចម្តេច?<br>**៣.៣- ព័រទុយហ្គាល់ និងភូមា**<br>សំណួរត្រិះរិះ :<br>• តើឥទ្ធិពលពាណិជ្ជកម្មព័រទុយហ្គាល់ទៅលើភូមាមានលក្ខណៈដូចម្តេច?<br>**៣.៤- ព័រទុយហ្គាល់ និងអយុធ្យា**<br>សំណួរត្រិះរិះ :<br>• តើឥទ្ធិពលពាណិជ្ជកម្មព័រទុយហ្គាល់នៅអយុធ្យាមានស្ថានភាពដូចម្តេច? | - វាយតម្លៃការចូលរួមរបស់អ្នកស្រុកអាយក្នុងសកម្មភាពជំនួញជាមួយពួកឈ្មួញព័រទុយហ្គាល់ និងការឱ្យតម្លៃពួកទាហានស៊ីឈ្នួលព័រទុយហ្គាល់ដោយស្តេចអាស៊ីអាគ្នេយ៍ដីគោក។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីផលប្រយោជន៍នៃអន្តរទំនាក់ទំនងខាងជំនួញជាមួយព័រទុយហ្គាល់របស់មនុស្សក្នុងតំបន់ និងការឱ្យតម្លៃពួកទាហានស៊ីឈ្នួល និងសព្វាវុធរបស់ព័រទុយហ្គាល់។ | |
| **មេរៀនទី៤ : អាស៊ីអាគ្នេយ៍ និងពាណិជ្ជកម្មហូឡង់ និងអង់គ្លេស**<br>**សិក្សាបញ្ញត្តិ**: ជំនួញ ហូឡង់ ក្រុមហ៊ុនឥណ្ឌាខាងកើត ការប្រកួតប្រជែង សង្គ្រាម មជ្ឈមណ្ឌលពាណិជ្ជកម្ម ប៉ាតាយ៉ា សន្ធិសញ្ញា១៧៩៥ រ៉ែត្បូង<br>**មាតិកា**:<br>**៤.១- ពាណិជ្ជកម្មហូឡង់នៅឥណ្ឌូណេស៊ី**<br>សំណួរត្រិះរិះ :<br>• តើឥទ្ធិពលពាណិជ្ជកម្មរបស់ហូឡង់ នៅឥណ្ឌូណេស៊ី បានធ្វើឱ្យនយោបាយសេដ្ឋកិច្ច និងសង្គមប្រែប្រួលដូចម្តេចខ្លះ?<br>**៤.២- ពាណិជ្ជកម្មហូឡង់ និងអង់គ្លេសនៅអយុធ្យា**<br>សំណួរត្រិះរិះ :<br>• តើឥទ្ធិពលពាណិជ្ជកម្មហូឡង់ និងអង់គ្លេសនៅអយុធ្យាមានលក្ខណៈយ៉ាងដូចម្តេច?<br>**៤.៣- ពាណិជ្ជកម្មហូឡង់នៅកម្ពុជា**<br>សំណួរត្រិះរិះ : | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃគោលនយោបាយជំនួញរបស់ហូឡង់ និងអង់គ្លេសមកលើតំបន់អាស៊ីអាគ្នេយ៍។<br>**បំណិនសម្បទា**<br>- វិនិច្ឆ័យមូលហេតុនៃការពង្រីកអំណាច និងឥទ្ធិពលជំនួញហូឡង់ និងអង់គ្លេសនៅអាស៊ីអាគ្នេយ៍<br>- វិភាគពីការចូលរួមរបស់អ្នកស្រុកអាយក្នុងសកម្មភាពជំនួញជាមួយពួកឈ្មួញហូឡង់ និងអង់គ្លេស និងការឱ្យតម្លៃចំពោះពួកអឺរ៉ុបដោយព្រះរាជានៅអាស៊ីអាគ្នេយ៍។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីផលប្រយោជន៍នៃអន្តរទំនាក់ទំនងខាងជំនួញជាមួយហូឡង់ និងអង់គ្លេសរបស់មនុស្សក្នុងតំបន់ និងការប្រកួតប្រជែងគ្នាជាលក្ខណៈអន្តរជាតិ | ៥ ម៉ |

<table>
<tr>
<td>

- តើឥទ្ធិពលពាណិជ្ជកម្មហូឡង់នៅកម្ពុជាមានស្ថានភាពដូចម្ដេច ក្នុងការប្រកួតប្រជែងជាមួយពួកមូស្លីម?

**៤.៤- ពាណិជ្ជកម្មហូឡង់នៅវៀតណាម?**<br>
សំណួរត្រិះរិះ :

- តើឥទ្ធិពលពាណិជ្ជកម្មហូឡង់នៅវៀតណាមមានលក្ខណៈដូចម្ដេច?

**៤.៥- ពាណិជ្ជកម្មអង់គ្លេសនៅភូមា**<br>
សំណួរត្រិះរិះ :

- តើឥទ្ធិពលពាណិជ្ជកម្មអង់គ្លេសនៅភូមាមានស្ថានភាពដូចម្ដេច?

</td>
<td></td>
<td></td>
</tr>
<tr>
<td colspan="3">ជំពូកទី៣ : ប្រវត្តិសាស្ត្រពិភពលោក និងអរិយធម៌ "បដិវត្តន៍ឧស្សាហកម្ម និងចក្រពត្តិនិយម"</td>
</tr>
<tr>
<td>

**មេរៀនទី១ : ការរីកចម្រើននៅអឺរ៉ុប និងឱនភាពនៅអាស៊ី**<br>
**សិក្សាបញ្ញត្តិ** : បដិវត្តន៍ឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកទេស របកគំហើញ ម៉ាស៊ីន ថាមពល បម្រែបម្រួលសង្គម ទីផ្សារ អាណានិគម វេជ្ជសាស្ត្រ ម៉ាស៊ីនចំហាយទឹក ម៉ាស៊ីនផ្ទុះ ឱនភាព<br>
**មាតិកា**:<br>
**១.១- ការរីកចម្រើននៅអឺរ៉ុប**<br>
ក. ការរីកចម្រើនខាងវិទ្យាសាស្ត្រ<br>
សំណួរត្រិះរិះ :

- ការរីកចម្រើនខាងវិទ្យាសាស្ត្រ និងបច្ចេកទេសបានធ្វើឱ្យមានការផ្លាស់ប្ដូរមុខមាត់សង្គមមនុស្សយ៉ាងដូចម្ដេចខ្លះ ?

ខ. របកគំហើញ និងការប្រើប្រាស់ម៉ាស៊ីន

- របកគំហើញម៉ាស៊ីន
- របកគំហើញថាមពលថ្មី
- ការវិវត្តន៍នៃម៉ាស៊ីន
- ម៉ាស៊ីន និងកសិកម្ម
- ម៉ាស៊ីន និងការដឹកជញ្ជូន
- ម៉ាស៊ីន និងមធ្យោបាយទាក់ទងគ្នា
- ម៉ាស៊ីន និងចង្វាក់ផលិតកម្ម

</td>
<td>

**វិជ្ជាសម្បទា**

- ពិពណ៌នាពីដំណើរការរីកចម្រើននៃវិទ្យាសាស្ត្រ បច្ចេកទេស និងគំនិតច្នៃប្រឌិតនៅអឺរ៉ុប
- ប្រាប់ពីឱនភាពនៅអាស៊ីចំពោះវត្តមានមហាអំណាចអាណានិគម។

**បំណិនសម្បទា**

- វិភាគផលវិជ្ជមាន និងអវិជ្ជមាននៃបដិវត្តឧស្សាហកម្ម និងបច្ចេកទេសចំពោះពិភពលោក ពិសេសទ្វីបអាស៊ី
- វិភាគស្ថានភាពទូទៅនៃសេដ្ឋកិច្ចនយោបាយនៅអាស៊ី ។

**ចរិយាសម្បទា**

- សន្និដ្ឋានរួមពីតួនាទីរបស់វិទ្យាសាស្ត្រ និងបច្ចេកទេស ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្ម

</td>
<td>៣ ម៉</td>
</tr>
</table>

| | | |
|---|---|---|
| • ម៉ាស៊ីន និងសង្គមមនុស្ស<br>សំណួរត្រិះរិះ:<br>• តើអ្នកវិទ្យាសាស្ត្របានបង្កើតម៉ាស៊ីន និងរកឃើញថាមពលអ្វីខ្លះ ?<br>• តើរបកគំហើញ និងការវិវត្តខាងម៉ាស៊ីនធ្វើឱ្យមានការផ្លាស់ប្តូរ យ៉ាងដូចម្តេចខ្លះទៅលើកសិកម្ម ការដឹកជញ្ជូន មធ្យោបាយទាក់ទងគ្នា ចង្វាក់ផលិតកម្ម និងសង្គមមនុស្ស ?<br>• របកគំហើញថាមពលបានជះឥទ្ធិពលយ៉ាងដូចម្តេចទៅលើ រោងចក្រឧស្សាហកម្ម ការដឹកជញ្ជូន និងជីវភាពរស់នៅរបស់មនុស្ស ?<br>គ. ផលប៉ះពាល់នៃបដិវត្តន៍ឧស្សាហកម្ម<br>សំណួរត្រិះរិះ:<br>• តើបដិវត្តន៍ឧស្សាហកម្មនិងបច្ចេកទេសបានផ្តល់នូវផលវិជ្ជមាន និងផលអវិជ្ជមានដូចម្តេចខ្លះ ទៅលើប្រជាជាតិនានាលើពិភពលោក ?<br>ឃ. ចូរត្រិះរិះ<br>សំណួរត្រិះរិះ:<br>• តើការរីកចម្រើនខាងវិទ្យាសាស្ត្រ និងបច្ចេកទេសពិតជាផ្តល់ប្រយោជន៍ឱ្យសង្គមមនុស្សឬយ៉ាងណា ?<br>**១.២- ឧិនភាពនៅអាស៊ី**<br>ក. នយោបាយ និងសេដ្ឋកិច្ចមុនការមកដល់របស់អឺរ៉ុប<br>សំណួរត្រិះរិះ:<br>• តើនយោបាយ និងសេដ្ឋកិច្ចនៅទ្វីបអាស៊ីស្ថិតក្នុងស្ថានភាពបែបណាមុនការមកដល់នៃពួកអឺរ៉ុប ?<br>ខ. នយោបាយ សង្គម និងសេដ្ឋកិច្ចអាស៊ីចំពោះវត្តមានអឺរ៉ុប<br>សំណួរត្រិះរិះ:<br>• តើនយោបាយ សង្គម និងសេដ្ឋកិច្ចនៅអាស៊ីមានបម្រែបម្រួលយ៉ាងដូចម្តេចខ្លះ | | |

| | | |
|---|---|---|
| ក្រោយការមកដល់នៃពួកអឺរ៉ុប ? | | |
| **មេរៀនទី២ : ការប្រជែងអំណាចនៃចក្រពត្តិនិយម នៅប្រទេសចិន**<br>**សិក្សាបញ្ញត្តិ** : ការប្រជែងអំណាច សន្ធិសញ្ញា ជំងឺអាភៀន អាណានិគម វត្ថុធាតុដើម ទីផ្សារ មាគ៌ានយោបាយ<br>**មាតិកា**:<br>**២.១- ប្រទេសចិនមុនអឺរ៉ុបចូលមកដល់**<br>សំណួរត្រិះរិះ:<br>• តើនយោបាយ សង្គម និងសេដ្ឋកិច្ចចិនមានស្ថានភាពដូចម្ដេច មុនមកដល់នៃពួកអឺរ៉ុប ?<br>**២.២- ចិនក្នុងពេលអឺរ៉ុបមកដល់**<br>ក. សង្គ្រាមអាភៀនលើកទី១ និងសន្ធិសញ្ញាណានជីន<br>ខ. ជំងឺអាភៀន<br>គ. សង្គ្រាមអាភៀនលើកទី២<br>សំណួរត្រិះរិះ :<br>• តើសង្គ្រាមអាភៀនជាអ្វី?  បង្កដោយប្រទេសណា ? ផ្ដល់នូវផលវិបាកអ្វីខ្លះចំពោះប្រទេសចិន ?<br>**២.៣- ការបែងចែកទឹកដីចិន ពីសំណាក់មហាអំណាច**<br>សំណួរត្រិះរិះ :<br>• តើមហាអំណាចណាខ្លះដែលបែងចែកទឹកដីចិននាចុងសតវត្សរ៍ទី១៩ ?<br>• ហេតុអ្វីបានជាមហាអំណាចធ្វើការបែងចែកទឹកដីចិនដើម្បីគ្រប់គ្រង ?<br>**២.៤- មាគ៌ាចិននៅដើមសតវត្សរ៍ទី២០**<br>សំណួរត្រិះរិះ :<br>• តើនៅដើមសតវត្សរ៍ទី២០ មានការលេចឡើងនូវលទ្ធិអ្វីខ្លះដែលបានផ្លាស់ប្ដូរផ្នត់គំនិតប្រជាជនចិន ? | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីស្ថានភាពសង្គម មុនពេល និងក្នុងពេលពួកអឺរ៉ុបចូលមកដល់ និងជំងឺអាភៀន<br>- ប្រាប់ពីមាគ៌ារបស់ចិនក្នុងដើមសតវត្សរ៍ទី២០ និងចម្បាំងរវាងចិន និងជប៉ុនក្នុងការត្រួតត្រាប្រទេសចិន<br>- ប្រាប់ពីការបែងចែកទឹកដីចិនពីសំណាក់ពួកចក្រពត្តិ ។<br>**បំណិនសម្បទា**<br>- វិភាគពីមូលហេតុនៃសង្គ្រាមអាភៀន និងផលប៉ះពាល់ក្នុងសង្គមចិន<br>- វិភាគពីមូលហេតុដែលបណ្ដាលឱ្យមហាអំណាចធ្វើការបែងចែកទឹកដីចិន ។<br>**ចរិយាសម្បទា**<br>- ចូលរួមទប់ស្កាត់ និងចៀសវាងការប្រើប្រាស់អាភៀន និងគ្រឿងញៀនគ្រប់ប្រភេទ ។ | ៤ ម៉ |

| | | |
|---|---|---|
| **មេរៀនទី៣ : ឥណ្ឌា និងអំណាចរបស់អង់គ្លេស**<br>**សិក្សាបញ្ញត្តិ** : អាណានិគម ក្រុមហ៊ុនឥណ្ឌាខាងកើត ទីផ្សារ វត្ថុធាតុដើម (មាសខ្មៅត្បូងថ្ម)<br>**មាតិកា**:<br>**៣.១- ឥណ្ឌាមុនការមកដល់នៃមអង់គ្លេស**<br>សំណួរត្រិះរិះ :<br>• តើនយោបាយ សេដ្ឋកិច្ច និងសង្គមឥណ្ឌាមានស្ថានភាពដូចម្តេច មុនការមកដល់របស់អង់គ្លេស?<br>**៣.២- ឥណ្ឌាក្នុងពេលមកដល់នៃអង់គ្លេស**<br>ក. តួនាទីរបស់ក្រុមហ៊ុនឥណ្ឌាខាងកើត<br>ខ. ការទទួលយកអាណានិគមអង់គ្លេស<br>សំណួរត្រិះរិះ :<br>• តើក្រុមហ៊ុនឥណ្ឌាខាងកើតមានតួនាទីយ៉ាងដូចម្តេចខ្លះក្នុងប្រទេសឥណ្ឌា?<br>• ហេតុអ្វីបានជាប្រទេសឥណ្ឌាធ្លាក់ក្រោមអាណានិគមអង់គ្លេស?<br>**៣.៣- បម្រែបម្រួលសង្គម និងនយោបាយឥណ្ឌាមុនសង្គ្រាមលោកលើកទី១**<br>ក. ប្រពន្ធ័ច្បាប់ឥណ្ឌា<br>ខ. ប្រពន្ធ័រដ្ឋបាល<br>គ. សេដ្ឋកិច្ច<br>ឃ. នយោបាយ<br>សំណួរត្រិះរិះ :<br>• តើវត្តមានអង់គ្លេសបានផ្លាស់ប្តូរប្រព័ន្ធច្បាប់ រដ្ឋបាល សេដ្ឋកិច្ច នយោបាយនៅឥណ្ឌាយ៉ាងដូចម្តេចខ្លះ ? | **វិជ្ជាសម្បទា**<br>- អធិប្បាយពីសង្គមឥណ្ឌាមុនការមកដល់នៃអាណានិគមអង់គ្លេស ។<br>**បំណិនសម្បទា**<br>- វិភាគពីតួនាទីរបស់ក្រុមហ៊ុនឥណ្ឌាខាងកើត និងការដាក់អាណានិគមរបស់អង់គ្លេសទៅលើឥណ្ឌា ។<br>**ចរិយាសម្បទា**<br>- វិនិច្ឆ័យពីការចូលរួមកសាងសង្គមឱ្យក្លាយជានីតិរដ្ឋ ។ | ៤ ម៉ |
| **មេរៀនទី៤ : អំណាចរបស់ជប៉ុននៅចិន និងកូរ៉េ**<br>**សិក្សាបញ្ញត្តិ** : អាណានិគម យោធនិយម កំណែទម្រង់ ម៉ីអ៊ីយិ សង្គ្រាមកាន់កាប់ទឹកដី សន្ធិសញ្ញា<br>**មាតិកា**:<br>**៤.១- ជប៉ុន និងការពង្រីកអំណាច**<br>ក. កំណែទម្រង់ម៉ីអ៊ីយិ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីកំណែទម្រង់ម៉ីអ៊ីយិ និងផលវិបាកនៃកំណែទម្រង់ ។<br>**បំណិនសម្បទា**<br>- វិភាគពីអំណាចរបស់ជប៉ុននៅអាស៊ី។ | ៤ ម៉ |

| | | |
|---|---|---|
| ខ. ចក្រពត្តិជប៉ុន និងអាស៊ី<br>សំណួរត្រិះរិះ :<br>• តើជប៉ុនធ្វើកំណែទម្រង់អ្វីខ្លះដើម្បីឈានទៅរកការរីកចម្រើនដូចបស្ចិមប្រទេស ?<br>• តើកត្តាអ្វីខ្លះបានធ្វើឱ្យជប៉ុនក្លាយជាមហាអំណាចនៅអាស៊ី ?<br>**៤.២- អំណាចរបស់ជប៉ុននៅចិន និងកូរ៉េ**<br>សំណួរត្រិះរិះ:<br>• តើជប៉ុនបានប្រើវិធី និងមធ្យោបាយអ្វីខ្លះដើម្បីពង្រីកអំណាចនៅចិន ?<br>• តើជប៉ុនបានប្រើវិធី និងមធ្យោបាយអ្វីខ្លះដើម្បីពង្រីកអំណាចនៅកូរ៉េ ? | **ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីការឯកភាពជាតិ និងសុខដុមភាពក្នុងសង្គម។ | |

## ៨- សន្ទានុក្រម

**កម្មន្តបំណិន**

សំដៅដល់កញ្ចប់សមត្ថភាពសម្រាប់បម្រើការងារ និងរួមចំណែកដល់ភាពជោគជ័យរបស់បុគ្គល និងស្ថាប័ន

**គុណសម្បទា**

សំដៅដល់គុណសម្បទាក៏ជាកញ្ចប់សមត្ថភាពដែលសិស្សត្រូវទទួលបានក្រោយពេលបញ្ចប់ភូមិសិក្សានីមួយៗ ដែលរួមមាន វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។

**បុច្ឆនសិក្សា**

សំដៅដល់កញ្ចប់បំណិនក្នុងការឆ្លើយ និងសួរដើម្បីបង្កើតពុទ្ធិថ្មី។

**និម្មិតកម្ម**

សំដៅដល់ជាដំណើរការ ឬជាទំនោរនៃការវិវឌ្ឍសង្គមដែលមានការប្រែប្រួលទាំងរូបរាង និងសម្លេង

**នវកម្ម**

សំដៅដល់ដំណើរនៃការបង្កើតថ្មី ឬដំណើរនៃការមកដល់ថ្មី

**ប្រាជ្ញាភិវឌ្ឍន៍**

សំដៅដល់ជាការប្រើប្រាស់វិជ្ជាដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍទាំងវិជ្ជា បំណិន និងចរិយា។

**វុឌ្ឍិវិជ្ជា**

សំដៅដល់កញ្ចប់ចំណេះដឹងសម្រាប់ប្រើជាប្រយោជន៍ដល់ភាពជឿនលឿន និងការអភិវឌ្ឍជាបន្តបន្ទាប់។

**វុឌ្ឍិបំណិន**

សំដៅដល់កញ្ចប់បំណិនសម្រាប់ប្រើជាប្រយោជន៍ដល់ភាពជឿនលឿន និងការអភិវឌ្ឍជាបន្តបន្ទាប់។

**វុឌ្ឍិចរិយា**

សំដៅដល់កញ្ចប់នៃចរិយាវិជ្ជមានសម្រាប់ប្រើជាប្រយោជន៍ដល់ភាពជឿនលឿន និងការអភិវឌ្ឍជាបន្តបន្ទាប់។

**សង្កប្បសម្បទា**

សំដៅដល់កម្រិតនៃបញ្ញាក្នុងការគិត គឺកម្រិតចងចាំ យល់ ប្រតិបត្តិ វិភាគ វាយតម្លៃ និងបង្កើតថ្មី ។

**សង្កប្បបំណិន**

សំដៅដល់កញ្ចប់បំណិនក្នុងដំណើរនៃការគិត ការត្រិះរិះ និងពិចារណា ដើម្បីរកហេតុផលត្រឹមត្រូវ។

## ៩- ឯកសារយោង


- Arasumani Retnasamy, Marshall Cavendish /Singapore, (2014). History Bi-Polarity and the Cold War Secondaty (4).
- Arthur, J & Philips, R (eds) (1999) Issues in History Teaching (Issues in Subject Teaching), UK: Routledge Falmer.
- Bage, G (1999) Narrative Matters: Teaching History through stories, UK: Falmer Press.
- Ben Walsh, Cambridge IGCSE / London, (2016). Modern World History.
- Ben Walsh, Hodder Education/London, (1996). G C S E Modern World History.
- Bourdillion, H (1996) Teaching History: A Reader (Open University), UK: Open University Press.
- Cantu, D. A. (2003) Teaching Secondary History: 40 Classroom Armonk: ME Sharpe.
- Curriculum Planning and Development Division Ministry of Education., (2012). Primary Social Studies Syllabus 2012.
- Cynthia Luna Scott (2015), The futures of learning 2: What kind of learning for the 21st century?, UNESCO.
- David Chandler, Steven Boswell/Thailand , (2016). King Norodim's Head Phnom Penh Sights Beyond the Guidebooks.
- David J. Flinders, Routledge/New York, (2017). The Curriculum Studies Reader.
- Davies, P et. al (2003) Enlivening Secondary History: 40 Classroom Activities for teachers and pupils, UK: Routledge Falmer.
- Department for Education.,(2013) . The national curriculum in England Framework ducument.
- Dickenson, A et. al (eds) (2001) Raising Standards in History Education, Portland: Woburm Press.
- Esther Care, Rebekah Luo, Assessment of transversal Competencies: Policy and practice in the Asia-Pacific region, Unesco-NEQMAP, 2016
- Florida C. Leuterio, Magallanes/Philippine., (2014). History Gransformation for a Better World.
- Edinger, M (2000) Seeking History: Teaching with Primary Sources in Grades 4-6, US: Heinemann.
- Fisher, P & Leat, D (eds) (2000) Thinking Through History, UK: Routledge Falmer.
- François Legault, Éducation préscolaire Enseignement primaire., (2006). Prograammer de formation de québécoise.
- Genevieve Chapier-Legal, Belin Education /Paris., (2016) . Histoire Geographie Histoire des Arts (CM1).
- Genevieve Chapier-Legal, Belin Education /Paris., (2017). Histoire Geographie Histoire des Arts .EMC (CM2).
- Geoff Wade,and Sun Laichen ,(2010). Southeast asia in the Fifteenth Century.
- Haydyn, T et. al (2001) Learning to Teach History in the Secondary School (Learning to teach subjects in secondary schools)
- Haydyn, T et. al (2001) Thinking Through History, UK: Routledge Falmer.
- http://asean.org/
- Husbands, C (1996) What is History Teaching, UK: Open University Press.
- Imelda Wong, Wisemann PublishingSingapore, (2016). Comprehensive Guide History Secondary(1).
- Imelda Wong, Wisemann PublishingSingapore, (2017). Comprehensive Guide History Secondary(2).
- Isabel Lee, Global Publishers /Singapore, (2016). Secondary 2 History Topical Revision.
- Jacques Marseille, Nathan/France, (2001). 2 e` histoire les fibdenebts du monde contemporain.

- Jean-Baptiste de Panafieu, Bayard Jeunesse/ Fance., (2016). Pre`histoire La Grande Aventure De L'homme.
- John Wiley, and Sons, Wiley., (2011). Asia A Concise History.
- Jose' Abrami, Belin Education /Paris., (2012). Histoire Geographie(3).
- Kaylee Ng Master Arts, Redspot/ Singapore, (2016). Exam Victory in History Secondary (1).
- Kaylee Ng Master Arts, Redspot/ Singapore, (2017). Exam Victory in History Secondary (2).
- Kishore Mahbobani , and Jeffery Sng. NUS Press /Singapor., (2017). The Asean Miracle.
- Kobrin, D (1996) Beyond the Textbook: Teaching History using documents and primary sources, USA: Heinemann.
- Larsson, Y & Johnston, G (1983) Understanding the time concept in History: research findings and teaching strategies, Sydney: University of Sydney.
- Levsti, L. S. & Barton, K.C. (1996) Doing History: Investigating with Children in Elementary and Middle Schools, US: Lawrence Erlbaum Associates.
- Margaret Tan, GLM / Singapore, (2017). Understanding History Secondary (1).
- Margaret Tan, GLM / Singapore, (2017). Understanding History Secondary (2).
- Marie Dietsch-Volkringer, Magnard /Paris., (2017). Histoire.
- Marshall Cavendish /Malaysia, (2013). Social Studies for Brunei Darussalam Year 8.
- Marshall Cavendish /Singapore, (2013). Inquiring Into Our World Primary Social Studies (4B).
- Marshall Cavendish /Singapore., (2013). Inquiring Into Our World Primary Social Studies (4A).
- Marshall Cavendish /Singapore., (2014). Inquiring Into Our World Primary Social Studies (5A).
- Marshall Cavendish /Singapore., (2014). Inquiring Into Our World Primary Social Studies(5B).
- Marshall Cavendish /Singapore., (2014). Inquiring Into Our World Primary Social Studies (6A).
- Marshall Cavendish /Singapore., (2014). Inquiring Into Our World Primary Social Studies (6B).
- MES, MES., (2005). History Syllabus Lower Secondary.
- MES, MES., (2013). Lower Secondary HIistory Teaching Syllabuses.
- MES, MES., (2016). History Syllabus Pre-University H2.
- MES, singapor,.(2016). Upper Secondary Social Studies.
- Ministére de l'Education, du Loisir et du Sport,. (2014). History du 20e siécle.
- Ministére de L'éducation nationale, de L'enseignement Supérieur et de la Recherche, (1990). Programmes pour les cycles.
- Ministére de L'éducation, (2006). Programme de formation de l 'école québécoise .
- Ministry of Education Singapore., (2006). History Syllabus Lower Secondary.
- Ministry of Education Singapore., (2016). History Syllabus Lower Secondary Express Course Normal (Academic) Course.
- Ministry of Education Singapore., (2016). History Syllabus Pre-University H1.
- Ministry of Education Singapore., (2016). History Syllabus Pre-University H3.
- Ministry of Education Singapore., (2016). History Syllabus Upper Secondary Express Course Normal (Academic) Course.
- Chai-anan Samudavanija, MET/ Thailand., (2008). Basic Education Core Curriculum B.E. 2551 (A.D 2008).
- O'Hara, L & O'Hara, M (2001) Teaching History 3-11: the essential guide, New York: Continuum.
- Pak Tee Ng, Routledge/New York, (2017). Learning Siagapore.
- Percoco, J. A. (1998) A Passion for the Past: Creative Teaching of U.S. History, Portsmouth: Heinemann.
- Philips, R (2002) Reflective Teaching of History 11-18: Continuum Studies in Reflective Practice and Theory (Continuum Studies in Reflective Practice and Theory Series), New York: Continuum.

- Québec, (2017). Histoire du Québec et du Canada.
- Québec, (2017). Monde contemporain 2 unités.
- Reynaldo D. Oliveros, IBON Books/Philippine., (2014). History of the Filipino People (7).
- Reynaldo D. Oliveros, IBON Books/Philippine., (2015) .History of the Filipino People Challenges and Responses to Nationhood (5).
- Reynaldo D. Oliveros, IBON Books/Philippine., (2015). History of the Filipino People Challenges and Responses to Nationhood (6).
- Rosario Bella Guzman, IBON Books/Philippine.,(2011). Philippine History and Governance.
- Ruff, T.P & Nelson, J. T. (1997) Classroom Ready Activities for Teaching History and Geography in Grades 7-12, US: Allyn & Bacon.
- Singapore Examinations and Assessment Board, (2015). History Higher 2 (2017) (Syllabus 9752).
- Sophie Le Callennec Hatier /Paris., (2016). Histoire et histoire des arts.
- Sophie Le Callennec, Hatier /Paris., (2004). Histoire Geographie.
- Sophie Le Callennec, Hatier /Paris., (2010). Histoire Geographie.
- Sophie Le Callennec, Hatier/Paris, (2010). Histoire Ge`ographie.
- Sophie Le Callennec, Hatier/Paris., (2002). Histoire Geographie.
- Sophie Le Callennec, Hatier/Paris., (2003). Histoire Geographie.
- Taylor & Francis Group, (2017), The Curriculum Studies Reader.
- UNESCO, (2015), Global Citizenship Education: Topics and Learning Objectives
- UNESCO, (2014), Global citizenship education: Preparing learners for the challenges of the 21st century.
- UNESCO, (2016), A Teacher's Guide on the Prevention of VIOLENT EXTREMISM.
- UNESCO, (2016), Promoting intercultural dialogue and a culture of peace in Southeast Asia through shared histories.
- Vincent Kucholl, LEP/Fance., (2016). Histoire Suisse.
- ក្រសួងអប់រំ យុវជន និងកីឡា (ខែ មិថុនា ឆ្នាំ២០១០) : ប្រវត្តិវិទ្យាថ្នាក់ទី១១។
- ក្រសួងអប់រំ យុវជន និងកីឡា (ខែ ឧសភា ឆ្នាំ២០១១) : ប្រវត្តិវិទ្យាថ្នាក់ទី១២។
- ក្រសួងអប់រំ យុវជន និងកីឡា (ខែឧសភា ឆ្នាំ២០១០) : សិក្សាសង្គមថ្នាក់ទី១០។
- ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០០៩) : ប្រវត្តិវិទ្យាថ្នាក់ទី៧។
- ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០១០) : ប្រវត្តិវិទ្យាថ្នាក់ទី៨។
- ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០១១) : ប្រវត្តិវិទ្យាថ្នាក់ទី៩។
- ក្រសួងអប់រំជាតិ (១៩៧៣), ប្រវត្តិវិទ្យាថ្នាក់ទី៣, ខេមរយានកម្ម។

## ១០- បញ្ជីឈ្មោះគណៈកម្មការ

### គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

៣- លោកជំទាវ **ទន់ សាអ៊ីម**

៤- លោកជំទាវ **ឃុន រចនា**

៥- ឯកឧត្តម **ហ៊ាង ស៊ីណេ**

៦- ឯកឧត្តម **ពុត សាមិត្ត**

៧- លោកបណ្ឌិត **ម៉ុក សារ៉ុម**

៨- លោកស្រីបណ្ឌិត **ឃួន វិច្ឆិកា**

៩- លោក **អោ សៀម**

### គណៈកម្មការរៀបចំកម្មវិធីសិក្សាលម្អិត

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ិន សំណាង**

៣- លោកស្រីបណ្ឌិត **ឃួន វិច្ឆិកា**

៤- លោកបណ្ឌិត **វង់ សុធារ៉ា**

៥- លោក **មួង សុផាត**

៦- លោក **សំបូរ មាណ្ណារ៉ា**

៧- លោកបណ្ឌិត **ឌី ខាំបូលី**

៨- លោកបណ្ឌិត **តឹក មេង**

៩- លោក **ចេង ហុង**

១០- លោកស្រី **ជា កល្យាណ**

១១- លោក **ប៉ូ សុខា**

១២- លោក **ទី សុផល**

១៣- លោក **ណុប សុខា**

១៤- កញ្ញា **ហ៊ សុីវី**

១៥- លោក **មាស ភិរុណ**

១៦- លោក **អ៊ីវ សៅសុខា**

១៧- លោក **ស៊ីវ ធួន**

១៨- លោក **ឈឹម ឌីណា**

១៩- លោក **លី រមនី**

**ទីប្រឹក្សាបច្ចេកទេស**

*ទីប្រឹក្សាបច្ចេកទេស*

២០- លោក **ខៀវ វិជ្ជានន្ទ**

*ជំនួយការបច្ចេកទេស*

២១- កញ្ញា **ជិត ចាន់វន្នី**

២២- លោកស្រី **ងួន សុខកែវ**

២៣- លោកស្រី **ព្រីង ចាន់រស្មី**

២៤- លោក **យិន សុធា**

២៥- លោក **ចេង សីហា**

២៦- លោក **ហួត ប៊ុនថន**

២៧- លោក **ស៊ុន ផុន**

២៨- កញ្ញា **លន់ ម៉ាឡា**

២៩- កញ្ញា **សន សារី**

៣០- លោកស្រី **ពាង ប៉ុណ្ណារិន**

## គណៈកម្មការត្រួតពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ សំណព្វ**

៣- ឯកឧត្តមបណ្ឌិត **ជេត ជាលី**

៤- លោកបណ្ឌិត **ម៉ុក សារ៉ុម**

៥- លោក **យិន ធី**

៦- លោក **យឹម សារិន**

៧- លោក **ស៊ុន ប៊ុណ្ណា**

៨- លោក **វ៉ា វុទ្ធី**

## ជំនួយការបច្ចេកទេសកុំព្យូទ័រ

១- លោក **លឹម សុត្ថារិទ្ធ**

២- លោក **អេង វណ្ណារិទ្ធ**

៣- លោក **មឿន លិនណា**

៤- លោក **ជួន ចៃវ**

## លេខាធិការដ្ឋាន

១- លោកបណ្ឌិត **ម៉ុក សារ៉ុម**

២- លោកបណ្ឌិត **ជ័យ ចាន់អឿន**

៣- លោកបណ្ឌិត **យុន គឹមលាង**

៤- លោកបណ្ឌិត **ម៉ម សុជាតិ**

៥- លោក **អុន ស៊ីវុធថា**

៦- លោក **យិន ធី**

៧- លោក **យឹម សារិន**

៨- លោក **ហាក់ ធម្មតា**

៩- លោកស្រី **វ៉ាន់ លីណា**

**ចរិយាសម្បទា**

អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម
សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ
ការទទួលខុសត្រូវ
កាយសុខភាព
ចិត្តសុខភាព

**វិជ្ជាសម្បទា**

អក្ខរសាស្ត្រ
លេខសាស្ត្រ
ភាសាបរទេស
បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍

**បំណិនសម្បទា**

បំណិនពិចារណានិងការបង្កើតថ្មី
ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម
អនុវត្តចំណេះដឹងនិងជំនាញ